# រឿង

# ព្រះភូរិទត្តបំពេញសីលបារមី



ដោយ

ភិក្ខុធម្មថាលោ **សាន-សប្បាយ** វត្តវិសុទ្ធិមគ្គ

ព. ស. ២៥៥៦

# រឿងព្រះភូរិទត្តបំពេញសីលបារមី

កាលព្រះបរមសាស្តាទ្រង់គង់នៅក្នុងវត្តជេតពន ទៀបក្រុងសាវត្ថី ទ្រង់ប្រារព្ធឧបាសកទាំងឡាយ ហើយត្រាស់ធម្មទេសនានេះ មានពាក្យចាប់ផ្តើមថា យង្កិញ្ចិ រតនមត្ថិ ដូច្នេះជាដើម។

បានឮមកថា ក្នុងថ្ងៃឧបោសថ ពួកឧបាសកនោះ អធិដ្ឋានឧបោសថអំពីព្រឹក ហើយថ្វាយទាន ពេលខាងក្រោយភត្តម្នាក់ៗមានដៃកាន់គ្រឿងក្រអូប និងផ្កាឈើជាដើមទៅកាន់វត្តជេតពន អង្គុយក្នុងទីដ៏សមគួរដើម្បីស្តាប់ព្រះធម៌ កាលនោះព្រះបរមសាស្តាស្តេចយាងមកកាន់ធម្មសភា ទ្រង់ប្រថាប់គង់ខាងលើពុទ្ធាសនៈ ដែលគេរៀបចំទុកហើយ ព្រះអង្គទតឃើញភិក្ខុសង្ឃ ទ្រង់ជ្រាបថា បណ្តាភិក្ខុសង្ឃទាំងឡាយ ធម្មកថាតាំងឡើងប្រារព្ធភិក្ខុពួកណា ព្រះតថាគតទាំងឡាយទ្រង់មានព្រះពុទ្ធដីកាប្រាស្រ័យជាមួយនឹងភិក្ខុពួកនោះ ព្រោះហេតុនោះ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្តែងរឿងទាក់ទងទៅនឹងបុព្វចរិយា ដែលតាំងឡើងប្រារព្ធឧបាសក

ទាំងឡាយដូច្នេះហើយ ទើបទ្រង់មានពុទ្ធដីកាប្រាស្រ័យជាមួយនឹងឧបាសកពួកនោះហើយ ត្រាស់សួរថា តើពួកអ្នកជាអ្នករក្សាឧបោសថឬ? កាលឧបាសកក្រាបទូលឲ្យព្រះមានព្រះភាគ ទ្រង់ជ្រាបព្រះអង្គទើបទ្រង់ត្រាស់ថាល្អហើយឧបាសកទាំងឡាយ កាលបានជួបព្រះពុទ្ធដូចតថាគត ជាអ្នកឲ្យឱវាទ ការធ្វើឧបោសថ ចាត់ថាពួកលោកធ្វើកម្មដ៏ល្អ មិនជាអស្ចារ្យឡើយៗ សូម្បីបោរាណកបណ្ឌិតជាអ្នកមិនអើពើនឹងយសសក្តិ ទ្រព្យសម្បត្តិ ហើយលោកបានលះបង់យសដ៏ធំ ធ្វើឧបោសថបានដូចគ្នា ត្រាស់ដូច្នេះហើយ ព្រះមាន-ព្រះភាគក៏ទ្រង់តុណ្ហីភាពៗ ភិក្ខុសង្ឃទាំងឡាយក្រាបទូលអារាធនាទើបព្រះមានព្រះភាគទ្រង់នាំអតីតនិទានមកសម្តែងថា :

ម្នាលភិក្ខុទាំងឡាយ ក្នុងអតីតកាលមានព្រះរាជាមួយព្រះអង្គទ្រង់ព្រះនាមថា ព្រះបាទព្រហ្មទត្ត គ្រងរាជសម្បត្តិក្នុងក្រុងពារាណសី បានប្រទានតំណែងឧបរាជដល់ព្រះរាជឱរស ទ្រង់ទតឃើញយសធំរបស់ព្រះរាជឱរសនោះ ទើបទ្រង់កើតបរិវិតក្កៈឡើងថា ព្រះរាជឱរសនេះនឹងដណ្តើមរាជសម្បត្តិរបស់យើងជាមិន

ខាន រួចក៏ឲ្យគេហៅព្រះរាជឱរសនោះមក ទើបទ្រង់ត្រាស់ថា ម្នាលកូនមាសឪពុក បុត្រមិនអាចនៅទីនេះបានទេ បុត្រចូរចេញពីទីនេះសិន ហើយទៅនៅក្នុងស្ថានទីដែលបុត្រពេញចិត្តចុះ ឲ្យឆ្ងាយអំពីយើង កាលបើអត់អំពីបិតាទៅ បុត្រចូរយករាជសម្បត្តិដែលជារបស់នៃត្រកូលចុះ។ ព្រះរាជឱរសទ្រង់ទទួលព្រះរាជតម្រាស់ហើយ ទើបថ្វាយបង្គំលាព្រះរាជបិតា រួចចាកចេញអំពីព្រះនគរទៅ។ ព្រះរាជកុមារទៅដល់ស្ទឹងយមុនាដោយលំដាប់តាមដំណើរ ហើយឲ្យគេសាងបណ្ណសាលាក្នុងចន្លោះទន្លេយមុនា សមុទ្រ និងភ្នំ។ មានឫសឈើ និងផ្លែឈើជាអាហារ អាស្រ័យនៅក្នុងទីនោះ។ គ្រានោះនាងនាគមាណវិកា ដែលស្វាមីបានស្លាប់ចោលនៅក្នុងពិភពនាគស្ថិតនៅត្រើយប្រាំងនៃសមុទ្រ ត្រួតមើលនូវយសរបស់អ្នកដទៃដែលមានស្វាមីអាស្រ័យកិលេសក៏ត្រេកត្រអាលឡើង។ ទើបចេញចាកពិភពនាគ ត្រាច់ទៅត្រង់ប្រាំងសមុទ្ទ បានឃើញដានជើងរបស់ព្រះរាជឱរស ទើបដើរទៅតាមដានជើងនោះ ហើយឃើញបណ្ណ-សាលាមួយ។

គ្រានោះព្រះរាជឱរសបានទៅកាន់ព្រៃ ដើម្បីត្រូវការផ្លែឈើផ្សេងៗ។ នាងនាគចូលទៅកាន់បណ្ណសាលា បានឃើញគ្រឿងកម្រាលធ្វើដោយឈើ និងបរិក្ខារដ៏សេសទើបគិតថា នេះប្រហែលជាទីនៅរបស់បព្វជិតមួយរូប យើងនឹងសាកល្បងមើល ថាតើគេបួសដោយសទ្ធាដែរឬទេហ្ន៎? បើគេនោះចូលមកបួសដោយសទ្ធានឹងបង្អោនទៅក្នុងនេក្ខម្មៈ គេនឹងមិនរីករាយក្នុងការដេកដែលយើងស្អិតស្អាងទុកឡើយ បើគេរីករាយនៅក្នុងកាម គេនឹងមិនបួសដោយសទ្ធាទេ ក៏នឹងដេកក្នុងទីដេកដែលយើងចាត់ចែងទុក។ កាលបើដូច្នេះ យើងនឹងចាប់គេធ្វើជាស្វាមីរបស់យើង នៅក្នុងទីនេះឯង។ នាងទៅកាន់ពិភពនាគនាំផ្កាឈើទិព្វ និងគ្រឿងក្រអូបដ៏ជាទិព្វ មកចាត់ចែងកន្លែងដេកឲ្យសម្រេចដោយផ្កាឈើ បាននាំផ្កាឈើទុកឯបណ្ណសាលា រោយរាយលម្អផ្កាក្រអូប តាក់តែងបណ្ណសាលា ហើយនាងទៅនៅឯពិភពនាគដូចដើមវិញ។

ព្រះរាជឱរសមកក្នុងវេលាល្ងាច ចូលទៅដល់បណ្ណសាលា ទ្រង់ទតឃើញសេចក្ដីប្រព្រឹត្តទៅនៅទីនោះ ទើបគិតថា នរណាហ្ន៎

រៀបចំទីដេកនេះ? ដូច្នេះហើយ ទើបសោយផ្លែឈើ តូចធំ គិតថា គួរអស្ចារ្យ ផ្កាឈើមានក្លិនក្រអូប គួរអស្ចារ្យណាស់ ផ្កាឈើមានក្លិនក្រអូប អ្នកណាតុបតែងទីដេក ឲ្យជាទីគាប់ព្រះទ័យរបស់យើង ក៏កើតជាសោមនស្សឡើង ព្រោះមិនបានបួសដោយសទ្ធាទេ ទើបផ្ទុំត្រឡប់ចុះឡើង នៅលើទីក្រឡាព្រះបន្ទំផ្កាឈើ ក៏លង់លក់បាត់ទៅ ថ្ងៃស្អែកឡើង កាលព្រះអាទិត្យរះហើយ ក្រោកឡើង តែមិនបានសម្អាតបណ្ណសាលាទេ ក៏បានទៅដើម្បីត្រូវការបួសឈើ និងផ្លែឈើតូចធំនៅក្នុងព្រៃទៀត។ ក្នុងខណៈនោះឯង នាងនាគមាណវិកា មកឃើញផ្កាឈើស្វិតស្រពោន ទើបដឹងថា តាបសនេះបង្អោនចិត្តទៅក្នុងកាម មិនបានបួសដោយសទ្ធាឡើយ យើងអាចនឹងចាប់គេធ្វើជាស្វាមីបាន ដូច្នេះហើយ ក៏នាំផ្កាឈើចាស់ៗចេញទៅ នាំផ្កាឈើដទៃៗមក ចាត់ចែងទីដេកដូចមុននោះឯង ប្រដាប់បណ្ណសាលា រោយរាយផ្កាឈើក្នុងទីចង្ក្រម ហើយទៅកាន់ភពនាគដូចដើមវិញ។ សូម្បីក្នុងថ្ងៃនោះ ព្រះរាជឱរសក៏ផ្ទុំនៅលើផ្កាឈើជាទីដេក ថ្ងៃស្អែកឡើងទើបគិតថា

នរណាហ្ន៎ប្រដាប់បណ្ណសាលានេះ? ព្រះអង្គមិនទៅដើម្បីត្រូវការផ្លែឈើតូចធំទៀតទេ រួចទៅនៅក្នុងទីកំបាំងមិនឆ្ងាយពីបណ្ណសាលាប៉ុន្មានឡើយៗ ចំណែកនាងនាគមាណវិកាកាន់គ្រឿងក្រអូប និងផ្កាឈើជាច្រើន មកអាស្រមបទ ព្រះរាជឱរសកាលមើលឃើញនាងនាគមាណវិកា ដែលមានរូបដ៏ស្រស់ស្អាត មានចិត្តប្រតិព័ទ្ធសំដែងខ្លួនចូលទៅបណ្ណសាលារបស់ខ្លួន ក្នុងវេលានាងនាគបាត់ចែងផ្កាឈើ ហើយសួរថា នាងជាអ្នកណា? នាងឆ្លើយថា បពិត្រព្រះតាបស ខ្ញុំឈ្មោះថា នាងនាគមាណវិកាៗ ព្រះរាជឱរសត្រាស់សួរថា នាងមានស្វាមីហើយ ឬនៅ? នាងឆ្លើយថា បពិត្រព្រះតាបស កាលពីមុនខ្ញុំមានស្វាមី តែឥឡូវនេះស្វាមីរបស់ខ្ញុំមិនរស់នៅទេៗ នាងសួរថា តើលោកម្ចាស់ ឈ្មោះអ្វីដែរ? ព្រះរាជ-ឱរសឆ្លើយថា ខ្ញុំឈ្មោះព្រហ្មទត្តកុមារ ជាឱរសរបស់ព្រះបាទក្រុងពារាណសីៗ ក៏ព្រោះហេតុអ្វី ទើបនាង ចេញពីពិភពនាគមកនៅក្នុងទីនេះ? នាងឆ្លើយថា បពិត្រព្រះរាជឱរស ទូលព្រះបង្គំមើលឃើញយសនៃនាងនាគមាណវិកា ជាអ្នកមានស្វាមីក្នុងទីនោះ

អាស្រ័យកិលេស ទើបត្រេកត្រអាល នឹងកាមឡើងចេញពីភព នាគនោះដើរស្វែងរកស្វាមី។ ព្រះរាជឱរស ត្រាស់ថា ព្រោះហេតុនោះ ម្នាលនាងដ៏ចម្រើន សូម្បីយើងក៏មិនបានបួសដោយសទ្ធាទេ ព្រោះត្រូវព្រះរាជបិតាបានបណ្តេញចេញពីព្រះនគរ ទើបមកនៅក្នុងទីនេះ នាងកុំគិតទៅឡើយ យើងនឹងជាស្វាមីរបស់នាង។ សូម្បីអ្នកទាំងពីរក៏បានស្ម័គ្ររួមសង្វាសគ្នាក្នុងទីនោះៗឯង។ នាងសាងដំណាក់មានតម្លៃច្រើន ដោយអានុភាពរបស់ខ្លួន និងនាំបល្ល័ង្កគួរដល់តម្លៃច្រើន រួចតុបតែងទីដេក។ ចាប់ដើមតាំងពីពេលនោះមក ព្រះរាជឱរសនោះមិនបានសោយឫសឈើ និងផ្លែឈើតូចធំទៀតទេ សោយតែបាយ និងទឹកដ៏ជាទិព្វទាំងនោះ ដើម្បីចិញ្ចឹមជីវិត។

គ្រាខាងក្រោយមក នាងនាគមាណវិកាតាំងគភ៌ ប្រសូតបុត្រប្រុសមួយ ពួកញាតិបានដាក់ឈ្មោះថា សាគរព្រហ្មទត្ត ព្រោះលោកប្រសូតឯច្រាំងទន្លេសាគរ ក្នុងកាលដែលបុត្រអាចដើរបាន នាងនាគមាណវិកាក៏សម្រាលកូនស្រីមួយទៀត ពួក

ញាតិបានដាក់ឈ្មោះថា សមុទ្ទជា ព្រោះនាងបានកើតនៅក្បែរឆ្នេរសមុទ្រ។ អស់កាលដ៏យូរកន្លងទៅ កាលថ្ងៃមួយនោះមានព្រានព្រៃអ្នកក្រុងពារាណសីម្នាក់ បានទៅដល់លំនៅរបស់ព្រះរាជឱរសហើយធ្វើបដិសណ្ឋារៈ ចងចាំព្រះរាជឱរសបាន ក៏ស្នាក់នៅក្នុងទីនោះអស់រយៈពេល២- ៣ថ្ងៃ ហើយពោលថា បពិត្រព្រះសម្មតិទេពខ្ញុំព្រះអង្គនឹងប្រាប់ការដែលព្រះអង្គនៅក្នុងទីនេះ ដល់រាជត្រកូលក្រាបថ្វាយបង្គំព្រះឱរសហើយ រួចចេញចាកពីទីនោះ បានត្រឡប់ទៅកាន់ព្រះនគរពារាណសី។

ក្នុងកាលនោះព្រះរាជាក្រុងពារាណសីបានសោយទិវង្គតទៅ ពួកអាមាត្យធ្វើសរីរកិច្ចដល់ព្រះរាជារួចរាល់ហើយ ប្រជុំក្នុងថ្ងៃទី៧ បានប្រឹក្សាគ្នាថា ឈ្មោះថារាជសម្បត្តិនឹងមិនមានព្រះរាជា រមែងតាំងនៅមិនបាន ពួកយើងមិនដឹងទីនៅរបស់ព្រះរាជឱរសនៅទីណាហើយនៅមានព្រះជន្ម ឬមិនមានទេ? ទើបនាំគ្នាផ្សងបុស្សរថរកព្រះរាជា។ ខណៈនោះនាយព្រានព្រៃចូលទៅដល់ព្រះនគរ ដឹងរឿងរបស់អាមាត្យទាំងនោះហើយ ទើបទៅកាន់សម្នាក់របស់ពួក

អាមាត្យ ហើយគិតថា យើងនៅក្នុងសម្នាក់ព្រះរាជឱរស៣- ៤ថ្ងៃដែរ ទើបត្រឡប់មកវិញ។ ហើយបានទៅប្រាប់រឿងនោះដល់ពួកអាមាត្យទាំងឡាយ លំដាប់នោះពួកអាមាត្យបានស្ដាប់ពាក្យនោះហើយ ក៏បានឲ្យរង្វាន់ដល់នាយព្រានព្រៃជាច្រើន។ មាននាយព្រានជាអ្នកនាំផ្លូវទៅក្នុងកន្លែងនោះ បានធ្វើបដិសណ្ឋារៈ ទើបប្រាប់សេចក្ដីដែលព្រះរាជាទ្រង់សោយទិវង្គត។ ពួកអាមាត្យទាំងឡាយ ក្រាបទូលថា សូមព្រះអង្គទទួលគ្រងរាជសម្បត្តិចុះ ក្រាបទូល ព្រះរាជឱរសទ្រង់ព្រះតម្រិះថា យើងនឹងដឹងចិត្តរបស់នាងនាគមាណវិកាដូចម្ដេចបាន? ដូច្នេះហើយក៏ចូលទៅរកនាងទើបត្រាស់ថា ម្នាលនាងដ៏ចម្រើន ព្រះរាជបិតារបស់យើងចូលទិវង្គតទៅហើយ អាមាត្យទាំងឡាយមកក្នុងទីនេះ ដើម្បីយកស្វេត-ច្ឆត្រឲ្យយើង សូមនាងទៅជាមួយយើងចុះ យើងទាំងពីរនាក់នឹងគ្រងរាជសម្បត្តិក្នុងក្រុងពារាណសី ប្រមាណ១២យោជន៍ដោយជុំវិញនាងនឹងបានជាស្រ្តីធំជាងស្រ្តី១៦០០០នាក់។ នាងពោលថា បពិត្រព្រះស្វាមីទូលព្រះបង្គំមិនអាចនឹងទៅបានទេ។ ព្រះរាជឱរសសួរថា

ព្រោះហេតុអ្វី? នាងពោលថា ខ្ញុំម្ចាស់ជាអសិរពិស កាចសាហាវខ្លាំងណាស់ រមែងក្រោធខឹង សូម្បីដោយហេតុត្រឹមតែតិចតួចប៉ុណ្ណោះ នឹងឈ្មោះថាការនៅរួមប្ដីតែមួយជាការៈធ្ងន់ៗ បើខ្ញុំម្ចាស់បានឃើញ ឬបានឮ បានដឹងរឿងអ្វីដែលនាំឲ្យក្រេវក្រោធ ក្រឡេកមើលអ្វីមួយ របស់នោះនឹងខ្ទាត់ខ្ចាយទៅដូចជាល្អងធូលីបាន ព្រោះហេតុនេះ បានជាខ្ញុំម្ចាស់មិនអាចទៅជាមួយនឹងព្រះអង្គបានទេៗ សូម្បីក្នុងថ្ងៃស្អែកឡើង ព្រះរាជឱរសក៏ទៅអង្វរនាងម្ដងទៀតៗ លំដាប់នោះ ទើបនាងពោលជំទាស់យ៉ាងនេះថា ខ្ញុំម្ចាស់នឹងមិនអាចទៅដោយបរិយាយណាៗបានឡើយៗ ចំណែកនាគកុមារបុត្ររបស់យើងទាំងពីរនេះ ជាជាតិមនុស្ស ព្រោះកើតដោយសម្ពពជាមួយនឹងព្រះអង្គ បើបុត្រទាំងនោះនៅមានសេចក្ដីស្រឡាញ់ចំពោះយើង សូមព្រះអង្គចូរកុំប្រមាទក្នុងបុត្រទាំងនោះអី ប៉ុន្តែបុត្រទាំងនេះឯង ជាពូជដែលកើតអំពីទឹកដ៏ទន់ភ្លន់ កាលធ្វើដំណើរតាមផ្លូវត្រូវលំបាកដោយខ្យល់ កម្ដៅថ្ងៃនឹងគួរដល់សេចក្ដីស្លាប់ ព្រះស្វាមីគប្បីឲ្យគេធ្វើទូកមួយ ដាក់ទឹកឲ្យពេញ ហើយឲ្យបុត្រទាំងនោះចុះ

កម្សាន្តលេង គប្បីធ្វើស្រះបោក្ខរណីខាងក្នុងនគរដល់បុត្រទាំងនោះ សូមនាំទៅចុះ។ រីឯនាងនាគនោះពោលយ៉ាងនេះហើយ ក៏ថ្វាយបង្គំព្រះរាជឱរស ធ្វើប្រទក្សិណឱបបុត្រឲ្យអង្គុយត្រង់ចន្លោះសុដន់ ថើបត្រង់សីសៈ ប្រគល់ឲ្យដល់ព្រះរាជឱរស យំរៀបរាប់ហើយបាត់ទៅក្នុងទីនោះឯង បានទៅកាន់ពិភពនាគដូចដើមវិញ ចំណែកព្រះរាជឱរសកើតសេចក្ដីខ្សឹកខ្សួលទោមនស្សមានព្រះនេត្រពោរពេញទៅដោយទឹកភ្នែក។ ចេញអំពីនិវេសន៍ ជូតទឹកភ្នែកហើយ ចូលទៅរកពួកអាមាត្យ។ ពួកអាមាត្យទាំងនោះ អភិសេកព្រះរាជឱរសក្នុងទីនោះឯង ហើយទូលថា បពិត្រព្រះសម្មតិទេព ពួកទូលព្រះបង្គំនឹងទៅកាន់ព្រះនគររបស់ព្រះអង្គក្រាបទូល។ ព្រះរាជាមានព្រះរាជឱង្ការថា បើដូច្នោះពួកលោកចូរប្រញាប់ធ្វើទូកលើកឡើងកាន់រទេះហើយដាក់ទឹកឲ្យពេញ សូមពួកលោកប្រមូលផ្កាឈើផ្សេងៗដែលសម្បូណ៌ដោយពណ៌ និងក្លិនដាក់ខាងលើទឹក បុត្រទាំងឡាយរបស់យើងជាអ្នកមានពូជអំពីទឹក បុត្រទាំងនោះលេងទឹកក្នុងទូកនោះនឹងស្រួលមិនលំបាក។ ពួកអាមាត្យបានធ្វើយ៉ាង

នោះហើយ។ ព្រះរាជាស្ដេចយាងរហូតដល់ក្រុងពារាណសី ស្ដេច ចូលទៅកាន់ព្រះនគរ ដែលគេតាក់តែងទុក ហែហមទៅដោយស្រ្ដី អ្នករបាំ និងអាមាត្យជាដើម ប្រមាណ១៦០០០នាក់ប្រថាប់គង់ខាង លើផ្ទៃដ៏ធំសោយទឹកមហាបាន៧ថ្ងៃ ហើយឲ្យគេជីកស្រះបោក្ខរណី ដើម្បីប្រយោជន៍ដល់បុត្រទាំងឡាយ។ បុត្រទាំងឡាយ បានលេង ក្នុងទីនោះជាប់ជានិច្ច។ ខាងក្រោយមក ថ្ងៃមួយកាលបុត្រទាំងឡាយ នាំគ្នាលេងទឹកក្នុងស្រះបោក្ខរណី អណ្ដើកមួយក្បាលបានចូលទៅ កាន់ស្រះនោះហើយ មិនឃើញទីកន្លែងដែលត្រូវចេញមកវិញ ទើប មុជចុះទៅក្នុងស្រះបោក្ខរណី ក្នុងវេលាក្មេងលេងទឹក ផុសអំពីទឹក អើតក្បាលឡើងមក ឃើញពួកក្មេងទាំងនោះ ទើបមុជក្បាលចុះ ទៅក្នុងទឹកវិញ។ បុត្រទាំងឡាយរបស់ព្រះរាជាឃើញអណ្ដើក ក៏ តក់ស្លុតភ័យខ្លាច យាងទៅកាន់សំណាក់ព្រះរាជបិតាក្រាបទូលថា បពិត្រព្រះបិតា នៅក្នុងស្រះបោក្ខរណីមានយក្ខមួយ ធ្វើឲ្យពួក ទូលព្រះបង្គំតក់ស្លុតភ័យខ្លាច។ ព្រះរាជាទ្រង់បង្គាប់ពួករាជបុរស ថា ពួកលោកចូរទៅចាប់យក្ខនោះមក។ រាជបុរសទាំងនោះបង់

សំណាញ់បានអណ្ដើកមួយនាំយកទៅថ្វាយព្រះរាជា ព្រះរាជកុមារទាំងឡាយបានឃើញអណ្ដើកនោះហើយ ស្រែកឡើងថា នេះជាបិសាចព្រះវរបិតា។ ព្រះរាជាទ្រង់ក្រេវក្រោធនឹងអណ្ដើកយ៉ាងខ្លាំង ដោយសេចក្ដីស្រឡាញ់ចំពោះបុត្រ ទើបបង្គាប់ថា ពួកលោកចូរទៅធ្វើកម្មករណ៍ដល់អណ្ដើកនេះចុះ បណ្ដារាជបុរសទាំងឡាយមានរាជបុរសម្នាក់ពោលថា អណ្ដើកនេះជាអ្នកបង្កពៀរដល់ព្រះរាជា គួរយកវាទៅដាក់ក្នុងត្បាល់ ហើយយកអង្រែបុកឲ្យល្អិត។ អាមាត្យពួកខ្លះពោលថា គួរនឹងអាំងឲ្យឆ្អិនក្នុងភ្លើងបីជង ហើយបរិភោគឲ្យអស់។ អាមាត្យពួកខ្លះពោលថា គួរនឹងស្ងោរវាក្នុងខ្ទះនោះឯង។ ប៉ុន្ដែអាមាត្យម្នាក់ជាអ្នកខ្លាចទឹកពោលឡើងថា គួរនឹងបោលអណ្ដើកនេះចុះទៅក្នុងទឹក ដែលមានព្រៃត្រង់ទន្លេយមុនាវានឹងដល់នូវសេចក្ដីវិនាសធំក្នុងទីនោះឯងហើយ ព្រោះកម្មករណ៍របស់អណ្ដើកនោះបែបនេះរមែងមិនមាន។

អណ្ដើកបានស្ដាប់ពាក្យ សម្ដីរបស់អាមាត្យខាងក្រោយនេះទើបអើតក្បាល និយាយយ៉ាងនេះថា បពិត្រលោកដ៏ចម្រើនហេតុអ្វី

ទៅលោក តើយើងធ្វើអ្វីខុស ដែលធ្វើឲ្យលោកពិចារណាដល់កម្មករណ៍បែបនេះនឹងខ្ញុំ? ខ្ញុំអាចអត់ធន់កម្មករណ៍ក្រោយនេះបាន រីឯបុគ្គលមុននោះជាអ្នកគ្រោតគ្រាតក្រៃពេក លោកកុំពោលពាក្យបែបនោះឡើយ។ ព្រះរាជាទ្រង់ព្រះសណ្ដាប់ដូច្នោះ គួរនឹងធ្វើសេចក្ដីទុក្ខដល់អណ្ដើកនេះដូច្នោះហើយ ទើបឲ្យប្រលែងចោលទៅក្នុងទឹក ដែលមានព្រៃត្រង់ទន្លេយមុនា។ អណ្ដើកនោះដល់អន្លង់ទឹកជាទីទៅកាន់ពិភពនាគមួយកន្លែង បានទៅដល់ពិភពនាគ។ លំដាប់នោះពួកនាគមាណព បុត្ររបស់ស្ដេចនាគឈ្មោះថាធតរដ្ឋៈ កំពុងលេងនៅក្នុងអន្លង់ទឹក ឃើញអណ្ដើកនោះហើយ ទើបពោលថា ពួកយើងរាល់គ្នាចូរចាប់វាជាទាសៈចុះ។ អណ្ដើកនោះគិតថា យើងរួចចាកអំពីដៃរបស់ព្រះរាជាក្រុងពារាណសី ហើយឥឡូវនេះមកដល់ដៃរបស់ពួកនាគ ជាបុគ្គលគ្រោតគ្រាតបែបនេះម្ដងទៀត យើងនឹងគប្បីរួចខ្លួនដោយឧបាយដូចម្ដេចទៅហ្ន៎? អណ្ដើកគិតថា ឧបាយនេះប្រើការបាន យើងនឹងគប្បីនិយាយមុសាវាទទើបរួចខ្លួន ហើយពោលឡើងថា ពួកលោកមកអំពីសំណាក់របស់ស្ដេចនាគ

ឈ្មោះធតរដ្ឋៈ ព្រោះហេតុអ្វីបានជា ពួកលោកពោលយ៉ាងនេះទៅវិញ? ខ្ញុំជាអណ្ដើកឈ្មោះចិត្តចូឡៈជាទូតនៃព្រះរាជាក្រុងពារាណសីមកកាន់សំណាក់របស់ស្ដេចនាគឈ្មោះថាធតរដ្ឋៈ ព្រះរាជារបស់យើងមានបំណងនឹងឲ្យរាជធីតាដល់ស្ដេចនាគឈ្មោះធតរដ្ឋៈ ទើបបញ្ជូនយើងមក សូមលោកចូរបង្ហាញយើងដល់ស្ដេចនាគនោះចុះៗ នាគមាណពទាំងនោះ ជឿហើយកើតសោមនស្សរីករាយ បាននាំអណ្ដើកនោះទៅកាន់សម្នាក់ព្រះរាជា ក្រាបទូលសេចក្ដីនោះដល់ព្រះរាជា ស្ដេចបង្គាប់ឲ្យហៅអណ្ដើកនោះមក ដោយពាក្យថា ចូរនាំវាមកចុះ គ្រាន់តែឃើញអណ្ដើកនោះភ្លាម ក៏សព្វព្រះរាជហឫទ័យត្រាស់ថា អ្នកឯង មានរាងកាយដ៏លាមកបែបនេះ មិនអាចធ្វើជាទូតកម្មបានទេ អណ្ដើកបានស្ដាប់ពាក្យនោះហើយទើបក្រាបទូលថា បពិត្រមហារាជ ឈ្មោះថាអ្នកជាទូត នឹងមានរាងកាយប្រមាណប៉ុនដើមត្នោតឬ? សេចក្ដីពិតរាងកាយធំ ឬតូចមិនជាប្រមាណទេ ការធ្វើកម្មក្នុងទីដែលទៅហើយៗឲ្យសម្រេចនោះឯងទើបជាប្រមាណ ដូច្នោះ បពិត្រមហារាជទូតជាច្រើនរបស់ព្រះរាជានៃយើងជាមនុស្ស

រមែងធ្វើការងារខាងលើគោក សត្វបក្សីរមែងធ្វើការងារខាងលើអាកាស ឯខ្ញុំព្រះអង្គឈ្មោះចិត្តចូឡៈដល់ឋានន្តរៈជាទីប្រោសប្រាណរបស់ព្រះរាជា ជាអ្នកគ្រប់គ្រងពួកស្រុក រមែងធ្វើកម្មក្នុងទឹក សូមព្រះអង្គកុំសង្កត់សង្កិនមើលងាយទូលព្រះបង្គំឡើយៗ ដូច្នោះហើយទើបសរសើរគុណរបស់ខ្លួនមានប្រការផ្សេងៗ។ លំដាប់នោះឯងស្តេចនាគធតរដ្ឋៈ ទើបសួរអណ្តើកនោះថា អ្នកឯងហ្នឹងដែលព្រះរាជាបញ្ជូនមកដើម្បីត្រូវការអ្វី? អណ្តើកពោលឡើងថា បពិត្រមហារាជ ព្រះរាជារបស់ទូលព្រះបង្គំត្រាស់នឹងខ្ញុំព្រះអង្គយ៉ាងនេះថា យើងនឹងធ្វើមិត្តធម៌ជាមួយនឹងព្រះរាជា អ្នកជម្ពូទ្វីបទាំងអស់ឥឡូវនេះយើងគួរនឹងធ្វើមិត្តធម៌ជាមួយនឹងស្តេចធតរដ្ឋៈ យើងនឹងឲ្យនាងសមុទ្ទជា ជាធីតារបស់យើងដល់ស្តេចនាគធតរដ្ឋៈ ទើបបញ្ជូនខ្ញុំព្រះអង្គមក ដោយព្រះតម្រាស់ថា សូមលោកកុំធ្វើការឲ្យយឺតយូរឡើយៗ ចូរបញ្ជូនបុរសទាំងឡាយ ទៅជាមួយខ្ញុំព្រះអង្គនឹងកំណត់ថ្ងៃយកនាងទារិកាចុះ ស្តេចនាគនោះត្រេកអររីករាយឲ្យធ្វើសក្ការៈហើយ បញ្ជូននាគមាណព៤នាក់ទៅជាមួយនឹងអណ្តើក

នោះដោយពាក្យថា ពួកលោកទៅចុះចូរស្ដាប់ពាក្យរបស់ព្រះរាជា កំណត់ថ្ងៃ ហើយចូរមកវិញៗ នាគមាណពទាំងនោះទទួលពាក្យ ហើយ ទើបនាំអណ្ដើកចេញចាកពិភពនាគៗ អណ្ដើកឃើញស្រះ ឈូកមួយកន្លែង ក្នុងរវាងស៊ឹងយមុនា និងក្រុងពារាណសីមាន សេចក្ដីប្រាថ្នានឹងគេចទៅដោយឧបាយម្យ៉ាង ទើបពោលយ៉ាងនេះ ថា ម្នាលនាគមាណពដ៏ចម្រើនទាំងឡាយ ព្រះរាជារបស់យើង និងបុត្រភរិយារបស់ព្រះរាជា ឃើញយើងត្រាច់ទៅក្នុងទឹកទៅកាន់ ព្រះរាជនិវេសន៍អង្វរថា ឯងចូរឲ្យផ្កាឈូកដល់យើង ចូរឲ្យក្រឌី ឈូក យើងនឹងកាន់យកក្រឌីឈូកទាំងនោះ ដើម្បីប្រយោជន៍ ដល់ព្រះរាជាទាំងនោះ ពួកលោកចូរប្រលែងខ្ញុំក្នុងទីនេះចុះ បើ កាលណាពួកលោកមិនឃើញខ្ញុំ សូមចូលទៅកាន់សម្នាក់របស់ ព្រះរាជាជាមុនទៅ យើងនឹងឃើញពួកលោកក្នុងទីនោះឯងៗ នាគ- មាណពជឿពាក្យសម្ដីរបស់អណ្ដើកនោះហើយ ទើបបានពន្លែង អណ្ដើកនោះទៅ អណ្ដើកបានអែបនៅក្នុងទឹកន្លែងដ៏សមគួរមួយ នៅទីនោះរួបក៏គេចខ្លួនបាត់ទៅៗ ចំណែកឯនាគមាណពមិនឃើញ

អណ្តើកមកវិញ ទើបចូលទៅគាល់ព្រះរាជាដោយភេទនៃមាណព តាមសញ្ញាថា យើងនឹងទៅកាន់សម្នាក់ព្រះរាជា។



ចប់កាច្ឆបកណ្ឌ

ព្រះរាជាទ្រង់ធ្វើបដិសណ្ឋារៈហើយ ទ្រង់ត្រាស់សួរថា ពួកលោកមកអំពីទីណា? នាគមាណពទាំងឡាយក្រាបទូលថា បពិត្រមហារាជ ពួកទូលព្រះបង្គំមកពីសម្នាក់ស្ដេចនាគឈ្មោះធតរដ្ឋៈ។ ព្រះរាជាមានព្រះរាជឱង្ការត្រាស់សួរថា ព្រោះហេតុអ្វីបានជាពួកលោកមកក្នុងទីនេះ? នាគមាណពទាំងឡាយក្រាបទូលថា បពិត្រមហារាជ ពួកទូលព្រះបង្គំជាទូតនៃស្ដេចនាគ ធតរដ្ឋៈឯណោះ ស្ដេចនាគធតរដ្ឋៈ បានសួរដល់សេចក្ដីមិនមានរោគរបស់ព្រះអង្គ ហើយបើព្រះអង្គប្រាថ្នានូវវត្ថុណា ស្ដេចធតរដ្ឋៈនឹងឲ្យវត្ថុនោះដល់ព្រះអង្គ បានឮមកថា ព្រះអង្គនឹងប្រទាននាងសមុទ្ទជា ជាធីតារបស់ព្រះអង្គ ឲ្យជាមហេសីរបស់ព្រះរាជានៃពួកទូលព្រះបង្គំក្រាបទូល។

កាលប្រកាសសេចក្ដីនោះហើយ ទើបពោលគាថាដូច្នេះថា :

០១. យង្កិញ្ចិ រតនមត្ថិ ធតរដ្ឋនិវេសនេ
សព្វានិ តេ ឧបយន្តុ ធីតរំ ទេហិ រាជិនោ។

រតនៈណាមួយមានក្នុងនិវេសន៍របស់នាគរាជព្រះនាមធតរដ្ឋៈ រតនៈទាំងអស់នោះ ចូរមកដល់ព្រះអង្គ សូមព្រះអង្គទ្រង់ប្រទានធីតាដល់ព្រះរាជាយើង។ ព្រះរាជាកាលបានស្ដាប់ដូច្នោះហើយ ទើបត្រាស់គាថាដូច្នេះថា :

០២. ន នោ វិវាហោ នាគេហិ កតបុព្វោ កុទាចនំ
តំ វិវាហំ អសំយុត្តំ កថំ អម្ហេ ករោមសេ។

វិវាហៈជាមួយនឹងពួកនាគ យើងមិនធ្លាប់ធ្វើក្នុងកាលណាម្ដងទេ យើងនឹងធ្វើវិវាហៈមិនសមគួរនោះដូចម្ដេចកើត។

នាគមាណពបានស្ដាប់ដូច្នោះហើយ ទើបពោលថាបើសម្ពន្ធ-ភាពនឹងព្រះបាទធតរដ្ឋៈមិនសមគួរនឹងព្រះបាទព្រហ្មទត្តទេ កាលដូច្នេះ ព្រោះហេតុដូចម្ដេច បានជាព្រះអង្គបញ្ជូនអណ្ដើកឈ្មោះថាចិត្តចូឡៈ ជាឧបដ្ឋាករបស់ព្រះអង្គ ទៅជាទូតដល់ព្រះរាជារបស់ពួកយើងថា យើងនឹងឲ្យធីតារបស់យើង ឈ្មោះសមុទ្ទជា (ឲ្យដល់ស្ដេចនាគ) កាលបញ្ជូនព្រះរាជសារយ៉ាងនេះហើយ ឥឡូវ

នេះព្រះអង្គប្រែរជាមើលងាយព្រះរាជារបស់ពួកទូលព្រះបង្គំទៅវិញ ពួកយើងឈ្មោះថាជានាគមាណព ស្គាល់កម្មដែលគួរធ្វើដល់ព្រះអង្គបាន។ កាលទឹងគម្រាមព្រះបាទព្រហ្មទត្តហើយ ទើបពោលពីរគាថាដូច្នេះថា :

០៣. ជីវិតំ នូន តេ ចត្តំ   រដ្ឋំ វា មនុជាធិប

ន ហិ នាគេ កុប្បិតម្ហិ   ចិរំ ជីវន្តិ តាទិសា។

យោ ត្វំ ទេវ មនុស្សោសិ   ឥទ្ធិមន្តំ អនិទ្ធិមា

វរុណស្ស និយំ បុត្តំ   យាមុនំ អតិមញ្ញសិ។

បពិត្រព្រះអង្គជាធំជាងមនុស្ស ជីវិតក្តី ដែនក្តី ព្រះអង្គនឹងលះបង់ដោយពិត កាលបើនាគខឹងហើយ ព្រះរាជាទាំងឡាយប្រហែលនឹងព្រះអង្គមិនគង់ព្រះជន្មនៅយូរទេ។

បពិត្រព្រះសម្មតិទេព ព្រះអង្គណាជាមនុស្ស ព្រះអង្គនេះមិនមានឫទ្ធិ មើលងាយព្រះរាជាដែលមានឫទ្ធិ ជាកូនបង្កើតនៃព្រះបាទវរុណៈ ដែលកើតក្នុងទន្លេយមុនា។

លំដាប់នោះ ព្រះបាទព្រហ្មទត្តមានព្រះរាជឱង្ការពីរគាថាដូច្នេះថា :

០៤. ជាតិមញ្ញាមិ រាជានំ ធតរដ្ឋំ យសស្សិនំ
ធតរដ្ឋោ ហិ នាគានំ ពហូនមបិ ឥស្សរោ។
អហិ មហានុភាវោបិ ន មេ ធីតរមារហោ
ខត្តិយោ ច វិទេហានំ អភិជាតា សមុទ្ទជា។

យើងមិនមើលងាយព្រះបាទធតរដ្ឋៈដ៏មានយសទេ ព្រោះថាព្រះបាទធតរដ្ឋៈជាធំជាងនាគទាំងឡាយដ៏ច្រើនៗ ពស់ទុកជាមានអានុភាពច្រើន ក៏មិនសមគួរនឹងធីតារបស់យើងទេ ចំណែកខាងយើងជាក្សត្រិយ៍របស់អ្នកដែនវិទេហៈ ធីតារបស់យើងឈ្មោះសមុទ្ទជាមានជាតិដ៏ប្រសើរ។

ពួកនាគមាណពបានស្តាប់ដូច្នោះហើយ សូម្បីប្រាថ្នានឹងសម្លាប់ព្រះបាទព្រហ្មទត្តដោយខ្យល់ក្នុងច្រមុះ ក្នុងទីនោះឯងក៏បានទើបគិតថា សូម្បីកាលពួកយើងត្រូវព្រះរាជាបញ្ជូនមកដើម្បីកំណត់

ថ្ងៃ ការដែលយើងនឹងសម្លាប់ព្រះបាទព្រហ្មទត្តនេះហើយទៅ មិនសមគួរឡើយ ពួកយើងនឹងទៅក្រាបទូលព្រះរាជា ឲ្យបានជ្រាបៗ ដូច្នេះហើយពួកគេទើបក្រោកចាកអំពីទីនោះ ចេញចាកពីព្រះរាជ-និវេសន៍មុជចុះទៅកាន់ផែនដីក្នុងទីនោះឯង ត្រូវស្តេចនាគសួរថា ម្នាលបាទាំងឡាយ ពួកអ្នកបានរាជធីតាហើយឬ? ដូច្នេះហើយ ខឹងចំពោះព្រះរាជា ទើបក្រាបទូលថា បពិត្រព្រះសម្មតិទេព ព្រះអង្គបញ្ជូនពួកខ្ញុំព្រះអង្គទៅក្នុងទីណា ព្រោះហេតុមិនសមគួរអ្វីឡើយ បើព្រះអង្គប្រាថ្នានឹងសម្លាប់ខ្ញុំព្រះអង្គ ចូរសម្លាប់ពួកទូលព្រះបង្គំទៅចុះ ព្រះបាទព្រហ្មទត្តនោះ ដេរបរិកាសដល់ព្រះអង្គលើកធីតារបស់ខ្លួនឡើងដោយសេចក្តីស្រវឹងក្នុងជាតិ ដូច្នេះហើយក្រាបបង្គំទូលដល់សេចក្តីដែលព្រះអង្គពោល និងមិនបានពោលធ្វើសេចក្តីក្រោធឲ្យកើតឡើងដល់ព្រះរាជាធតរដ្ឋៈៗ ព្រះបាទធតរដ្ឋៈទ្រង់បង្គាប់ឲ្យប្រជុំបរិស័ទ ទើបមានព្រះរាជឱង្ការថា :

០៥. កាម្ពលស្សតរា ឧដ្ឋេន្តុ សព្វេ នាគេ និវេទយ

ពារាណសឹ បវជ្ជន្តុ មា ច កញ្ចិ វិហេឋយុំ។

ពួកនាគឈ្មោះកម្ពលស្សតរា ចូរក្រោកឡើង អ្នកចូរប្រាប់នាគទាំងអស់ថា នាគទាំងឡាយចូរទៅកាន់ក្រុងពារណសី តែកុំបៀតបៀនបុគ្គលណាមួយឡើយ។

លំដាប់នោះពួកនាគទើបពោលនឹងព្រះរាជាថា បពិត្រមហារាជ បើមិនបៀតបៀនពួកមនុស្សខ្លះទេ ពួកយើងនឹងទៅក្នុងទីនោះធ្វើអ្វី? លំដាប់នោះព្រះបាទធតរដ្ឋ: ទើបមានព្រះរាជឱង្ការនឹងពួកនាគនោះថា ពួកអ្នកចូរធ្វើវត្ថុនេះនឹងវត្ថុនេះ សូម្បីយើងក៏នឹងធ្វើវត្ថុឈ្មោះនេះដូច្នេះហើយ កាលនឹងមានព្រះរាជឱង្ការតបទើបត្រាស់ពីរគាថាដូច្នេះថា :

០៦. និវេសនេសុ សោព្ភេសុ រថិយា ចច្ចរេសុ ច
រុក្ខគ្គេសុ ច លម្ពន្តុ វិតតា តោរណេសុ ច។
អហម្បិ សព្ពសេតេន មហតា សុមហំ បុរំ
បរិក្ខិបិស្សំ ភោគេហិ កាសីនំ ជនយំ ភយំ។

នាគទាំងឡាយដែលមានសរីរៈធំ ចូរសំយុងខ្លួនក្នុងនិវេសនដ្ឋានទាំងឡាយក្នុងស្រះ ត្រង់ផ្លូវដើរ ក្នុងព្រះលានហ្លួងខ្លះ លើចុងឈើខ្លះ និងលើក្លោងទ្វារខ្លះៗ ចំណែកខាងខ្ញុំ(ធតរដ្ឋៈ) មានកាយធំសសុទ្ធ នឹងរុំព័ទ្ធបុរីដែលធំទូលាយ ដោយភ្នេនទាំងឡាយ ហើយញ៉ាំងភ័យឲ្យកើតឡើងដល់ពួកអ្នកដែនកាសី។

ព្រះសាស្តាកាលទ្រង់ប្រកាសសេចក្តីនោះ ទើបត្រាស់ថា :

០៧. តស្ស តំ វចនំ សុត្វា ឧរគានេកវណ្ណិនោ
ពារាណសឹ បវជ្ជឹសុ ន ច កញ្ចិ វិហេឋយុំ។
និវេសនេសុ សោព្ភេសុ រថិយា ចច្ចរេសុ ច
រុក្ខគ្គេសុ ច លម្ពឹសុ វិតតា តោរណេសុ ច។
ឃតេ ទិស្វាន លម្ពន្តេ ប្វច្វ កន្ទឹសុ នារិយោ
នាគេ សោណ្ឌិកតេ ទិស្វា បស្សសន្តេ មហុំ មហុំ។
ពារាណសី សព្យាធិតា អាតុរា សមបជ្ជថ
ពាហា បគ្គយ្ហ បក្កន្ទុំ ធីតរំ ទេហិ រាជិនោ។

នាគទាំងឡាយមានសម្បុរដ៏ច្រើន បានស្តាប់ពាក្យព្រះបាទធតរដ្ឋៈនោះហើយ ក៏ចូលទៅកាន់ក្រុងពារាណសី តែមិនបាន

បៀតបៀនបុគ្គលណាមួយឡើយ។ នាគទាំងឡាយដែលមាន សរីរៈធំ ក៏សំយុងខ្លួនក្នុងនិវេសនដ្ឋាន ក្នុងស្រះ ត្រង់ផ្លូវដើរ ក្នុងព្រះលាន លើចុងឈើ និងលើក្លោងទ្វារ។ នារីទាំងឡាយជាច្រើន បានឃើញនាគទាំងនុ៎ះ កំពុងសំយុងខ្លួន លុះឃើញពួកនាគបើកពពារ កំពុងឲ្យសម្លេងរៀយៗ ក៏កន្ទក់កន្ទេញ។ ពួកជនក្នុងក្រុងពារាណសីតក់ស្លុតក្តៅក្រហល់ក្រហាយ ក៏លើកដៃកន្ទក់កន្ទេញថា សូមព្រះអង្គប្រទានធីតាដល់នាគរាជទៅ។

ចំណែកនាគមាណពទាំង៤នាក់នោះ បានឈរនៅហាក់បីដូចយកមាត់ជន្ទ ចឹកសីសៈ ហើយពោលថា ចូរឲ្យៗ ព្រះអង្គទ្រង់ផ្ទំបានស្តាប់សម្លេងអ្នកនគរ និងមហេសីរបស់ព្រះអង្គយំរៀបរាប់ និងព្រះអង្គត្រូវបាននាគមាណពទាំង៤នោះគម្រាម ទ្រង់តក់ស្លុតព្រះរាជហឫទ័យអំពីមរណភ័យ ទើបបានត្រាស់ឡើង៣ដងថា យើងនឹងឲ្យនាងសមុទ្ទជា ជាធីតារបស់យើង ដល់ស្តេចធតរដ្ឋៈ។ នាគរាជទាំងអស់ កាលបានស្តាប់ព្រះតម្រាស់ដូច្នោះហើយ ក៏ត្រឡប់ទៅកាន់ទីប្រមាណ១គាវុត សាងនគរ១កន្លែងដូចទេវនគរ បាននៅក្នុងទីនោះ ទើបបញ្ជូនបណ្ណាការទៅ ជាដំណឹងថា សូមព្រះអង្គចូរបញ្ជូនព្រះរាជធីតា ព្រះរាជាយកគ្រឿងបណ្ណាការ ដែលពួក

នាគនាំមក ទើបបញ្ជូនពួកនាគទៅថា ពួកលោកទៅសិនចុះ យើងនឹងបញ្ជូនធីតាទៅ ដោយមានការការពារពីពួកអាមាត្យរបស់យើង ហើយត្រាស់បង្គាប់ឲ្យហៅធីតាមក ឲ្យឡើងកាន់ប្រាសាទជាន់លើ ឲ្យគេបើកសីហបញ្ជរ(បង្អួច) ហើយឲ្យសញ្ញាថា ម្នាលបុត្រីដ៏ចម្រើន កូនចូរមើលនគរដែលតាក់តែងហើយនេះចុះ កូនជាអគ្គមហេសីរបស់ព្រះរាជាអង្គនេះក្នុងទីនោះ នគរនោះនៅមិនឆ្ងាយអំពីទីនេះប៉ុន្មានទេ កាលបើកូនកើតនូវសេចក្តីអផ្សុកក្នុងនគរនោះ កូនអាចនឹងមកវិញបាន កូនគប្បីមកក្នុងទីនេះ ហើយឲ្យគេកក់សីសៈ ប្រដាប់ដោយគ្រឿងអលង្ការទាំងពួង ឲ្យអង្គុយខាងលើគ្រែស្នែងដែលបិទបាំងហើយ។ បានបញ្ជូនទៅក្នុងការឃុំគ្រងរបស់អាមាត្យនៃព្រះរាជា។ ស្តេចនាគទាំងឡាយធ្វើបដិសណ្ឋារៈព្រះរាជធីតាហើយ បានធ្វើមហាសក្ការៈដល់អាមាត្យទាំងឡាយ ចូលទៅកាន់ព្រះនគរថ្វាយព្រះធីតានោះដល់ស្តេចធតរដ្ឋៈ បានកាន់យកទ្រព្យជាច្រើន ហើយត្រឡប់មកវិញ។ ព្រះរាជធីតាឡើងកាន់លើប្រាសាទ ទ្រង់ផ្ទុំលើក្រឡាព្រះបន្ទំដ៏ជាទិព្វដែលគេប្រដាប់តាក់តែងទុកហើយ។ ក្នុងខណៈនោះឯង ពួកនាគមាណពប្រែភេទជាមនុស្សគម និងមនុស្សតឿជាដើម ឡោមព័ទ្ធព្រះរាជធីតា ដូចពួកបារិចារិការបស់

មនុស្សដែរ។ ព្រះរាជធីតាទ្រង់ផ្ទំលើទីសយនាដ៏ជាទិព្វ ពាល់ត្រូវសម្ផស្សដ៏ជាទិព្វតែប៉ុណ្ណោះ ក៏ឈានចុះកាន់ការលង់លក់ទៅ។ ព្រះបាទធតរដ្ឋៈ នាំព្រះធីតាព្រមទាំងបរិវារនាគ បាត់ក្នុងទីនោះ បានប្រាកដក្នុងពិភពនាគ។ ព្រះរាជធីតាតើនឡើង ទ្រង់ទតព្រះនេត្រឃើញផ្ទៃក្រឡាព្រះបន្ទំដ៏ជាទិព្វ ដែលគេតាក់តែងទុក និងទីដទៃទៀតដូចប្រាសាទ ដែលសម្រេចជាវិការៈនៃមាស និងសម្រេចជាវិការៈនៃកែវមណី។ ព្រះរាជឧទ្យាន និងស្រះបោក្ខរណីនៅភពនាគ ដូចទេវនគរដែលគេតាក់តែងទុកហើយ ទើបត្រាស់សួរស្រីបម្រើ មានស្រីគមជាដើមថា នគរនេះជាងតាក់តែងដ៏ប្រសើរ មិនដូចជានគររបស់យើងនោះទេ នគរនេះជានគររបស់អ្នកណា? ស្ត្រីអ្នកបម្រើក្រាបទូលថា បពិត្រព្រះទេវី នេះជានគរស្វាមីរបស់ព្រះនាងក្រាបទូល ឯខ្ញុំម្ចាស់ជាបុគ្គលដែលមានបុណ្យតិច រមែងមិនបានសម្បត្តិដូច្នេះទេ។ ព្រះនាងបានសម្បត្តិនេះ ព្រោះព្រះនាងមានបុណ្យច្រើន។ ចំណែកព្រះបាទធតរដ្ឋៈបង្គាប់ឲ្យគេវាយស្គរស្រែកប្រកាសទៅក្នុងពិភពនាគ ប្រមាណ៥០០យោជន៍ថា បុគ្គលណាៗសម្តែងភេទពស់ដល់ព្រះនាងសមុទ្ទជា បុគ្គលនោះៗ នឹងត្រូវព្រះរាជទណ្ឌ(ត្រូវទោស)។ ព្រោះហេតុនោះ ថាបុគ្គលណា

ហ៊ានដើម្បីនឹងសម្តែងភេទពស់ដល់ព្រះនាង សូម្បីតែម្នាក់ក៏គ្មានដែរ។ ព្រោះសេចក្តីសម្គាល់ថាជាមនុស្សលោក ព្រះនាងទើបរីករាយត្រេកអរនឹងព្រះបាទធតរដ្ឋៈនោះ ក្នុងទីនោះឯង។ នៅ រួមដោយសេចក្តីស្រឡាញ់ ដោយអាការៈយ៉ាងនេះ។



ចប់នគរកណ្ឌា

ចំណេរកាលតមកព្រះនាងទ្រង់អាស្រ័យព្រះបាទធតរដ្ឋៈ ទើបទ្រង់តាំងព្រះគភ៌ ហើយប្រសូតព្រះឱរសមួយព្រះអង្គ ពួកព្រះញាតិបានតាំងនាមថា សុទស្សនៈ ព្រោះឃើញហើយ ឲ្យកើតសេចក្ដីស្រឡាញ់ៗ ក្នុងពេលព្រះឱរសទ្រង់ដើរបាន ព្រះនាងប្រសូតព្រះឱរសមួយព្រះអង្គទៀត ពួកព្រះញាតិបានតាំងនាមថា ទត្តៈ គឺជាព្រះពោធិសត្វ។ ព្រះនាងប្រសូតព្រះឱរសមួយព្រះអង្គទៀត ពួកព្រះញាតិតាំងឈ្មោះថា សុភោគៈ ព្រះនាងប្រសូតព្រះឱរសមួយព្រះអង្គទៀត ពួកព្រះញាតិបានតាំងឈ្មោះថា អរិដ្ឋៈ។ ដូច្នោះព្រះនាង សុម្បីប្រសូតព្រះឱរស៤ព្រះអង្គហើយ ក៏មិនដឹងថាជាភពរបស់នាគឡើយ។ ថ្ងៃមួយ ពេលខាងក្រោយមកពួកនាគកំលោះៗប្រាប់ដល់ព្រះឱរសឈ្មោះអរិដ្ឋៈថា មាតារបស់ព្រះអង្គជាមនុស្សមិនមែនជានាងនាគទេ។ ព្រះឱរសឈ្មោះអរិដ្ឋៈគិតថាយើងនឹងល្បងលេងព្រះមាតានេះលមើល។ ថ្ងៃមួយកាលសោយទឹកដោះ ទើបនិមិត្តសរីរៈជាពស់យកកន្ទុយបាក់ខ្នងជើងព្រះមាតា។ ព្រះនាង

ឃើញរាងកាយជាពស់របស់ព្រះឱរសឈ្មោះអរិដ្ឋៈ ទើបតក់ស្លុតព្រះរាជហឫទ័យ ហើយស្រែកឡើងក៏បោះព្រះឱរសទៅលើផែនដី ក្អែករបស់ព្រះឱរសនោះក៏បែកហូរឈាម ព្រោះត្រូវនឹងក្រចក។ ព្រះរាជាទ្រង់ស្ដាប់សម្លេងរបស់ព្រះនាងហើយ ទើបត្រាស់សួរថា នោះជាសម្លេងស្រែករបស់អ្នកណា? ទ្រង់ព្រះសណ្ដាប់កិរិយាដែលព្រះឱរសឈ្មោះថាអរិដ្ឋៈធ្វើ ទើបស្ដេចពោលគម្រាមថា ពួកឯងចូរនាំអរិដ្ឋៈនេះយកទៅប្រហារជីវិតចោលភ្លាម។

ព្រះរាជធីតាទ្រង់ជ្រាបថា ព្រះរាជាទ្រង់ពិរោធ ទើបត្រាស់ដោយសេចក្ដីស្រឡាញ់ចំពោះបុត្រថា ក្អែកបុត្រារបស់នាងខ្ញុំម្ចាស់បែកហើយ សូមព្រះអង្គចូរលើកទោសឲ្យដល់បុត្ររបស់ខ្ញុំម្ចាស់ផងចុះ។ ព្រះរាជាកាលព្រះនាងទ្រង់ព្រះសុវណ្ណីយ៉ាងនោះ ទើបត្រាស់ថា យើងមិនអាចធ្វើអ្វីបាន ទើបលើកទោសឲ្យ។ ក៏ក្នុងថ្ងៃនោះឯងព្រះនាងបានជ្រាបថា នេះជាពិកពនាគ។ ចាប់តាំងពីនោះមក ព្រះឱរសឈ្មោះអរិដ្ឋៈ បានឈ្មោះថាព្រះអរិដ្ឋៈខ្វាក់។ ចំណែកព្រះឱរសទាំងពួនព្រះអង្គក៏ដឹងក្ដីហើយ។

លំដាប់នោះព្រះបិតារបស់ព្រះរាជឱរសទាំងនោះ បានទ្រង់ប្រទានរាជសម្បត្តិម្នាក់ៗ១០០យោជន៍ យសដ៏ធំបានកើតមានដល់ព្រះរាជបុត្រទាំងបួនព្រះអង្គ។ នាងនាគមាណវិកានាំគ្នាហែហមព្រះរាជបុត្រមួយព្រះអង្គៗ មាន១៦០០០នាក់ ព្រះបិតាមានរាជ-សម្បត្តិតែ១០០យោជន៍ប៉ុណ្ណោះ ព្រះឱរសទាំងបីព្រះអង្គមកដើម្បីគាល់ព្រះរាជមាតាបិតារៀងរាល់មួយខែម្តងៗ ចំណែកព្រះបរមពោធិសត្វ(ភូរិទត្ត) មករៀងរាល់កន្លះខែម្តង។ ព្រះពោធិសត្វបានពោលដល់បញ្ហាដែលកើតឡើងក្នុងពិភពនាគ ព្រមជាមួយនឹងព្រះបិតា ទើបទៅកាន់ទីឧបដ្ឋាករបស់ស្តេចវិរូបក្ខមហារាជ ព្រះអង្គបានពោលបញ្ហា ដែលកើតឡើងក្នុងសំណាក់របស់កពនាគនោះ។ ថ្ងៃមួយ ខាងក្រោយមក កាលស្តេចវិរូបក្ខមហារាជ ព្រមដោយនាគបរិវារទៅកាន់ត្រៃទសបុរី អង្គុយឡោមព័ទ្ធស្តេចសក្កទេវរាជលើកបញ្ហាឡើង ក្នុងចំណោមពួកទេពទាំងឡាយ អ្នកណាៗក៏មិនអាចដើម្បីនឹងដោះស្រាយបញ្ហានោះបានឡើយ ព្រះពោធិសត្វជាអ្នកអង្គុយនៅលើបល្ល័ង្កដ៏ប្រសើរប៉ុណ្ណោះ ទើបដោះស្រាយបញ្ហាបាន។

លំដាប់នោះទេវរាជទ្រង់បូជាព្រះបរមពោធិសត្វដោយគ្រឿងក្រអូប និងផ្កាកម្រងដ៏ជាទិព្វ ត្រាស់ថា ម្នាលទត្តៈ លោកប្រកបដោយបញ្ញាដ៏បរិបូណ៌ស្មើដោយផែនដី ចាប់តាំងពីពេលនេះតទៅលោកទើបបានឈ្មោះថា ភូរិទត្ត ព្រោះហេតុនោះទើបបានតាំងឈ្មោះលោកថា ភូរិទត្តៗ ចាប់តាំងអំពីនោះមក លោកបានទៅឧបដ្ឋាកសក្កទេវរាជ ឃើញវេជ្ជយន្តប្រាសាទដែលកម្មវិចិត្រហើយនិងសម្បត្តិរបស់ព្រះឥន្ទ្រាធិរាជ គួរជាទីមនោរម្យក្រៃពេកពាស-ពេញទៅដោយស្រីទេពអប្សរ ទើបធ្វើសេចក្តីប្រាថ្នាក្នុងទេវលោករួចគិតឡើងថា យើងនឹងមានប្រយោជន៍អ្វីចំពោះអត្តភាពនេះដោយមានកង្កែបជាអាហារៗ ហើយទៅកាន់ភពនាគរក្សាឧបោសថ និងធ្វើហេតុឲ្យកើតក្នុងទេវលោកនេះដូច្នេះហើយ ទើបត្រឡប់មកកាន់ពិភពនាគ ក្រាបបង្គំទូលលាព្រះមាតា និងព្រះបិតាថា ខ្ញុំព្រះអង្គនឹងរក្សាឧបោសថៗ ព្រះរាជមាតាបិតាទ្រង់មានព្រះរាជឱង្ការថាប្រពៃហើយបុត្រា ចូរធ្វើទៅចុះ កាលបុត្រានឹងធ្វើនូវឧបោសថកុំយាងចេញទៅខាងក្រៅឡើយ ចូរធ្វើតែក្នុងវិមានដ៏ស្ងាត់មួយកន្លែង

ក្នុងភពនាគនេះចុះ កាលពួកនាគទៅខាងក្រៅ ភ័យដ៏ធំរមែងកើតឡើងបាន។ ព្រះពោធិសត្វក្រាបបង្គំ ទទួលថាសាធុ... ហើយនៅរក្សាឧបោសថក្នុងព្រះរាជឧទ្យានក្នុងវិមានដ៏ស្ងាត់នោះឯង។ លំដាប់នោះនាងនាគម្នាក់ៗកាន់តន្ត្រីផ្សេងៗឡោមព័ទ្ធព្រះពោធិសត្វ ព្រះពោធិសត្វទ្រង់ព្រះតម្រិះថា កាលយើងនៅក្នុងទីនេះឧបោសថនឹងមិនដល់ទីបំផុតទេ យើងនឹងទៅកាន់ឋានមនុស្ស ធ្វើឧបោសថ។ ទ្រង់មិនបានប្រាប់ដល់ព្រះរាជមាតាបិតាឡើយ ព្រោះខ្លាចការហាមឃាត់ ទើបហៅភរិយាទាំងឡាយរបស់ខ្លួន មកពោលថា ម្នាលនាងដ៏ចម្រើន ខ្ញុំនឹងទៅកាន់មនុស្សលោកពត់ពែនលើដំបូកមួយមិនឆ្ងាយអំពីដើមជ្រៃធំ ដែលមាននៅត្រង់ច្រាំងទន្លេយមុនានោះទេ ហើយអធិដ្ឋានឧបោសថដែលប្រកបដោយអង្គបួន ដេកធ្វើឧបោសថកម្ម កាលយើងដេកធ្វើឧបោសថរហូតយប់ ញុំាងអរុណឲ្យរះឡើង ពួកអ្នកជាស្ត្រីកាន់តន្ត្រីម្តងៗ១០នាក់ ចូរផ្លាស់ប្តូរគ្នាទៅកាន់សម្នាក់របស់យើង បូជាយើងដោយគ្រឿងក្រអូប និងផ្កាកម្រង រាំច្រៀង ហើយត្រឡប់មកកាន់ពិភពនាគវិញចុះ។ ដូច្នេះ

ហើយក៏បានទៅកាន់ទីនោះ ពត់ភ្នែនខាងលើដំបូកមួយ ហើយ
អធិដ្ឋានឧបោសថដែលប្រកបដោយអង្គ៤ថា បុគ្គលណាប្រាថ្នា
ស្បែក ឆ្អឹង សរសៃ ឬឈាម បុគ្គលនោះចូរនាំយកទៅចុះ ហើយ
នេរមិត្តរាងកាយ ប្រមាណប៉ុនយាមនង្គ័ល ដេកធ្វើឧបោសថកម្ម
ល្មមពេលអរុណរះឡើង នាងនាគមាណវិកាមកបដិបត្តិពោធិសត្វ
តាមពាក្យទូន្មាននោះហើយ ទើបត្រឡប់ទៅកាន់ពិភពនាគវិញ។
ព្រះបរមពោធិសត្វធ្វើឧបោសថកម្មតាមទំនងនេះ អស់រយៈកាល
ដ៏យូរ។



ចប់ឧទោសជកណ្ឌ

ក្នុងកាលនោះមានព្រាហ្មណ៍នេសាទម្នាក់ អាស្រ័យនៅជិតទ្វារក្រុងពារាណសី ព្រមជាមួយនឹងកូនប្រុសឈ្មោះសោមទត្តទៅកាន់ព្រៃបានដាក់អន្ទាក់ គឺជង់ សម្លាប់ម្រឹគបានហើយរែកសាច់យកមកលក់ចិញ្ចឹមជីវិតរៀងរាល់ថ្ងៃៗ ថ្ងៃមួយព្រាហ្មណ៍នោះមិនបានអ្វីសោះឡើយ ដោយហោចទៅ សូម្បីត្រឹមតែសត្វទន្សោងមួយក៏គ្មានដែរ ទើបពោលថា ម្នាលបាសោមទត្ត បើយើងទៅដៃទទេៗមាតារបស់កូននឹងក្រោធខឹង យើងនឹងនាំសត្វត្រឹមតែមួយទៅឲ្យបាន ដូច្នេះហើយទើបបែរមុខតម្រង់ទៅផ្លូវដំបូកដែលព្រះពោធិសត្វកំពុងដេកសំងំនៅ ឃើញស្នាមជើងម្រឹគទាំងឡាយ ដែលចុះទៅផឹកទឹកក្នុងទន្លេយមុនា ទើបពោលថា ម្នាលកូនមាសឪពុកនេះជាផ្លូវម្រឹគប្រាកដណាស់ ចូរកូនថយចេញទៅ យើងនឹងបាញ់ម្រឹគដែលមកផឹកទឹក ដូច្នេះហើយទើបចាប់យកធ្នូ ឈរអែបក្បែរគល់ឈើមួយដើមរង់ចាំមើលម្រឹគៗ នៅពេលល្ងាចម្រឹគមួយមកដើម្បីផឹកទឹក ព្រាហ្មណ៍បាញ់ម្រឹគនោះៗ ម្រឹគមិនដួលចុះក្នុងទីនោះទេ តក់ស្លុតដោយកម្លាំងព្រួញមានឈាមហូរ បោលគេចចេញទៅបាត់

ចំណែកបិតា និងបុត្រនាំគ្នាដេញតាមម្រឹគនោះ ចាប់យកម្រឹគនោះក្នុងកន្លែងដែលវាដួលចុះហើយ ចេញអំពីព្រៃដល់ដើមជ្រៃមួយក្នុងពេលព្រះអាទិត្យអស្តង្គត ទើបប្រឹក្សាគ្នាថា ឥឡូវនេះយើងមិនអាចនឹងធ្វើដំណើរទៅមុខទៀតបានទេ យើងនឹងឈប់សម្រាកនៅក្នុងទីនេះឯងហើយ ដូច្នេះទើបយកម្រឹគទុកក្នុងទីដ៏សមគួរមួយក៏នាំគ្នាឡើងដើមឈើ ដេកនៅត្រង់ចន្លោះប្រគាបឈើ នៅពេលជិតភ្លឺព្រាហ្មណ៍ក៏ភ្ញាក់ឡើង ផ្ទៀងត្រចៀករង់ចាំស្តាប់សម្លេងម្រឹគស្រែកៗ ខណៈនោះនាងនាគមាណវិកាទាំងឡាយនាំគ្នាមកតាក់-តែងផ្កាឈើដើម្បីព្រះបរមពោធិសត្វ។ ព្រះពោធិសត្វប្រែរាងកាយអំពីពស់ និរមិត្តរូបរាងជាទិព្វប្រដាប់ដោយគ្រឿងអលង្ការទាំងពួងប្រថាប់អង្គុយលើអាសនៈផ្កាឈើ ដោយលីលាដូចសក្កទេវរាជ។ចំណែកនាង នាគមាណវិកាក៏បូជាព្រះបរមពោធិសត្វដោយគ្រឿងក្រអូប និងផ្កាឈើជាដើម រួចលេងតន្ត្រីជាទិព្វ ហើយចាប់ផ្តើមរាំច្រៀង ព្រាហ្មណ៍បានស្តាប់សម្លេងនោះហើយ ទើបគិតថា នោះជាអ្នកណាហ្ន៎ យើងនឹងស្គាល់សម្លេងនោះដូចម្តេចបាន? ហើយទើប

ពោលថា ម្នាលកូនដ៏ចម្រើន កាលមិនអាចដាស់កូនឲ្យភ្ញាក់ឡើងបាន ទើបគិតថា កូននេះប្រហែលជានឿយហត់ពេកណាស់ហើយ ចូរដេកទៅចុះ យើងនឹងទៅតែម្នាក់ឯងក៏បាន គិតហើយក៏ចុះអំពីដើមឈើចូលទៅរកព្រះបរមពោធិសត្វ។ ពួកនាងនាគមាណវិកាឃើញព្រាហ្មណ៍នោះហើយទើបមុជចុះទៅក្នុងផែនដី ព្រមដោយគ្រឿងតន្ត្រីត្រឡប់ទៅកាន់ពិភពនាគវិញ។ ចំណែកឯព្រះបរម-ពោធិសត្វបានអង្គុយនៅតែម្នាក់ឯងប៉ុណ្ណោះ។ ព្រាហ្មណ៍ឈរនៅក្នុងសម្នាក់ព្រះពោធិសត្វ កាលនឹងសាកសួរទើបបានពោលគាថាពីរគាថាដូច្នេះថា :

០៨. បុច្ឆាភិហារស្ស វនស្ស មជ្ឈេ
កោ លោហិតក្ខោ វិហតន្តរំសោ
កា កម្ពុកាយូរធរា សុវត្ថា
តិដ្ឋន្តិ នារិយោ ទស វន្ទមានា។
កោ ត្វំ ព្រហាពាហុ វនស្ស មជ្ឈេ
វិរោចសិ ឃតសិត្តោវ អគ្គិ

មហេសក្ខោ អញ្ញតរោសិ យក្ខោ
ឧទាហុ នាគោសិ មហានុភាវោ។

*អ្នកជាអ្វី មានភ្នែកក្រហម មានចង្កេះស្មាទូលាយ អង្គុយក្នុងកណ្តាលនៃព្រៃ ជាទីនាំមកបូជាដោយផ្កាឈើ ស្រីទាំងដប់នាក់ជាអ្វី? ដែលទ្រទ្រង់នូវសង្វារ ជាវិការៈនៃមាស មានសំពត់ដ៏ល្អកំពុងឈរសំពះ។ អ្នកជាអ្វី មានដៃ ធំរុងរឿងក្នុងកណ្តាលព្រៃដូចភ្លើងឆេះនូវថ្នាំងខ្លាញ់ អ្នកជាយក្ខណាមួយដែលមានសក្តិធំឬ ឬជានាគមានអានុភាពច្រើន។*

*ព្រះបរមពោធិសត្វបានស្តាប់ដូច្នេះហើយទើបត្រិះរិះថា បើយើងនឹងប្រាប់ថា យើងជាអ្នកណាមួយដែលមានឫទ្ធិ ក្នុងបណ្តាអ្នកមានឫទ្ធិ មានសក្កទេវរាជជាដើម។ ព្រាហ្មណ៍នេះគង់នឹងជឿពិតប្រាកដ ប៉ុន្តែថ្ងៃនេះ យើងគួរនឹងនិយាយសេចក្តីពិតតែម្យ៉ាងកាលនឹងប្រាប់ថាខ្លួនជាស្តេចនាគទើប ពោលគាថាដូច្នេះថា :*

០៩. នាគោហមស្មិ ឥទ្ធិមា តេជសី ទុរតិក្កមោ
ឌំសេយ្យំ តេជសា កុទ្ធោ ផីតំ ជនបទំ អបិ។

សមុទ្ទជា ហិ មេ មាតា ធតរដ្ឋោ ច មេ បិតា
សុទស្សនកនិដ្ឋោស្មិ ភូរិទត្តោតិ មំ វិទូ។

ខ្ញុំជានាគមានឫទ្ធិ មានតេជះដែលគេកន្លងមិនបាន ប្រសិនបើខ្ញុំក្រោធ អាចចឹកសូម្បីនូវអ្នកជនបទ ដែលបរិបូណ៌ដោយភោគៈដោយតេជះបាន។ ឯមាតារបស់ខ្ញុំឈ្មោះសមុទ្ទជា បិតារបស់ខ្ញុំឈ្មោះធតរដ្ឋៈ ខ្ញុំជាប្អូននៃនាគរាជឈ្មោះសុទស្សនៈ ជនទាំងឡាយស្គាល់ខ្ញុំថាភូរិទត្ត។ ព្រះបរមពោធិសត្វពោលយ៉ាងនេះហើយទើបគិតថា ព្រាហ្មណ៍នេះជាបុគ្គលអាក្រក់គ្រោតគ្រាតពេកណាស់ បើគេនឹងទៅប្រាប់ដល់ហ្មពស់ហើយ គប្បីធ្វើអន្តរាយដល់ឧបោសថកម្មរបស់យើងបាន យ៉ាងណាទេហ្ន៎? យើងនឹងនាំព្រាហ្មណ៍នេះទៅកាន់ពិភពនាគ គប្បីឲ្យយសដល់គាត់ឲ្យធំ ហើយយើងនឹងគប្បីធ្វើឧបោសថកម្មរបស់យើង ឲ្យយឺនយូរទៅថ្ងៃមុខបាន។



លំដាប់នោះ ព្រះបរមពោធិសត្វ ទើបពោលនឹងព្រាហ្មណ៍នោះយ៉ាងនេះថា ម្នាលព្រាហ្មណ៍ យើងនឹងប្រគល់យសដល់លោកឲ្យជាធំ នាគពិភពជាស្ថានទីដ៏សមគួរ ជាទីមនោរម្យក្រៃពេក មកទៅជាមួយគ្នាចុះ ហើយក៏ទៅក្នុងពិភពនាគនោះជាមួយគ្នា។ ព្រាហ្មណ៍ពោលថា បពិត្រនាគរាជ បុត្ររបស់ខ្ញុំមានម្នាក់ទៀត កាលបុត្រនោះមក ខ្ញុំនឹងទៅ។ លំដាប់នោះព្រះបរមពោធិសត្វ ទើបពោលនឹងព្រាហ្មណ៍នោះថា ម្នាលព្រាហ្មណ៍ លោកចូរទៅនាំបុត្ររបស់លោកមកចុះ កាលនឹងប្រាប់លំនៅរបស់ព្រះអង្គ ទើបពោលគាថា ដូច្នេះថា :

១០. យំ គម្ភីរំ សទាវដ្ដំ រហទំ ភេស្មំ បេក្ខសិ
ឃសោ និព្យោ មហាវាសោ អនេកសតចោរិសោ។
មយូរកោញ្ចាភិរុទំ នីលោទំ វនមជ្ឈតោ
យមុនំ បវិស មា ភិតោ ខេមំ វត្តវតី សិវំ។

លោករមែងឃើញអន្លង់ទឹកណាដ៏ជ្រៅ ដែលហូរគួចសព្វកាល ជាអន្លង់ទឹកគួរខ្លាច អន្លង់ទឹកនោះជាទិព្វ ជាលំនៅរបស់ខ្ញុំ មានជម្រៅច្រើនយោជន៍របស់។ អ្នកកុំខ្លាច ចូរចូលទៅកាន់ស្ទឹងយមុនាមានទឹកខៀវ ដែលហូរមកអំពីកណ្តាលព្រៃ ជាកន្លែងដែលក្ងោកនិងក្រៀលយំ ជាស្ទឹងត្រជាក់ក្សេមក្សាន្ត ជាលំនៅរបស់ពួកអ្នកមានវត្ត។ ឯព្រះបរមពោធិសត្វពោលយ៉ាងនេះហើយ ទើបពោលថា ទៅចុះព្រាហ្មណ៍ ទៅនាំកូននោះមក។ ព្រាហ្មណ៍ទើបទៅប្រាប់សេចក្តីនោះដល់កូន ហើយនាំកូននោះមក។ ព្រះបរមពោធិសត្វនាំព្រាហ្មណ៍ និងកូនទាំងពីរទៅកាន់ស្ទឹងយមុនា ឈរនៅត្រង់មាត់ច្រាំង ហើយទើបពោលថា :

១១. តត្ថ បត្តោ សានុចរោ សហ បុត្តេន ព្រាហ្មណ
បូជិតោ មយ្ហំ កាមេហិ សុខំ ព្រាហ្មណ វច្ឆសិ។

ម្នាលព្រាហ្មណ៍ អ្នកព្រមទាំងកូនមកដល់ភពនាគនោះហើយនឹងបានប្រពន្ធ ម្នាលព្រាហ្មណ៍ យើងនឹងបូជាអ្នកដោយកាមទាំងឡាយរបស់យើង អ្នកចូរនៅឲ្យសុខចុះ។ រីឯព្រះពោធិសត្វ

ពោលយ៉ាងនេះហើយ ទើបនាំបិតា និងបុត្រទាំងពីរនាក់ទៅកាន់ពិភពនាគដោយអានុភាពរបស់ខ្លួន។ កាលបិតា និងបុត្រទាំងពីរនាក់ទៅដល់ពិភពនាគហើយ អត្តភាពក៏ប្រាកដជាទិព្វ។ លំដាប់នោះព្រះបរមពោធិសត្វក៏ប្រគល់សម្បត្តិទិព្វឲ្យដល់បិតា និងកូនទាំងពីរនាក់នោះច្រើន និងបានឲ្យនាងនាគកញ្ញាម្នាក់ៗ៤០០នាក់។ ទាំងពីរនាក់ក៏បរិភោគសម្បត្តិធំនៅក្នុងពិភពនាគនោះ។

ចំណែកព្រះបរមពោធិសត្វមិនបានប្រមាទ ទៅបម្រើព្រះមាតា ព្រះបិតារៀងរាល់កន្លះខែម្ដង សម្ដែងធម្មកថាថ្វាយ តអំពីនោះមកក៏ទៅកាន់សម្នាក់របស់ព្រាហ្មណ៍សួរដល់ការមិនមានរោគហើយពោលថា លោកត្រូវការវត្ថុណា ក៏គប្បីប្រាប់ទៅចុះ កុំទើសទាល់អ្វីឡើយ ចូររីករាយជួប្រចុះ ហើយបានធ្វើបដិសណ្ឋារៈជាមួយសោមទត្ត រួចហើយទៅកាន់និវេសន៍របស់ព្រះអង្គវិញ។ ព្រាហ្មណ៍នៅពិភពនាគបានមួយឆ្នាំ ព្រោះហេតុដែលខ្លួនជាអ្នកមានបុណ្យតិច ក៏កើតការនឿយណាយ ប្រាថ្នានឹងទៅកាន់មនុស្សលោកវិញ ឃើញពិភពនាគប្រាកដដូចជាលោកន្តរនរក ប្រាសាទ

ដែលប្រដាប់ដ៏ល្អស្អាត ក៏ប្រាកដដូចជាពន្ធនាគារ នាងនាគកញ្ញា ដែលតាក់តែងស្អាតបាតហើយ ប្រាកដដូចជានាងយក្ខិនី ព្រាហ្មណ៍ ទើបគិតថា យើងនឿយណាយជាគ្រាដំបូងៗ យើងនឹងដឹងការគិត របស់សោមទត្តខ្លះ ដូច្នេះហើយទើបទៅកាន់សម្នាក់របស់សោមទត្ត ហើយសួរថា ម្នាលបាសោមទត្តកូននឿយណាយឬទេ? សោមទត្ត ឆ្លើយតបថា បពិត្របិតា តើឲ្យខ្ញុំនឿយណាយដោយហេតុអ្វី? ខ្ញុំ មិនធុញទ្រាន់ទេ ចុះបិតានឿយណាយឬ? ព្រាហ្មណ៍តបថា អើ យើងនឿយណាយខ្លាំងណាស់ៗ សោមទត្តសួរថា នឿយណាយ ព្រោះហេតុអ្វី? ព្រាហ្មណ៍ឆ្លើយថា ម្នាលកូនមាសឪពុក យើង នឿយណាយ ដោយមិនបានឃើញមាតា និងបងប្អូនរបស់កូនៗ បាសោមទត្តចូរមក ទៅជាមួយគ្នាចុះៗ សោមទត្តពោលថា ខ្ញុំមិន ទៅទេលោកឪពុក តែកាលបិតាអង្វរហើយអង្វរទៀត ក៏យល់-ព្រមៗ ព្រាហ្មណ៍គិតថា យើងបានសម្រេចចិត្តតាំងតែពីគ្រាដំបូង មកម្ល៉េះ ប៉ុន្តែបើនឹងប្រាប់ដល់ព្រះភូរិទត្ត ថាយើងនឿយណាយ

ព្រះភូរិទត្តនឹងឲ្យយសដល់យើងក្រៃលែងឡើងថែមទៀត។ កាលដូច្នេះ យើងក៏មិនបានទៅទេ យើងនឹងត្រូវពណ៌នា លើកតម្កើងសម្បត្តិរបស់ព្រះភូរិទត្តដោយឧបាយតែម្យ៉ាង ទើបសួរថា ដែលព្រះភូរិទត្តលះទ្រព្យសម្បត្តិរហូតត្រឹមប៉ុណ្ណោះ ទៅធ្វើឧបោសថកម្មក្នុងមនុស្សលោកនោះព្រោះហេតុណា? បើឆ្លើយថា ត្រូវការនឹងទៅកាន់ស្ថានសួគ៌ យើងក៏នឹងទូលឲ្យជ្រាបសេចក្ដីរបស់យើងថា សម្បត្តិមានដល់យ៉ាងនេះទៅហើយ លោកនៅលះបង់ទៅធ្វើឧបោសថកម្មដើម្បីត្រូវការនឹងទៅកាន់ស្ថានសួគ៌ ព្រោះហេតុអ្វីទៀតទៅ? មនុស្សដូចជាយើងនឹង មកចិញ្ចឹមជីវិតដោយសារទ្រព្យរបស់អ្នកដទៃ យើងនឹងទៅកាន់មនុស្សលោក សួរសុខទុក្ខញាតិសាច់សារលោហិត ហើយបួសបំពេញសមណធម៌ដូច្នេះ ព្រះភូរិទត្តគង់នឹងអនុញ្ញាតឲ្យទៅជាមិនខាន។ កាលព្រាហ្មណ៍គិតដូច្នេះហើយ ថ្ងៃមួយពេលតមកកាលព្រះពោធិសត្វមកសួរសុខទុក្ខនឹងសួរថានឿយណាយ ឬទេ? ក៏ឆ្លើយថាខ្ញុំនឹងនឿយណាយព្រោះ

ហេតុអ្វី? វត្ថុរបស់គ្រឿងបរិភោគ ដែលបានអំពីសម្នាក់របស់ព្រះអង្គមិនបានខ្វះខាតឡើយ សូម្បីតែបន្តិចបន្តួចក្នុងរយៈពេលនេះៗ ព្រាហ្មណ៍មិនបានសំដែងដល់រឿងដែលទាក់ទងដល់ការនឹងទៅ ចាប់តាំងអំពីដើមក៏ពោលពណ៌នាដល់សម្បត្តិរបស់ព្រះពោធិសត្វថា :

១២. សមា សមន្តបរិតោ បហុតតគរា មហី
ឥន្ទគោបកសញ្ឆន្នា សោភតិ ហរិតុត្តមា ។
រម្មានិ វនចេត្យានិ រម្មា ហំសុបកូជិតា
ឱបុប្ផបទុមា តិដ្ឋន្តិ ចោក្ខរញ្ញោ សុនិម្មិតា ។
អដ្ឋំសា សុកតា ថម្ភា សព្វេ វេឡុរិយាមយា
សហស្សថម្ភា បាសាទា បូរា កញ្ញាហិ ជោតរេ ។
វិមានំ ឧបបន្នោសិ ទិព្វំ បុញ្ញេហិ អត្តនោ
អសម្ពាធំ សិវំ រម្មំ អច្ចន្តសុខសញ្ហិតំ ។
មញ្ញេ សហស្សនេត្តស្ស វិមានំ នាភិកង្ខសិ
ឥទ្ធិ ហិត្វាយំ វិបុលា សក្កស្សេវ ជុតីមតោ ។

ផែនដីមានផ្ទៃរាបស្មើដោយជុំវិញ មានដើមក្រឹស្នាច្រើនដេរដាសដោយមេភ្លៀង មានស្មៅខៀវដ៏ឧត្តមល្អៗ ព្រៃជ្រឹគួរជាទីរីករាយ ស្រះបោក្ខរណីទាំងឡាយដែលជាបុញ្ញកម្មរបស់ព្រះអង្គនិម្មិតល្អហើយ ជាទីរីករាយដែលហង្សយំ ហើយមានផ្កាឈូកធ្លាក់ចុះៗ សសរមានជ្រុង៨ដែលគេធ្វើល្អហើយ ជាវិការៈនៃកែវពៃទូរ្យទាំងអស់ ប្រាសាទទាំងឡាយ មានសសរមួយពាន់ដ៏ពេញដោយនាងកញ្ញាក្ដឹរុងរឿងៗ ព្រះអង្គបានដល់នូវវិមានដ៏ជាទិព្វដោយបុណ្យរបស់ព្រះអង្គ ជាវិមានមិនចង្អៀត ជាទីក្សេមក្សាន្តគួររីករាយប្រកបដោយសេចក្តីសុខយ៉ាងក្រៃលែងៗ ខ្ញុំសម្គាល់ថាព្រះអង្គមិនប្រាថ្នាវិមានរបស់ព្រះឥន្ទ្រជាសហស្សនេត្តទេ ព្រោះថាឫទ្ធិរបស់ព្រះអង្គនេះដ៏ធំដូចជាឫទ្ធិនៃព្រះឥន្ទ្រដ៏រុងរឿងដែរៗ ព្រះបរមពោធិសត្វកាលបានស្តាប់ដូច្នោះហើយ ទើបពោលថា ម្នាលព្រាហ្មណ៍ លោកកុំនិយាយយ៉ាងនេះឡើយៗ យសសក្តិរបស់យើងដែលប្រៀបធៀបនឹងយសសក្តិរបស់ស្តេចសក្កទេវរាជនោះហើយ រាប់ថាទាបពេក ប្រាកដដូចគ្រាប់ស្ពៃជិតភ្នំសិនេរុ ពួកយើង

ក៏មានតម្លៃមិនដល់ សូម្បីដោយអ្នកបម្រើរបស់សក្កទេវរាជ ដូច្នេះ ហើយទើបពោលគាថាដូច្នេះថា :

១៣. មនសា បិ ន បត្តព្ពោ អានុភាវោ ជុតិមតោ
 បរិចារិយមានានំ ឥន្ទានំ វសវត្តិនំ ។

អានុភាពរបស់ព្រះឥន្ទ្រ អានុភាពរបស់លោកបាលទាំងបួន ញុំាងអំណាចឲ្យប្រព្រឹត្តទៅ ជាអ្នកបម្រើព្រះឥន្ទ្រក្តី អ្នកមិនគប្បីដឹងដោយចិត្តបានទេ។ សេចក្តីនៃពាក្យជាគាថានោះ មានដូច្នេះ ម្នាលព្រាហ្មណ៍អ្នកណាៗមិនគប្បីដល់ដោយចិត្ត គឺសូម្បីដោយចិត្តថា ឈ្មោះថាយសសក្តិរបស់សក្កទេវរាជ នឹងមានត្រឹមតែប៉ុណ្ណេះ គឺ ១- ២- ៣- ៤- ថ្ងៃប៉ុណ្ណោះ យសសក្តិរបស់សត្វតិរច្ឆាននៃយើង នៅមិនដល់ចម្រៀកទី១៦នៃយសសក្តិរបស់ស្តេចមហារាជទាំង៤ក្តី របស់ស្តេចលោកបាលទាំង៤ អ្នកបម្រើ ត្រាច់ធ្វើឲ្យជាអ្នកធំ អ្នកនាំក្តី។ កាលព្រះពោធិសត្វពោលយ៉ាងនេះហើយ ទើបពោលតទៅទៀតថា យើងបានឮលោកនិយាយថានេះជាវិមាន

របស់លោកអ្នកមានព្រះនេត្រទាំងពាន់ យើងក៏រំពឹកបាន ព្រោះថា យើងប្រាថ្នាវិជ្ជយន្តប្រាសាទ ទើបធ្វើឧបោសថកម្ម កាលនឹងប្រាប់សេចក្ដីប្រាថ្នារបស់ខ្លួនដល់ព្រាហ្មណ៍ ទើបពោលគាថា នេះថា :

១៨. តំ វិមានំ អភិជ្ឈាយ អមរានំ សុខេសិនំ
ឧបោសថំ ឧបវសន្តោ សេមិ វម្មិកមុទ្ធនិ។

ខ្ញុំប្រាថ្នាវិមាននោះរបស់ទេវតាទាំងឡាយ អ្នកស្វែងរកសេចក្ដីសុខ បានជារក្សាឧបោសថ ហើយដេកលើក្បាលដំបូក។ ព្រាហ្មណ៍កាលបានស្ដាប់ដូច្នោះហើយ ដល់នូវសេចក្ដីសោមនស្សថា ឥឡូវនេះយើងបានឱកាសហើយកាលនឹងលាទៅ ទើបពោលគាថាដូច្នេះថា :

១៩. អហញ្ច មិគមេសានោ សបុត្តោ ធាវិសី វនំ
តេ មំ មតំ វា ជីវំ វា នាភិវេទេន្តិ ញាតកា។
អាមន្តយេ ភូរិទត្តំ កាសិបុត្តំ យសស្សិនំ
តយា នោ សមនុញ្ញាតា អបិ បស្សេមុ ញាតកេ។

ឯខ្ញុំព្រមទាំងកូនស្នេងរកម្រឹគ បានចូលទៅកាន់ព្រៃ ញាតិទាំងនោះ មិនដឹងខ្ញុំថា ស្លាប់ ឬរស់ទេ។ ខ្ញុំសូមលាព្រះភូរិទត្ត ជាបុត្រព្រះរាជធីតាក្នុងដែនកាសី ព្រះអង្គមានយស។ យើងខ្ញុំបើព្រះអង្គព្រមអនុញ្ញាតហើយ គប្បីឃើញពួកញាតិ។ លំដាប់នោះព្រះពោធិសត្វពោលពីរគាថាដូច្នេះថា :

១៦. ឯសោ ហិ វត មេ ឆន្ទោ យំ វសេសិ មមន្តិកេ
ន ហិ ឯតាទិសា កាមា សុលភា ហោន្តិ មានុសេ។
សចេ ត្វំ និច្ឆសេ វត្ថុំ មម កាមេហិ បូជិតោ
មយា ត្វំ សមនុញ្ញាតោ សោត្ថិ បស្សាហិ ញាតកេ។

ឱន៎ុះពិតជាសេចក្តីពេញចិត្តរបស់ខ្ញុំហើយ ត្រង់ដែលអ្នកនៅក្នុងសំណាក់របស់ខ្ញុំ ព្រោះថាកាមទាំងឡាយប្រាកដដូច្នេះ អ្នកមិនងាយបានក្នុងពួកមនុស្សទេ។ អ្នកដែលខ្ញុំបូជាដោយកាមទាំងឡាយរបស់ខ្ញុំ បើមិនចង់នៅទេ ខ្ញុំនឹងអនុញ្ញាតអ្នក សូមអ្នកទៅជួបពួកញាតិដោយសួស្តីចុះ។

លំដាប់នោះព្រះបរមពោធិសត្វ កាលពោលពីរគាថាហើយ ទើបគិតថា ព្រាហ្មណ៍នេះកាលបានអាស្រ័យនឹងយើងចិញ្ចឹមជីវិតជាសុខហើយ គង់នឹងមិនប្រាប់ដល់អ្នកណាៗ យើងនឹងឲ្យកែវមណីដែលឲ្យសេចក្ដីប្រាថ្នាគ្រប់យ៉ាងដល់ព្រាហ្មណ៍នេះ។ លំដាប់នោះកាលនឹងឲ្យកែវមណីដល់ព្រាហ្មណ៍នោះទើប ពោលថា :

១៧. ធារយិមំ មណឹ ទិព្វំ បសុំ បុត្តេ ច វិន្ទសិ
អារោគោ សុខិតោ ហោហិ គច្ឆេវាទាយ ព្រាហ្មណ។

អ្នកកាលទ្រទ្រង់កែវមណីជាទិព្វនេះ រមែងបានសត្វចិញ្ចឹមនិងបុត្រ អ្នកចូរមិនមានរោគ បានសេចក្ដីសុខ។ ម្នាលព្រាហ្មណ៍ អ្នកចូរយក(នូវកែវមណីនេះ) ហើយទៅចុះ។ លំដាប់នោះព្រាហ្មណ៍ទើបពោលគាថាដូច្នេះថា :

១៨. កុសលំ បដិនន្ទាមិ ភូរិទត្ត វចោ តវ
បព្វជិស្សាមិ ជិណ្ណោស្មិ ន កាមេ អភិបត្ថយេ។

បពិត្រព្រះភូរិទត្ត ស្រួលហើយ ខ្ញុំត្រេកអរនឹងព្រះបន្ទូលរបស់ព្រះអង្គ ខ្ញុំនឹងបួស ព្រោះខ្ញុំចាស់ហើយ ខ្ញុំមិនប្រាថ្នាកាមទេ។ ព្រះបរមពោធិសត្វទើប ពោលថា :

១៩. ព្រហ្មចរិយស្ស ចេ ភង្គោ ហោតិ ភោគេហិ ការិយំ
អវិកប្បមានោ ឯយ្យាសិ ពហុំ ទស្សាមិ តេ ធនំ។

*បើមានការបែកធ្លាយព្រហ្មចរិយៈ កិច្ចការដែលត្រូវធ្វើដោយភោគៈទាំងឡាយ រមែងមាន អ្នកកុំមានសេចក្ដីរង្កៀសឡើយ គប្បីមក យើងនឹងឲ្យទ្រព្យដ៏ច្រើនដល់អ្នក។ ព្រាហ្មណ៍ពោលថា :*

២០. កុសលំ បដិនន្ទាមិ ភូរិទត្ត វចោ តវ
បុនបិ អាគមិស្សាមិ សចេ អត្ថោ ភវិស្សតិ។

*បពិត្រព្រះភូរិទត្ត ស្រួលហើយ ខ្ញុំត្រេកអរនឹងព្រះបន្ទូលរបស់ព្រះអង្គ ប្រសិនបើមានសេចក្ដីត្រូវការ ខ្ញុំនឹងមកម្ដងទៀត។ ព្រះបរមសាស្ដាកាលទ្រង់ប្រកាសសេចក្ដីនោះ ទើបត្រាស់ថា :*

២១. ឥទំ វត្វា ភូរិទត្តោ បេសេសិ ចតុរោ ជនេ
ឯថ គច្ឆថ ឧដ្ឋេថ ខិប្បំ ចាបេថ ព្រាហ្មណំ។
តស្ស តំ វចនំ សុត្វា ឧដ្ឋាយ ចតុរោ ជនា
បេសិតា ភូរិទត្តេន ខិប្បំ ចាបេសុ ព្រាហ្មណំ។

ព្រះភូរិទត្តលុះពោលពាក្យនេះហើយ ក៏បញ្ជូននូវនាគទាំង៤ថា អ្នកទាំងឡាយមកនេះ ចូរទៅ ចូរក្រោកឡើង ចូរញ៉ាំងព្រាហ្មណ៍ឲ្យដល់នូវផ្លូវជាទីទៅកាន់ក្រុងពារាណសីជាឆាប់ៗ នាគទាំង៤ត្រូវព្រះភូរិទត្តប្រើទៅហើយ បានស្តាប់ពាក្យនោះ របស់ភូរិទត្តនោះ ក៏ក្រោកឡើង ហើយបានញ៉ាំងព្រាហ្មណ៍ឲ្យដល់យ៉ាងឆាប់ៗ

ចំណែកព្រាហ្មណ៍ កាលប្រាប់ដល់បុត្រថា ម្នាលបាសោមទត្ត យើងបាញ់ម្រឹគក្នុងទីនេះ ជ្រូកក្នុងទីនេះ ដូច្នេះហើយទើបដើរទៅឃើញស្រះបោក្ខរណីត្រង់ចន្លោះផ្លូវ ហើយពោលថា នែ៎សោមទត្ត យើងងូតទឹកជាមួយគ្នាចុះ កាលសោមទត្តពោលថា ប្រពៃហើយបិតាៗ អ្នកទាំងពីរនាក់ គឺឪពុក និងកូនទើបដោះគ្រឿងអាភរណៈដ៏ជាទិព្វ និងសំពត់ទិព្វ ហើយខ្ចប់ទុកមាត់ប្រាំងស្រះបោក្ខរណីរួចចុះទៅងូតទឹកៗ ខណៈនោះគ្រឿងអាភរណៈ និងសំពត់ទិព្វទាំងនោះបានបាត់ទៅកាន់ពិភពនាគវិញ សំពត់ស្លៀកដណ្តប់ផ្ទាំងចាស់ៗ ត្រឡប់មកពាក់ក្នុងរាងកាយរបស់មនុស្សទាំងពីរនាក់នោះដូចកាលពីមុន សូម្បីធ្នូ ព្រួញ និងលំពែង បានប្រាកដដូចកាលពី

ដើម។ ចំណែកសោមទត្តស្រែកថា បិតាធ្វើយើងឲ្យវិនាសហើយ។ លំដាប់នោះបិតាទើបលួងលោមកូនថា កុំវិតក្កៈទៅឡើយ កូនមាសឪពុក កាលម្រឹគមាន យើងសម្លាប់ម្រឹគក្នុងព្រៃចិញ្ចឹមជីវិតចុះ។ មាតាសោមទត្តជ្រាបការមកដល់របស់អ្នកទាំងពីរទើបធ្វើបដិសណ្ឋារៈនាំទៅកាន់ផ្ទះ រៀបចំបាយទឹក ឲ្យបរិភោគឆ្អែតនាំទៅសម្រាក។ ព្រាហ្មណ៍បរិភោគអាហារស្រេចហើយក៏ដេកលង់លក់ទៅ។ ចំណែកមាតាទើបសួរបុត្រថា បាសោមទត្ត អ្នកទាំងពីរនាក់បាត់ទៅណាយូរម្ល៉េះ? សោមទត្តឆ្លើយថា បពិត្រអ្នកម្ដាយព្រះភូរិទត្តនាគរាជបាននាំខ្ញុំ និងបិតាទៅកាន់ពិភពនាគ ព្រោះហេតុនោះ យើងទាំងពីរនាក់គិតដល់អ្នកម្ដាយ ឥឡូវនេះទើបត្រឡប់មកវិញ។ មាតាសួរថា តើបានកែវអ្វីៗមកខ្លះទេ? សោមទត្តឆ្លើយថា មិនបានយកមកទេអ្នកម្ដាយ មាតាសួរថា ហេតុអ្វីព្រះភូរិទត្តមិនឲ្យអ្វីខ្លះទេឬ? សោមទត្តឆ្លើយថា ព្រះភូរិទត្តបានឲ្យកែវមណីដល់បិតា តែបិតាមិនទទួលយកមកទេ មាតាសួរថា ហេតុអ្វីបិតាកូនទើបមិនទទួលយក? សោមទត្តឆ្លើយថា បពិត្រអ្នកម្ដាយ

បានឮថា បិតានឹងបួស។ នាងព្រាហ្មណីនោះក្រោធខឹងថា បិតាបោះបង់ចោលទារកឲ្យជាភារៈដល់យើង រហូតអស់កាលមានប្រមាណប៉ុណ្ណេះ ទៅនៅក្នុងពិភពនាគ ដំណឹងថាឥឡូវនេះនឹងបួសទៀត។ ដូច្នេះហើយ ទើបវាយខ្នងព្រាហ្មណ៍ដោយប៉ែលចូកដី ជះទឹកបាយហើយពោល គម្រាមថា នែ៎! អាតាព្រាហ្មណ៍គម្រក់ ឮថានឹងបួសភូរិទត្តឲ្យកែវមណី ក៏មិនព្រមទទួលយក ហេតុអ្វីក៏មិនបួសទៅត្រឡប់មកទីនេះធ្វើអីទៀត ចូរប្រញាប់ចេញទៅឲ្យផុតពីផ្ទះយើង។

លំដាប់នោះព្រាហ្មណ៍ ទើបលួងលោមនាងព្រាហ្មណីថា នាងកុំក្រោធខឹងនឹងបងអី កាលម្រឹគក្នុងព្រៃនៅមាន បងនឹងទៅសម្លាប់មកចិញ្ចឹមអូន ដូច្នេះហើយក៏ទៅអំពីទីនោះ ទៅកាន់ព្រៃព្រមជាមួយនឹងកូន រកចិញ្ចឹមជីវិតដោយទំនងដូចកាលពីមុនទៀត។



ចប់ព្រាហ្មណ៍នេសាទកណ្ឌ

ក្នុងកាលនោះមានគ្រុឌមួយនៅត្រង់ដើមរកា ផ្លូវមហាសមុទ្រ ភាគខាងត្បូង ទទះស្លាបញែកទឹកក្នុងមហាសមុទ្រ ចុះទៅចាប់ក្បាលនាគរាជបានមួយៗ ពិតមែនក្នុងកាលនោះ គ្រុឌទាំងឡាយនៅមិនទាន់ស្គាល់វិធីចាប់នាគទេ គ្រាខាងក្រោយមក ទើបស្គាល់វិធីចាប់នាគបាន ដូចក្នុងបណ្ឌរកជាតក ប៉ុន្តែគ្រុឌនោះ កាលចាប់នាគខាងក្បាល ទឹកនឹងលិចមកដល់ នៅមិនទាន់ ក៏ព្យួរនាគឡើងបានបណ្ដោយឲ្យនាគសំយ៉ុងកន្ទុយចុះ នាំហើរទៅខាងលើព្រៃហេមពាន្តៗ ក៏ក្នុងកាលនោះ មានព្រាហ្មណ៍អ្នកកាសិករដ្ឋម្នាក់ចេញបួសជាឥសីសាងបណ្ណសាលា អាស្រ័យនៅក្នុងហេមវន្ត-ប្រទេស (ព្រៃហេមពាន្ត)ៗ ខាងចុងបំផុតនៃទីចង្ក្រមរបស់ឥសីនោះមានដើមជ្រៃធំមួយ ឥសីនោះធ្វើទីសម្រាកពេលថ្ងៃត្រង់គល់ដើមជ្រៃនោះ គ្រុឌសំយ៉ុងនាគចូងហើរកាត់ទៅដល់ត្រង់ចុងនៃដើមជ្រៃៗ នាគពន្លៃងកន្ទុយ សំយ៉ុងចុះ ក៏យកកន្ទុយរុំព័ទ្ធដើមជ្រៃដោយសម្គាល់ថានឹងឲ្យរួចខ្លួន គ្រុឌមិនដឹងក៏ប្រញាប់ទៅតាមផ្លូវអាកាសព្រោះវាមានកម្លាំងច្រើនៗ ដើមជ្រៃព្រមទាំងឫស ជាប់

កន្ទុយនាគទៅផង កាលគ្រុឌនាំនាគទៅដល់ដើមរកា ក៏ចឹកដោយចំពុះ ហែកពោះនាគស៊ីខ្លាញ់រាវរបស់នាគ បោះចោលរាងកាយទៅក្នុងផ្ទៃមហាសមុទ្រ ដើមជ្រៃក៏ធ្លាក់ចុះឮសម្លេងខ្លាំងញាប់ញ័រ គ្រុឌសង្ស័យថាសម្លេងអ្វី ក៏សម្លឹងមើលចុះក្រោមឃើញដើមជ្រៃ ទើបគិតក្នុងចិត្តថា ដើមជ្រៃនេះយើងដកមកអំពីទីណាហ្ន៎? ក៏នឹកបានយ៉ាងច្បាស់ថា ដើមជ្រៃនោះនៅខាងចុងទីចង្ក្រមរបស់ព្រះតាបសមួយរូប។ ខ្លួនយើងនឹងប្រាកដថាធ្វើអកុសល ឬមិនធ្វើទេហ្ន៎? យើងនឹងទៅសាកសួរព្រះតាបសនោះលមើលក៏នឹងដឹងបាន។ ដូច្នេះហើយ ក៏ក្លែងភេទជាមនុស្សតូចម្នាក់ ទៅកាន់សម្នាក់ព្រះតាបស។ ក្នុងខណៈនោះតាបសកំពុងធ្វើទីនោះឲ្យរាបស្មើ ស្តេចគ្រុឌសំពះតាបសហើយក៏អង្គុយក្នុងទីដ៏សមគួរ ធ្វើហាក់បីដូចជាមិនដឹងអ្វីសោះ ក៏ក្លែងសួរថា បពិត្រលោកម្ចាស់ដ៏ចម្រើន ទីត្រង់នេះពីដើមជាកន្លែងអ្វី? តាបសឆ្លើយថា ម្នាលអ្នកមានអាយុ មានសុបណ្ណ(គ្រុឌ) មួយនាំនាគដើម្បីធ្វើជាអាហារ កាលនាគយកកន្ទុយរុំព័ទ្ធប្រគៀបដើមជ្រៃ ដោយសម្គាល់ថានឹងឲ្យរួចខ្លួន។ សុបណ្ណ

នោះមិនដឹងក៏ហើរទៅដោយរហ័ស ព្រោះភាវៈដែលខ្លួនមានកម្លាំង ច្រើន កាលដូច្នេះដើមឈើក្នុងទីនេះក៏ត្រូវដកឡើងភ្លាម ទីត្រង់នេះ ឯងជាទីនៃដើមជ្រៃដែលដកឡើងនោះ។ សុបណ្ណសួរថា បពិត្រលោក ម្ចាស់ដ៏ចម្រើន អកុសលកម្មនឹងមានដល់សុបណ្ណនោះដែរឬទេ? តាបសឆ្លើយថា ប្រសិនបើសុបណ្ណនោះមិនដឹង អកុសលកម្មក៏មិន មានឡើយ ព្រោះគ្មានចេតនា។ សុបណ្ណសួរថា ក៏អកុសលកម្មនឹង មានដល់នាគនោះ ឬក៏មិនមានទេ? តាបសឆ្លើយថា នាគក៏មិនបាន ចាប់ទុកដើម្បីនឹងឲ្យដើមជ្រៃនោះវិនាសទេ ចាប់តោងទុកដើម្បីនឹង ឲ្យរួចចាកភ័យតែប៉ុណ្ណោះ ព្រោះហេតុនោះអកុសលកម្ម ក៏មិនមាន ដល់នាគនោះដូចគ្នា។ សុបណ្ណបានស្ដាប់ពាក្យតាបសក៏ត្រេកអរ ទើបពោលថា បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំនេះឯងហើយ គឺ សុបណ្ណនោះ ខ្ញុំត្រេកអរដោយលោកម្ចាស់ដោះស្រាយបញ្ហា។ ខ្ញុំ ចេះមន្តឈ្មោះថា អាលម្ពាយន៍ មួយបទតម្លៃកាត់ថ្លៃមិនបានខ្ញុំនឹង ថ្វាយមន្តនោះដល់លោកម្ចាស់ឲ្យជាចំណែកបូជាអាចារ្យ លោក ម្ចាស់ចូរទទួលយកទុកចុះ។ តាបសពោលថា មិនអីទេសុបណ្ណ

យើងមិនត្រូវការដោយមន្តនោះទេ អ្នកចូរទៅចុះ សុបណ្ណអង្វរករ រឿយៗ រហូតទាល់តែតាបសព្រមទទួលយក ទើបថ្វាយមន្ត ហើយប្រាប់ថ្នាំដល់តាបស រួចក៏គេចចេញទៅវិញ។



ចប់សុបណ្ណកណ្ឌ

ក្នុងកាលនោះមានព្រាហ្មណ៍ម្នាក់ក្នុងក្រុងពារាណសីជំពាក់បំណុលគេច្រើនពេក ត្រូវម្ចាស់បំណុលទាំងឡាយទារ ក៏គិតថា យើងនឹងនៅក្នុងក្រុងនេះធ្វើអ្វីទៀត យើងនឹងចូលទៅឲ្យស្លាប់នៅក្នុងព្រៃវាប្រសើរជាង ដូច្នេះហើយទើប ចេញអំពីស្រុកចូលទៅក្នុងព្រៃ ទើបទៅដល់អាស្រមឥសី បដិបត្តិតាបសឲ្យត្រេកអរដោយវត្តសម្បទាគុណ។ ព្រះតាបសគិតថា ព្រាហ្មណ៍នេះជាអ្នកមានឧបការៈដល់យើងក្រៃពេក យើងនឹងឲ្យទិព្វមន្តដែលសុបណ្ណរាជឲ្យយើងទុកដល់ព្រាហ្មណ៍នេះ ដូច្នេះហើយ ក៏ប្រាប់ព្រាហ្មណ៍ថា ម្នាលព្រាហ្មណ៍ យើងចេះមន្តឈ្មោះថា អាលម្ពាយន៍ នឹងឲ្យមន្តនោះដល់អ្នក ចូរអ្នករៀនយកមន្តនោះទុកចុះ សូម្បីកាលព្រាហ្មណ៍នោះហាមឃាត់ថា កុំឡើយ ខ្ញុំមិនត្រូវការមន្តទេ។ ព្រះតាបសក៏អង្វរហើយអង្វរទៀត រហូតដ៏រាបដល់ព្រាហ្មណ៍ទទួលពាក្យសម្តី ហើយទើបឲ្យមន្ត នឹងប្រាប់ថ្នាំដែលប្រកបជាមួយនឹងមន្ត និងឧបចារៈនៃមន្ត ព្រាហ្មណ៍នោះគិតថា យើងនឹងបានឧបាយដើម្បីចិញ្ចឹមជីវិតហើយ ក៏សម្រាកនៅ២-៣ថ្ងៃ ដោយអាងហេតុថា

រោគខ្យល់ចាប់មកបៀតបៀន ដ៏រាបតាបសយល់ព្រមឲ្យទៅ ទើបក្រាបថ្វាយបង្គំព្រះតាបស សុំខមាទោសលោក ហើយក៏ចេញអំពីព្រៃទៅរហូតដល់ប្រាំងស្ទឹងយមុនាដោយលំដាប់ ដើរស្វាធ្យាយមន្តនោះទៅតាមផ្លូវធំៗ

ខណៈនោះនាងនាគមាណវិកាជាកិរិយារបស់ភូរិទត្តប្រមាណ ១០០០នាក់ ម្នាក់ៗកាន់យកកែវមណីដែលឲ្យសម្រេចសេចក្តីប្រាថ្នាគ្រប់យ៉ាងនោះចេញអំពីពិភពនាគ ហើយដាក់កែវនោះលើគំនរខ្សាច់នៃមាត់ប្រាំងស្ទឹងយមុនា រួចក៏នាំគ្នាលេងទឹករហូតដល់ទល់ពេលយប់ដោយពន្លឺនៃកែវមណីនោះ។ គ្រាព្រះអាទិត្យរះឡើងទើបនាំគ្នាតាក់តែងកាយដោយគ្រឿងអាភរណៈទាំងពួង អង្គុយឡោមព័ទ្ធកែវមណី ឲ្យសិរីចូលកាន់កាយ។ ចំណែកព្រាហ្មណ៍ក៏ដើរស្វាធ្យាយមន្តមកដល់ទីនោះ ពួកនាងនាគមាណវិកាបានឮសម្លេងមន្តសម្គាល់ថាសម្លេងព្រាហ្មណ៍នោះជាគ្រុឌ ក៏តក់ស្លុតរន្ធត់ខ្លាចព្រោះមរណ-ភ័យ មិនទាន់បានចាប់យកកែវមណីក៏ នាំគ្នាជ្រែកផែនដី ទៅកាន់ពិភពនាគ។ ព្រាហ្មណ៍ឃើញកែវមណីក៏រីករាយចិត្តថា មន្តរបស់

យើងសម្រេចផលឥឡូវនេះហើយ ក៏ចាប់យកកែវមណីនោះទៅ។

ខណៈនោះព្រាហ្មណ៍នេសាទ ព្រមជាមួយសោមទត្តជាកូន ចូលទៅកាន់ព្រៃ ដើម្បីបរបាញ់សត្វឃើញកែវមណីនោះនៅក្នុងដៃរបស់ព្រាហ្មណ៍ ទើបពោលនឹងកូនថា ម្នាលសោមទត្តកូនកែវមណីនេះដែលកូរិទត្តឲ្យដល់យើងមិនមែនឬ? សោមទត្តឆ្លើយថា មែនហើយលោកឪពុក។ បិតានិយាយថា បើដូច្នោះយើងនឹងពោលទោសកែវមណីនោះបោកបញ្ឆោតព្រាហ្មណ៍ យកកែវមណីនេះឲ្យបាន សោមទត្តនិយាយថា បពិត្របិតា កាលព្រះកូរិទត្តឲ្យក្នុងពេលមុន ហេតុដូចម្ដេចក៏បិតាមិនព្រមទទួលយក? តែឥឡូវនេះត្រឡប់ជាទៅបោកបញ្ឆោតព្រាហ្មណ៍នោះទៅវិញ ហើយក៏នៅស្ងៀម។ ព្រាហ្មណ៍នេសាទទើបពោលថា រឿងនោះ ចូរលើកទុកសិនចុះ កូនចាំមើលយើងបោកបញ្ឆោតតាព្រាហ្មណ៍នោះសិនពោលហើយ កាលនឹងប្រាស្រ័យជាមួយនឹងអាលម្ពាយន៍ ទើបពោលថា :

២២. មណឹ បគ្គយ្ហ មង្គល្យំ សាធុ វិត្តំ មនោរមំ
សេលំ ព្យញ្ជនសម្បន្នំ កោ ឥមំ មណិមជ្ឈគា។

អ្នកកាន់យកកែវមណីជាមង្គលជាទ្រព្យដ៏ប្រសើរជាទីរីករាយនៃចិត្ត ជាថ្មបរិបូណ៌ដោយទ្រង់ទ្រាយ អ្នកបានកែវមណីនេះអំពីទីណា?

លំដាប់នោះអាលម្ពាយន៍ពោលគាថាដូច្នេះថា :

២៣. លោហិតក្ខិសហាស្សាហិ សមន្តា បរិវារិតំ
អជ្ជ កាលំ បថំ គច្ឆំ អជ្ឈគាហំ មណឹ ឥមំ។

ថ្ងៃនេះខ្ញុំទៅកាន់ផ្លូវពីព្រឹកបានកែវមណីនេះ ដែលពួកនាងនាគភ្នែកក្រហម មួយពាន់ថែរក្សាហើយ។

ព្រាហ្មណ៍នេសាទ ប្រាថ្នានឹងបោកបញ្ឆោតអាលម្ពាយន៍ព្រាហ្មណ៍នោះទើបប្រកាសទោសនៃកែវមណី ប្រាថ្នានឹងកាន់យកជារបស់ខ្លួន ទើបពោលគាថាដូច្នេះថា :

២៤. សុចិណ្ណោ អយំ សេលោ អច្ចិតោ មហិតោ សទា
សុធារិតោ សុនិក្ខិត្តោ សព្វត្ថមភិសាធយេ។
ឧបចារវិបន្នស្ស និក្ខេបេ ធារណាយ វា
អយំ សេលោ វធាសាយ បរិចិណ្ណោ អយោនិសោ។
នយិមំ អកុសលោ និព្វំ មណឹ ធារេតុមារហោ

បដិបជ្ជ សតំ និក្ខំ      នេហិមំ រតនំ មម។

កែវមណីនេះ បើបុគ្គលសន្សំទុកល្អ ថែទាំ បូជាគ្រប់គ្រងល្អ ទុកដាក់ល្អហើយសព្វកាល  គប្បីញ៉ាំងប្រយោជន៍ទាំងពួងឲ្យសម្រេចបាន។ តែកាលបើបុគ្គលជាអ្នកប្រាសចាកការថែទាំក្នុងការទុកដាក់ ឬក្នុងការប្រើប្រាស់វិញ កែវមណីនេះដែលគេសន្សំទុកដោយមិនត្រូវទំនង នឹងដល់នូវសេចក្តីវិនាស។ អ្នកជាបុគ្គលមិនឈ្លាស មិនគួរគ្រប់គ្រងកែវមណីជាទិព្វនេះទេ អ្នកចូរគ្រប់គ្រងមាសឆ្តោរមួយរយចុះ ចូរឲ្យកែវមណីនេះដល់ខ្ញុំ។

លំដាប់នោះអាលម្ពាយន៍ពោលគាថាដូច្នេះថា :

២៥.នេវ មាយំ មណិ កេយ្យោ  គោហិ វា រតនេហិ វា

សេលោ ព្យញ្ជនសម្បន្នោ  នេវ កេយ្យោ មណិ មម។

កែវមណីនេះ ខ្ញុំមិនគប្បីលក់ដោយគោ ដោយរតនៈទាំងឡាយទេ កែវមណីរបស់ខ្ញុំដែលកើតអំពីថ្ម បរិបូណ៌ដោយទ្រង់ទ្រាយ ខ្ញុំមិនគប្បីលក់ឡើយ។

ព្រាហ្មណ៍នេសាទពោលថា :

២៦. នោ ចេតយា មណិ កេយ្យោ  គោហិ វា រតនេហិ វា

អថ កេន មណិ កេយ្យោ តំ មេ អក្ខាហិ បុច្ឆិតោ។

*បើកែវមណីអ្នកមិនលក់ដោយគោ ឬដោយរតនៈទាំងឡាយទេ ចុះកែវមណីអ្នកនឹងលក់ដោយវត្ថុអ្វី ខ្ញុំសួរហើយ អ្នកចូរប្រាប់សេចក្ដីនោះ។*

*អាលម្ពាយន៍ពោលថា :*

២៧. យោ មេ សំសេ មហានាគំ តេជសឹ ទុរតិក្កមំ

តស្ស ទជ្ជំ ឥមំ សេលំ ជលន្តំរិវ តេជសា។

*បុគ្គលណាគប្បីបង្ហាញនាគដ៏ធំមានតេជៈ ដែលគេកន្លងបានដោយក្រ ដល់ខ្ញុំ ខ្ញុំនឹងឲ្យកែវមណី ដ៏រុងរឿងដោយតេជៈដល់បុគ្គលនោះ។*

*ព្រាហ្មណ៍នេសាទពោលថា :*

២៨. កោ នុ ព្រាហ្មណវណ្ណេន សុបណ្ណោ បតតំ វរោ

នាគំ ជិគីសមន្វេតិ អន្វេសំ ភក្ខមត្តនោ។

*អ្នកជាអ្វី ជាគ្រុឌដ៏ប្រសើរជាងសត្វស្លាបទាំងឡាយ កាលស្វែងរកចំណីដើម្បីខ្លួន ទើបចាប់យកនាគដោយភេទជាព្រាហ្មណ៍ឬ?*

អាលម្ពាយន៍ពោលថា :

២៩. នាហំ ទិជាធិបោ ហោមិ ន ទិដ្ឋោ គរុឡោ មយា

អាសីវិសេន វិត្ថោស្មិ វេជ្ជោ ព្រាហ្មណ មំ វិទូ។

ខ្ញុំមិនមែនជាស្តេចសត្វស្លាបទេ គ្រុឌខ្ញុំមិនដែលឃើញទេ ខ្ញុំជាអ្នកត្រេកអរដោយអាសិរពិស ម្នាលព្រាហ្មណ៍ ជនទាំងឡាយដឹងថាខ្ញុំជាហ្មពស់។

ព្រាហ្មណ៍នេសាទពោលថា :

៣០. កឹ តុយ្ហំ ពលំ អត្ថិ កឹ សិប្បំ វិជ្ជតេ តវ

កិស្មឹ វា ត្វំ បរត្ថទ្ធោ ឧរគំ នាបចាយសិ។

កម្លាំងរបស់អ្នកដូចម្តេច សិល្បៈរបស់អ្នកដូចម្តេច ទាំងអ្នករឹងប៉ឹងព្រោះហេតុអ្វី បានជាមិនកោតខ្លាចនាគ។

អាលម្ពាយន៍នោះកាលសម្តែងកម្លាំងរបស់ខ្លួនទើបពោលថា :

៣១. អារញ្ញិកស្ស ឥសិនោ ចិរំ រត្តំ តបស្សិនោ

សុបណ្ណោ កោសិយស្សក្ខា វិសវិជ្ជំ អនុត្តរំ។

តំ ភាវិតត្តញ្ញតរំ សម្មន្តំ បព្វតន្តរេ

សក្កច្ចំ ឧបដ្ឋាសិំ រត្តិន្ទិវមតន្ទិតោ។
សោ តទា បរិចិណ្ណោ មេ វត្តំ វា ព្រហ្មចារិយំ
ទិព្យំ ចាតុកិរ មន្តំ កាមសា ភគវា មមំ។
ត្យាហំ មន្តេ បរត្ថទ្ធោ ឆាហំ ភាយាមិ ភោគិនំ
អាចរិយោ វិសយាតានំ អាលម្ពាយនោតិ មំ វិទូ។

គ្រុឧបានប្រាប់វិជ្ជាពិសដ៏ប្រសើរដល់ឥសីមួយអង្គ ជាកោសិយគោត្រនៅក្នុងព្រៃ ប្រព្រឹត្តតបធម៌អស់រាត្រីយូរៗ ខ្ញុំជាអ្នកមិនខ្ជិលច្រអូសទាំងយប់ទាំងថ្ងៃ បានបម្រើឥសីមួយអង្គនោះដែលមានខ្លួនបម្រើនហើយ កាលគង់នៅក្នុងចន្លោះភ្នំ ដោយសេចក្តីគោរព។ ឥសីនោះដែលខ្ញុំបានបម្រើហើយក្នុងកាលនោះ វត្តក្តីព្រហ្មចរិយៈក្តី ឥសីនោះបានប្រព្រឹត្តហើយ ឥសីមានជោគនោះក៏បង្រៀនមន្តទិព្វដល់ខ្ញុំ តាមសេចក្តីប្រាថ្នា។ ខ្ញុំជាអ្នករឹងប៉ឹងព្រោះមន្តនោះ បានជាមិនខ្លាចនាគទាំងឡាយ ខ្ញុំជាអាចារ្យរបស់ពួកអ្នកសម្លាប់សត្វមានពិសទាំងឡាយ ជនទាំងឡាយស្គាល់ខ្ញុំថាអាលម្ពាយន៍។

ព្រាហ្មណ៍នេសាទ កាលបានស្តាប់ដូចនោះហើយទើបគិតថា អាលម្ពាយន៍នេះ ឲ្យកែវមណីដល់បុគ្គលអ្នកសំដែងទីនៅរបស់ព្រះភូរិទត្តដល់គេ កាលប្រាប់កន្លែងព្រះភូរិទត្តដល់គេហើយ ទើបចាប់យកកែវមណី កាលប្រឹក្សានឹងបុត្រ ទើបពោលដូច្នេះថា :

៣២. គណ្ហាមសេ មណឹ តាត  សោមទត្ត វិជានាហិ
មា ទណ្ឌេន សិរឹ បត្តំ  កាមសា បជហាមសេ ។

ម្នាលសោមទត្តកូន យើងនឹងកាន់យកកែវមណី ចូរអ្នកដឹងចុះ យើងកុំយកដំបងទាត់ចោល សិរីដែលមកដល់ហើយតាមសេចក្តីប្រាថ្នាឡើយ ។

សោមទត្តពោលថា :

៣៣. សកំ និវេសនំ បត្តំ  យោ តំ ព្រាហ្មណ បូជយិ
ឯវំ កល្យាណការិស្ស  កឹ មោហា ទុព្ភិមិច្ឆសិ ។
សចេ ត្វំ ធនកាមោសិ  ភូរិទត្តោ បទិស្សតិ
តមេវ គន្ត្វា យាចស្សុ  ពហុំ ទស្សតិ តេ ធនំ ។

បពិត្រព្រាហ្មណ៍ ភូរិទត្តណាបានបូជាលោកឲ្យដល់នូវនិវេសន៍របស់ខ្លួន លោកប្រាថ្នានឹងប្រទូស្តចំពោះព្រះភូរិទត្តនោះ ដែលធ្វើអំពើល្អយ៉ាងនេះ ព្រោះសេចក្តីវង្វេងធ្វើអ្វីៗ បើលោកឪពុកចង់បានទ្រព្យ ព្រះភូរិទត្តនឹងប្រទាន ចូរលោកឪពុកទៅសុំលោកចុះ លោកនឹងប្រទានទ្រព្យជាច្រើនដល់ឪពុកៗ ព្រាហ្មណ៍ពោលថា :

៣៨.ហត្ថគតំ បត្តគតំ    និក្កិណ្ណំ ខាទិតុំ វរំ
មា នោ សន្ទិដ្ឋិកោ អត្ថោ    សោមទត្ត ឧបច្ចគា ។

ម្នាលសោមទត្ត យើងគួរស៊ីរបស់ឆ្អិនដែលមកដល់ដៃ ឬដល់ភាជន៍ប្រសើរជាង កុំឲ្យប្រយោជន៍ដែលឃើញច្បាស់នឹងភ្អែកកន្លងផុតពីយើងទៅបាន។

សោមទត្តកុមារពោលថា :

៣៩.បច្ចតិ និរយេ ឃោរេ    មហិមស្ស វិន្ទ្រិយតិ
មិត្តទុព្ភី ហិតច្ចាគី    ជីវរេ វាបិ សុស្សតិ។
សចេ ត្វំ ធនកាមោសិ    ភូរិទត្តោ បទស្សតិ
មញ្ញេ អត្តកតំ វេរំ    ន ចិរំ វេទយិស្សសិ។

បុគ្គលជាអ្នកទ្រុស្តមិត្ត ជាអ្នកលះបង់ប្រយោជន៍ រមែងឆេះក្នុងនរកដ៏គួរខ្លាច ផែនដីក៏ស្រូបបុគ្គលទ្រុស្តមិត្តនោះ បុគ្គលទ្រុស្តមិត្តសូម្បីរស់នៅក៏រឹងស្ងួត(ដូចជាប្រេត)។ បើឪពុកចង់បានទ្រព្យ ព្រះភូរិទត្តនឹងប្រទានជាមិនខាន ខ្ញុំសម្គាល់មិនយូរប៉ុន្មាន ឪពុកនឹងដឹងច្បាស់នូវពៀរដែលខ្លួនធ្វើហើយ។



ចប់សោមទត្តកុមារ

ព្រាហ្មណ៍នេសាទនិយាយថា :

៣៦.មហាយញ្ញំ យជិត្វាន ឯវំ សុជ្ឈន្តិ ព្រាហ្មណា
មហាយញ្ញំ យជិស្សាម ឯវំ មោក្ខាម បាបកា។

ព្រាហ្មណ៍ទាំងឡាយបូជាមហាយ័ញ្ញហើយ រមែងបរិសុទ្ធ យ៉ាងនេះ យើងនឹងបូជាមហាយ័ញ្ញ គង់នឹងរួចចាកបាប ដោយ អាការៈយ៉ាងនេះ។

សោមទត្តពោលថា :

៣៧. ហន្ទទានិ អបាយាមិ នាហំ អជ្ជ តយា សហ
បទមេកំ ន គច្ឆេយ្យំ ឯវំ កិព្វិសការិនា។

ណ្ហើយចុះឥឡូវនេះ ខ្ញុំនឹងគេចចេញថ្ងៃនេះ ខ្ញុំមិនទៅជាមួយ ឪពុកទេ ខ្ញុំមិនដើរជាមួយនឹងឪពុក ដែលធ្វើអំពើអាក្រក់យ៉ាងនេះ អស់មួយជំហានទេ។

៣៨. ឥទំ វត្វាន បិតរំ សោមទត្តោ ពហុស្សុតោ
ឧជ្ឈាបេត្វាន ភូតានិ តម្ហា ឋានា អបក្កមិ។

(អភិសម្ពុទ្ធគាថា) សោមទត្តកុមារ ជាពហុស្សូត បានពោលពាក្យនេះនឹងបិតាហើយ ក៏ប្រកាសប្រាប់ទេវតាទាំងឡាយ រួចគេចចេញចាកពីទីនោះ។



ចប់សោមទត្តកណ្ឌ

ព្រាហ្មណ៍នេសាទគិតថា សោមទត្តនឹងមិនទៅទីណាក្រៅអំពីផ្ទះរបស់ខ្លួនឡើយ។ កាលឃើញអាលម្ពាយន៍មិនពេញចិត្តបន្តិច ទើបលួងលោមថា ម្នាលអាលម្ពាយន៍ លោកកុំវិតក្កៈឡើយ យើងនឹងចង្អុលប្រាប់ភូរិទត្តដល់លោក ដូច្នេះហើយក៏នាំអាលម្ពាយន៍ទៅកាន់ទីកន្លែងរក្សាឧបោសថនៃស្តេចនាគ។ ឃើញស្តេចនាគពន្លឺព័ទ្ធគ្រង់ដំបូក ទើបឈរនៅក្នុងទីមិនឆ្ងាយ លាតដៃចេញហើយពោលពីរគាថាដូច្នេះថា :

៣៩. តណ្ហាហេតំ មហានាគំ អាហារេតំ មណឹ មម
ឥន្ទគោបកវណ្ណាភា យស្ស លោហិតកោ សិរោ។
កប្បាសបិចុរាសីវ ឯសោ កាយោ បទិស្សតិ
វម្មិកគ្គគតោ សេតិ តំ ត្វំ គណ្ហាហិ ព្រាហ្មណ។

នាគណាមានពន្លឺ ដូចជាសម្បុរនៃសត្វមេភ្លៀង មានក្បាលក្រហម អ្នកចូរចាប់នាគធំនុ៎ះចុះ ហើយចូរនាំកែវមណីនុ៎ះដល់ខ្ញុំ។ កាយរបស់នាគនុ៎ះ រមែងប្រាកដដូចជាគំនរប៉ុយកប្បាស នាគនេះដេកលើដំបូក ម្នាលព្រាហ្មណ៍ អ្នកចូរចាប់យកនាគនោះចុះ។

ព្រះបរមពោធិសត្វ បើកភ្នែកឡើងឃើញព្រាហ្មណ៍នេសាទ ទើបគិតថា យើងបានគិតហើយថា ព្រាហ្មណ៍នេះនឹងធ្វើអន្តរាយ

ដល់ឧបោសថរបស់យើង យើងទើបនាំអ្នកនេះទៅកាន់ពិភពនាគ រៀបចំឲ្យមានសម្បត្តិជាច្រើន មិនប្រាថ្នាដើម្បីនឹងទទួលកែវមណី ដែលយើងឲ្យទេ តែឥឡូវនេះ បែរជាទៅទទួលយកកែវមណីពីហ្ម ពស់មក បើយើងក្រោធដល់អ្នកប្រទូសរ៉ាយមិត្ត សីលរបស់យើង ក៏នឹងដាច់ យើងបានអធិដ្ឋានឧបោសថ ដែលប្រកបដោយអង្គ៤ ទុកពីមុនហើយ ត្រូវឲ្យមាំទាំ អាលម្ពាយន៍នឹងកាត់ពុះ សម្លាប់ចាក់ ដោយស្នូរក៏ដោយចុះ យើងនឹងមិនក្រោធគេឡើយ បើយើងនឹង ក្រឡេកមើលគេដោយសេចក្ដីក្រោធ គេក៏នឹងខ្ទេច ដូចជាផេះ ណ្ដើយចុះ ចូរគេប់វាយយើងចុះ យើងនឹងមិនក្រោធឡើយ ដូច្នេះ ហើយក៏ធ្មេចភ្នែក ព្រោះបំពេញអធិដ្ឋានបារមីទុកជាខាងមុខ ស៊ក ក្បាលចូលទុកខាងក្នុងរង្វេល ដេកស្ងៀមមិនបានកម្រើកឡើយ។



ចប់សីលកណ្ឌ

ចំណែកព្រាហ្មណ៍នេសាទពោលថា : ម្នាលអាលម្ពាយន៍ដ៏ចម្រើន អញ្ជើញអ្នកចាប់នាគនេះហើយ ចូរឲ្យកែវមណីដល់យើងចុះៗ អាលម្ពាយន៍ឃើញនាគហើយ ក៏ត្រេកអរមិនបានរាប់អានក្នុងកែវថាមានអ្វីទៀតឡើយ ប្រៀបដូចជាស្មៅ បោះកែវមណីទៅត្រង់ដៃព្រាហ្មណ៍នេសាទ ដោយពាក្យថា យកទៅចុះព្រាហ្មណ៍ កែវមណីក៏ភ្លាត់ចាកដៃព្រាហ្មណ៍ធ្លាក់ចុះត្រង់ផែនដីៗ គ្រាន់តែធ្លាក់ចុះហើយ ក៏លិចចុះទៅក្នុងផែនដី ទៅកាន់ពិភពនាគនោះវិញៗ ព្រាហ្មណ៍នេសាទសាបសូន្យចាកឋានៈ៣ប្រការ គឺសាបសូន្យចាកកែវមណី១ សាបសូន្យចាកមិត្តភាពជាមួយនឹងព្រះភូរិទត្ត១ និងសាបសូន្យចាកបុត្ត១ៗ គាត់ក៏យំរៀបរាប់ថា យើងអស់ទីពឹងអាស្រ័យហើយ ព្រោះយើងមិនបានធ្វើតាមពាក្យរបស់កូន ហើយទៅកាន់ផ្ទះៗ

ចំណែកអាលម្ពាយន៍ ក៏លាបរាងកាយរបស់ខ្លួន ដោយឱសថជាទិព្យ ទំពាស៊ីបន្តិច និងប្រោះព្រំកាយរបស់ខ្លួន ក៏រាយទិព្វមន្តចូលទៅរកព្រះពោធិសត្វ ចាប់កន្ទុយព្រះពោធិសត្វកន្ត្រាក់

មក ចាប់ក្បាលសង្កត់ទុកមាំហើយ បើកមាត់ព្រះបរមពោធិសត្វ ទំពាថ្នាំព្រួសដាក់ព្រមទាំងស្ដោះស្ទ ចូលទៅក្នុងមាត់ព្រះបរមពោធិ-សត្វ។ ស្ដេចនាគជាអ្នកមានជាតិស្អាត មិនក្រោធ មិនបើកភ្នែក ព្រោះខ្លាចដាច់សីល។ លំដាប់នោះអាលម្ពាយន៍ប្រើថ្នាំ និងមន្ត ចាប់កន្ទុយព្រះពោធិសត្វព្យួរឲ្យក្បាលសំយុងចុះទៅក្រោម រលាក់ឲ្យអស់អាហារដែលមាននៅហើយ ឲ្យដេកលាតសន្ធឹងលើផែនដី ជាន់ដោយជើងដូចមនុស្សជំសណ្ដែក ឆ្អឹងបែកជាចម្រៀកតូចៗ។ ចាប់កន្ទុយព្រះបរមពោធិសត្វព្យួរ ឲ្យក្បាលសំយ៉ុងចុះខាងក្រោមម្ដងទៀត វាយដូចជាវាយសំពត់។ ព្រះបរមពោធិសត្វសូម្បីសោយទុក្ខវេទនាបែបនេះក៏មិនក្រោធខឹងឡើយ។

ព្រះសាស្ដាកាលទ្រង់ប្រកាសសេចក្ដីនោះទើបត្រាស់ថា៖

៤០. អថោ សធេហិ ឱពេហិ ជប្បំ មន្តបទានិ ច
ឯវន្តំ អសក្ខិ ជុជ្ជំ កត្វា បរិត្តមត្ថនោ។

គ្រានោះអាលម្ពាយនព្រាហ្មណ៍ កាលជប់បទនៃមន្តទាំងឡាយ ធ្វើជាគ្រឿងការពារខ្លួន ដោយឱសថទិព្វទាំងឡាយហើយ ទើបអាចចាប់នាគនោះដោយវិធីយ៉ាងនេះ។

អាលម្ពាយន៍ កាលធ្វើព្រះបរមពោធិត្វ ឲ្យថមថយកម្លាំងដូច្នោះហើយ ទើបយកវល្លិចាក់ជាកន្ត្រកហើយយកព្រះបរមពោធិ-សត្វដាក់ក្នុងកន្ត្រកនោះ តែសរីរៈរបស់ព្រះបរមពោធិសត្វធំពេកចូលទៅក្នុងកន្ត្រកនោះមិនបាន។ លំដាប់នោះ អាលម្ពាយន៍ទើបប្រើកែងជើងធាក់ព្រះបរមពោធិសត្វឲ្យចូលទៅ ហើយពុនកន្ត្រកទៅដល់ស្រុកមួយកន្លែង ទើបដាក់កន្ត្រកចុះដាក់ទុកកណ្ដាលស្រុក ស្រែកប្រាប់ថា អ្នកណាប្រាថ្នានឹងមើលការរាំរបស់ពស់ក៏ចូលមក អ្នកស្រុកទាំងអស់ម្នាក់ៗមកប្រជុំគ្នា ខណៈនោះអាលម្ពាយន៍ទើបពោលថា សូមមហានាគចេញមក ព្រះបរមពោធិសត្វគិតថា ថ្ងៃនេះយើងនឹងលេងឲ្យបរិស័ទរីករាយ ទើបនឹងគួរ។ អាលម្ពាយន៍កាលបានទ្រព្យច្រើនយ៉ាងនេះត្រេកអរហើយ នឹងពន្លែងយើងទៅ អាលម្ពាយន៍នឹងឲ្យយើងធ្វើយ៉ាងណា យើងក៏នឹងធ្វើយ៉ាងនោះ។ លំដាប់នោះអាលម្ពាយន៍ ក៏នាំព្រះបរមពោធិសត្វចេញអំពីកន្ត្រក ហើយពោលថា អ្នកចូរធ្វើខ្លួនឲ្យធំ។ ព្រះបរមពោធិសត្វធ្វើខ្លួនឲ្យធំ អាលម្ពាយន៍ប្រាប់ឲ្យធ្វើខ្លួនឲ្យតូច នឹងឲ្យពេនព័ន្ធ ឲ្យរំសាយ ឲ្យបើកពពារ១ ពពារ២ ពពារ៣, ៤, ៥, ៦, ៧, ៨, ៩, ១០,

២០, ៣០, ៤០, ៥០, ៦០, ៧០, ៨០, ៩០, ១០០...ឲ្យខ្ពស់ ឲ្យទាប ឲ្យឃើញខ្លួន ឲ្យបាត់ខ្លួន ឲ្យឃើញពាក់កណ្តាលខ្លួន ឲ្យពណ៌ ខៀវ លឿង ក្រហម ស ហង្សបាទ ឲ្យព្រួសអណ្តាតភ្លើង ព្រួសទឹក បន្តុយផ្សេងៗ ក្នុងអាការៈទាំងនេះអាលម្ពាយន៍ប្រាប់ឲ្យធ្វើអាការៈ ណាៗ ព្រះបរមពោធិសត្វក៏និម្មិតអត្តភាព សម្តែងអាការៈនោះៗ គ្រប់យ៉ាងៗ អ្នកណាៗឃើញព្រះបរមពោធិសត្វនោះហើយ ក៏មិន អាចនឹងទប់ទឹកភ្នែកបានឡើយ។ មនុស្សម្នាជាច្រើន ម្នាក់ៗនាំគ្នា ឲ្យរបស់ផ្សេងៗ មានប្រាក់ មាស សំពត់ និងគ្រឿងប្រដាប់ ជាដើម។ អាលម្ពាយន៍ទើបបានទ្រព្យក្នុងស្រុកនោះប្រមាណមួយ ពាន់ៗដោយអាការៈយ៉ាងនេះ។ អាលម្ពាយន៍នោះចាប់ព្រះបរម-ពោធិសត្វ បានទ្រព្យមួយពាន់ ទើបពោលនឹងព្រះបរមពោធិសត្វ ថា នឹងពន្លែងពិតប្រាកដ ប៉ុន្តែដល់បានទ្រព្យមួយពាន់ហើយ ក៏ គិតថា សូម្បីក្នុងស្រុកតូច យើងបានទ្រព្យប៉ុណ្ណោះ ចុះបើក្នុងព្រះ នគរ គង់នឹងបានទ្រព្យច្រើន ព្រោះសេចក្តីលោភលន់ក្នុងទ្រព្យ ទើប មិនបានពន្លែងព្រះបរមពោធិសត្វទេ។ អាលម្ពាយន៍នោះបានផ្តើម តាំងរណ្តាទ្រព្យឡើងក្នុងស្រុកនោះ ហើយទើបឲ្យនាយជាងធ្វើ

កន្ត្រកកែវ ដាក់ព្រះបរមពោធិសត្វក្នុងកន្ត្រកកែវនោះ ហើយក៏ឡើងកាន់យានតូចយ៉ាងសប្បាយ ចេញទៅដោយបរិវារជាច្រើន ឲ្យព្រះបរមពោធិសត្វទៅលេងក្នុងស្រុក និងនិគមជាដើម រហូតដល់ក្រុងពារាណសីដោយលំដាប់ៗ តែអាលម្ពាយន៍មិនឲ្យទឹកឃ្មុំនិងលាចដល់ស្តេចនាគទេ សម្លាប់កង្កែបឲ្យបរិភោគ ព្រះបរមពោធិសត្វមិនបានទទួលទានទេ លោកមិនបរិភោគអាហារព្រោះខ្លាចអាលម្ពាយន៍មិនពន្លែងៗ អាលម្ពាយន៍ទើបឲ្យព្រះពោធិសត្វលេងក្នុងស្រុកនោះៗតាំងអំពីដើមស្រុកជិតទ្វារទាំង៤ទិសនៃព្រះនគរៗ កាលដល់ថ្ងៃឧបោសថ១៥កើត អាលម្ពាយន៍ទើបសុំឲ្យក្រាបទូលដល់ព្រះរាជាថា ទូលព្រះបង្គំនឹងនាំឲ្យនាគរាជលេងថ្វាយព្រះអង្គៗ ព្រះរាជាទើបបង្គាប់ឲ្យវាយស្គរស្រែកប្រកាសឲ្យមហាជនប្រជុំគ្នា ជនពួកនោះ ទើបនាំគ្នាមកប្រជុំខាងលើគ្រែ និងតម្រួតគ្រែត្រង់ព្រះលានហ្លួង រង់ចាំមើលការសម្តែងៗ



អាលម្ពាយឯកណ្ឌ

ក្នុងថ្ងៃ ដែលអាលម្ពាយន៍ចាប់ព្រះបរមពោធិសត្វទៅនោះ ព្រះមាតារបស់ព្រះបរមពោធិសត្វបានឃើញព្រះសុបិនថា ព្រះនាងត្រូវមនុស្សប្រុសម្នាក់ មានខ្លួនខ្មៅ ភ្នែកក្រហម យកដាវកាត់ដៃស្តាំរបស់ព្រះនាងដាច់ ហើយនាំយកទៅទាំងដែលមានឈាមហូរៗ កាលព្រះនាងតើនឡើងក៏តក់ស្លុត ក្រោកឡើងស្ទាបដៃស្តាំ ទ្រង់ជ្រាបថាជាព្រះសុបិន លំដាប់នោះព្រះនាងទ្រង់ត្រិះរិះថា យើងសុបិនឃើញអាក្រក់ណាស់ បុត្ររបស់យើងទាំងបួននាក់ ឬស្តេចធតរដ្ឋៈ ទាំងខ្លួនយើងគង់នឹងមានអន្តរាយជាមិនខាន, ម្យ៉ាងទៀតព្រះនាងទ្រង់ប្រារព្ធគិតដល់ព្រះបរមពោធិសត្វ ក្រៃលែងជាងអ្នកដទៃៗ ព្រោះហេតុអ្វី ព្រោះហេតុថា នាគក្រៅអំពីនោះ នៅក្នុងនាគពិភពរបស់ខ្លួន ចំណែកព្រះបរមពោធិសត្វ ជាអ្នកមានសីលមានអជ្ឈាស្រ័យទៅកាន់មនុស្សលោក ធ្វើឧបោសថកម្ម ព្រោះហេតុនោះ ព្រះនាងទ្រង់គិតដល់ព្រះភូរិទត្តក្រៃលែងជាងអ្នកណាៗទាំងអស់, ថាហ្នពស់ ឬគ្រុឌ នឹងគប្បីចាប់យកបុត្ររបស់យើងទៅឬហ្ន៎? អំពីនោះកន្លងទៅបានកន្លះខែព្រះនាងទ្រង់ដល់នូវទោ-

មនស្សថា បុត្ររបស់យើងមិនអាចនឹងព្រាត់ប្រាសចាកយើងឲ្យលើសពីកន្លះខែបានឡើយ ភ័យយ៉ាងណាមួយនឹងកើតឡើងដល់បុត្ររបស់យើងជាពិតប្រាកដៗ កាលកន្លងទៅបានមួយខែ ព្រះនាងសមុទ្ទជាក៏ទ្រង់សោកសៅមិនដាច់ទឹកព្រះនេត្រទេ ដួងហឫទ័យក៏ក្រៀមក្រំ ព្រះនេត្រទាំងពីរក៏ហើមឡើង ព្រះនាងសមុទ្ទជាទ្រង់អង្គុយសម្លឹងមើលរកផ្លូវដែលព្រះបរមពោធិសត្វមកដល់តែប៉ុណ្ណោះដោយទ្រង់រំពឹងថា កុរិទត្តនឹងមកឥឡូវនេះៗ។ គ្រានោះសុទស្សនៈជាបុត្រច្បងរបស់ព្រះនាងសមុទ្ទជា គ្រាកន្លងទៅបានមួយខែហើយព្រមដោយបរិវារជាច្រើនមកសួរសុខទុក្ខព្រះមាតាបិតា បញ្ឈប់បរិវារទុកខាងក្រៅ ហើយឡើងកាន់ប្រាសាទ ថ្វាយបង្គំព្រះមាតាហើយឈរនៅក្នុងទីដ៏សមគួរ ព្រះនាងសមុទ្ទជានោះកំពុងសោយសោកដល់ព្រះកុរិទត្តមិនបានចរចាប្រាស្រ័យជាមួយនឹងសុទស្សនៈទេៗ សុទស្សនៈទើបគិតថា ព្រះមាតារបស់យើង កាលយើងមកពេលមុនៗ ឃើញយើងហើយរមែងត្រេកអរបដិសណ្ឋារៈ ប៉ុន្តែថ្ងៃនេះ ព្រះមាតាទ្រង់ទោមនស្សតូចព្រះទ័យ គង់មានហេតុអ្វីជា

ពិតប្រាកដៗ លំដាប់នោះកាលនឹងទូលសួរព្រះមាតា ទើបពោលថា :

៤១. មមំ ទិស្វាន អាយន្តំ សព្វកាមសមិទ្ធិនំ
ឥន្ទ្រិយានិ អហដ្ឋានិ សាវំ ជាតំ មុខំ តវ ។
បទុមំ យថា ហត្ថគតំ ចាណិនា បរិមទ្ទិតំ
សាវំ ជាតំ មុខំ តុយ្ហំ មមំ ទិស្វាន ឯទិសំ ។

ឥន្ទ្រីយ៍របស់ព្រះមាតាមិនស្រស់បស់ ព្រះភក្ត្ររបស់ព្រះមាតាក៏ខ្មៅ ព្រោះឃើញខ្ញុំដែលសម្រេចសេចក្តីប្រាថ្នាទាំងពួងកំពុងមកគាល់ឬ? ព្រះភក្ត្ររបស់ព្រះមាតាខ្មៅ ដូចជាផ្កាឈូកដែលបិតនៅក្នុងដៃដែលគេប្របាច់ដោយដៃ ព្រោះតែឃើញខ្ញុំប្រាកដដូច្នេះឬ?

សូម្បីកាលសុទស្សនៈពោលយ៉ាងនេះហើយ ព្រះនាងសមុទ្ទជាមិនបានទ្រង់ត្រាស់ប្រាស្រ័យចរចាឡើយ សុទស្សនៈទើបគិតថា អ្នកណាធ្វើឲ្យព្រះមាតាក្រោធឬហ្ន៎ ឬថាគប្បីមានអន្តរាយៗ លំដាប់នោះសុទស្សនៈកាលនឹងទូលសួរព្រះមាតានោះទើបពោលគាថាទៀតថា :

៤២. កច្ចិ នុ តេ ណាភិស្សសិ កច្ចិ តេ អត្ថិ វេទនា
យេន សាវំ មុខំ តុយ្ហំ មមំ ទិស្វាន អាគតំ ។

ក្រែងបុគ្គលណាមួយ មិនរាប់អានលោកខ្លះឬ វេទនារបស់លោកមានខ្លះឬ ព្រះភក្ត្ររបស់លោកខ្មៅ ព្រោះឃើញខ្ញុំមកដោយហេតុណា (សូមលោកប្រាប់នូវហេតុនោះដល់ខ្ញុំចុះ)។

លំដាប់នោះព្រះនាងសមុទ្ទជា កាលនឹងត្រាស់តបដល់សុទស្សនៈ ទើបត្រាស់ថា :

៤៣. សុបិនំ តាត អទ្ទក្ខិំ ឥតោ មាសំ អធោគតំ
ទក្ខិណំ វិយ មេ ពាហុំ ឆេត្វា រុហិរមក្ខិតំ
បុរិសោ អាទាយ បក្កាមិ មម រោទន្តិយា សតិ ។
យតោហំ សុបិនមទ្ទក្ខិំ សុទស្សន វិជានាហិ
តតោ ទិវា វា រត្តឹ វា សុខំ មេ នោបលព្ភតិ ។

ម្នាលកូនក្រោយមួយខែមកហើយអំពីថ្ងៃនេះ យើងបានឃើញសុបិនថា ហាក់បីដូចជាបុរសកាត់ដៃខាងស្តាំរបស់យើង ហើយនាំយកដៃដែលប្រឡាក់ដោយឈាម ដើរចេញទៅក្នុងកាលដែល

យើងកំពុងស្រែកយំៗ ម្នាលសុទស្សនៈ កាលណាយើងបានឃើញសុបិន អ្នកចូរដឹងចុះថា កាលនោះយើងមិនបានសេចក្ដីសុខទាំងថ្ងៃទាំងយប់ៗ

កាលព្រះនាងសមុទ្ទជាត្រាស់យ៉ាងនេះហើយ ទើបត្រាស់ថា ម្នាលកូនជាទីស្រឡាញ់ ប្អូនរបស់កូនបាត់ទៅដោយមិនបានឃើញ ប្រហែលជាភ័យគង់នឹងកើតមានដល់ប្អូនរបស់កូនដូច្នេះ ទ្រង់រៀបរាប់បណ្ដើរពោលតទៅថា :

៤៤. យំ បុព្វេ បរិវារឹសុ　　កញ្ញា រុចិរវិគ្គហា
ហេមជាលបដិច្ឆន្នា　　ភូរិទត្តោ ន ទិស្សតិ។
យំ បុព្វេ បរិវារឹសុ　　នេត្តឹសវរធារិនោ
កាឡិការាវ សម្មុល្ហា　　ភូរិទត្តោ ន ទិស្សតិ។
ហន្ទទានិ គមិស្សាម　　ភូរិទត្តនិវេសនំ
ធម្មដ្ឋំ សីលសម្បន្នំ　　បស្សាម តវ ភាតរំ។

នាងកញ្ញាទាំងឡាយ មានរាងកាយដ៏រុងរឿង ពាក់បណ្ដាញមាស បានចោមរោមភូរិទត្តណា ពីក្នុងកាលមុន (ឥឡូវនេះ)ភូរិទត្ត

នោះ យើងមិនឃើញទេ។ នាគទាំងឡាយដែលកាន់ព្រះខ័នដ៏ប្រសើរ ដូចជាផ្កាកណ្ណិការីក ចោមរោមភូរិទត្តណា ពីក្នុងកាលមុន (ឥឡូវនេះ)ភូរិទត្តនោះ យើងមិនឃើញទេ។ ណ្ហើយចុះឥឡូវនេះ យើងនឹងទៅកាន់លំនៅរបស់ភូរិទត្ត យើងគង់នឹងឃើញប្អូនរបស់អ្នកដែលតាំងនៅក្នុងធម៌បរិបូណ៌ដោយសីល។

កាលព្រះនាងសមុទ្ទជាត្រាស់យ៉ាងនេះហើយ ទើបស្ដេចយាងទៅកាន់និវេសន៍នៃភូរិទត្ត ព្រមដោយបរិវាររបស់សុទស្សនៈ និងបរិវាររបស់ព្រះនាង ចំណែកពួកកិរិយារបស់ព្រះបរមពោធិ-សត្វកាលមិនឃើញព្រះភូរិទត្តត្រង់ដំបូកហើយទើបគិតថា គង់នឹងនៅក្នុងនិវេសន៍របស់ព្រះមាតា ទើបមិនបាននាំគ្នាខ្វល់ខ្វាយតាមរក។ កិរិយាពួកនោះ កាលជ្រាបដំណឹងថា ព្រះមាតាក្មេកមក មិនឃើញបុត្ររបស់ខ្លួន ទើបនាំគ្នាបដិសណ្ឋារៈ ហើយទូលសួរថា បពិត្រព្រះមាតា កាលព្រះរាជបុត្ររបស់ព្រះមាតាបាត់កន្ទងទៅមួយខែចូលមកដល់ថ្ងៃនេះ ហើយម្នាក់ៗយំរៀបរាប់ ក្រាបចុះទៀប

ព្រះបាទរបស់ព្រះនាងសមុទ្ទជា, ព្រះសាស្តាកាលនឹងទ្រង់ប្រកាសសេចក្តីនោះទើបទ្រង់ត្រាស់ថា :

៤៥. តញ្ច ទិស្វាន អាយន្តំ  ភូរិទត្តស្ស មាតរំ
ពាហា បគ្គយ្ហ បក្កន្ទុំ  ភូរិទត្តស្ស ភរិយាយោ។
បុត្តន្តេយ្យេ ន ជានាម  ឥតោ មាសំ អធោគតំ
មតំ វា យទិ វា ជីវំ  ភូរិទត្តំ យសស្សិនំ។

ឯភរិយាទាំងឡាយរបស់ភូរិទត្ត បានឃើញព្រះមាតានៃភូរិទត្តនោះកំពុងដើរមកក៏ផ្គងដៃឡើងកន្ទក់កន្ទេញថា : បពិត្រព្រះមាតាជាម្ចាស់ ក្រោយមួយខែមកហើយអំពីថ្ងៃនេះ យើងខ្ញុំមិនដឹងភូរិទត្តដ៏មានយសជាបុត្ររបស់លោកស្លាប់ ឬក៏រស់នៅទេ។

ព្រះមាតារបស់ព្រះភូរិទត្ត ស្តេចព្រមដោយកូនប្រសារស្រី ទ្រង់នាំគ្នាយំរៀបរាប់ក្នុងកណ្តាលថ្នល់ ទ្រង់នាំស្រ្តីទាំងនោះឡើងកាន់ប្រាសាទរបស់ភូរិទត្តត្រួតមើលទីដេក និងទីអង្គុយរបស់បុត្រ ហើយយំរៀបរាប់ ទើបត្រាស់គាថាដូច្នេះថា :

៤៦. សកុណី ហតបុត្តាវ សុញ្ញំ ទិស្វា កុលាវកំ
ចិរំ ទុក្ខេន ឈាយិស្សំ ភូរិទត្តំ អបស្សតី ។
កុររី ហតច្ឆាចាវ សុញ្ញំ ទិស្វា កុលាវកំ
ចិរំ ទុក្ខេន ឈាយិស្សំ ភូរិទត្តំ អបស្សតី ។
សា នូន ចក្កាវក្កីវ បល្លលស្មិំ អនូទកេ
ចិរំ ទុក្ខេន ឈាយិស្សំ ភូរិទត្តំ អបស្សតី ។
កម្មារានំ យថា ឧក្កា អន្តោ ឈាយតិ នោ ពហិ
ឯវំ ឈាយាមិ សោកេន ភូរិទត្តំ អបស្សតី ។

យើងកាលមិនឃើញភូរិទត្តទេ នឹងឆេះដោយសេចក្តីទុក្ខអស់កាលដ៏យូរ ដូចជាមេសត្វស្លាបបាត់កូន ឃើញតែសម្បុកទទេដូច្នោះៗ យើងកាលមិនឃើញភូរិទត្ត នឹងឆេះដោយសេចក្តីទុក្ខ

អស់កាលយូរ ដូចជាមេអកបាត់កូន ឃើញតែសម្បុកទទេដូច្នោះៗ យើងកាលមិនឃើញភូរិទត្តទេ នឹងឆេះដោយសេចក្តីទុក្ខអស់កាលយូរ ដូចជាមេសត្វចាក្រពាកនោះនៅលើកក់ ដែលមិនមានទឹកដោយពិតៗ ជើងក្រានទៃពួកជាងមាស ឆេះតែខាងក្នុង

មិនចេះខានក្រៀមយ៉ាងណា យើងកាលមិនឃើញភូរិទត្ត នឹងចេះដោយសេចក្ដីសោកយ៉ាងនោះដែរ។

កាលព្រះមាតាភូរិទត្តទ្រង់រៀបរាប់យ៉ាងនេះ និវេសន៍របស់ភូរិទត្តក៏ឮសម្រែងទ្រហោយំតែមួយ ហាក់បីដូចជាសម្រែងរលកក្នុងផ្ទៃសមុទ្រដូច្នោះ សូម្បីនាគត្រឹមតែម្នាក់ក៏មិនអាចទ្រទ្រង់នូវការៈរបស់ខ្លួនបានឡើយ។ ទូទៅទាំងនិវេសន៍ដូចជាព្រៃឈើរាំងត្រូវខ្យល់យុគន្ធវាទដូច្នោះ ព្រះសាស្ដាកាលនឹងទ្រង់ប្រកាសសេចក្ដីនោះទើបត្រាស់ថា :

៤៧. សាលាវ សម្បមទ្ទិតា មាលុតេន បមទ្ទិតា
សេន្តិ បុត្តា ច ទារា ច ភូរិទត្តនិវេសនេ។

កូននឹងប្រពន្ធទាំងឡាយ ដួលដេកក្នុងនិវេសន៍របស់ព្រះភូរិទត្តដូចជាដើមឈើដែលត្រូវខ្យល់ញាំញីបំបាក់ដូច្នោះ។

ក្នុងកាលនោះអរិដ្ឋៈ និងសុភោគៈពីរនាក់បងប្អូនប្រុសទៅកាន់ទីឧបដ្ឋាករបស់ព្រះមាតាបិតា បានឮសម្រែងនោះ ទើបចូល

ទៅកាន់និវេសន៍របស់ភូរិទត្ត នាំគ្នាជួយលួងលោមព្រះមាតា។ ព្រះសាស្តាកាលនឹងទ្រង់ត្រាស់សេចក្តីនោះទើបត្រាស់ថា :

៤៨. តេសំ សុត្វាន និគ្ឃោសំ ភូរិទត្តនិវេសនេ
អរិដ្ឋោ ច សុភោគោ ច បធាវឹសុ អនន្តរា។
អម្ម អស្សាស មា សោចិ ឯវំ ធម្មា ហិ បាណិនោ
ចវន្តិ ឧបបជ្ជន្តិ ឯសាស្ស បរិណាមតា។

អរិដ្ឋៈ និងសុភោគនាគរាជ បានឮសម្លេងគឹកកងនៃនាគទាំងនោះក្នុងនិវេសន៍របស់ព្រះភូរិទត្ត ក៏ស្ទុះទៅតាមលំដាប់ ហើយពោលថា បពិត្រព្រះមាតា សូមព្រះមាតាជកដង្ហើមឲ្យបានស្រួលចុះ កុំសោយសោកឡើយ ព្រោះថាសត្វទាំងឡាយ មានសភាពយ៉ាងនេះជាធម្មតា តែងច្យុតិ តែងកើតឡើងវិញ នេះជាការប្រែប្រួលនៃលោក។

នាងសមុទ្ទជាពោលថា :

៤៩. អហំបិ តាត ជានាមិ ឯវំ ធម្មា ហិ បាណិនោ
សោកេន ច បរេតស្មិ ភូរិទត្តំ អបស្សតី

អជ្ជ ចេ មេ ឥមំ រត្តឹ   សុទស្សន វិជានាហិ ។

ម្នាលកូនមាសម្ដាយ យើងក៏ដឹងថាសត្វទាំងឡាយមានសភាពយ៉ាងនេះជាធម្មតាដែរ តែថាយើងកាលមិនឃើញកូរិទត្តទេ ត្រូវសេចក្ដីសោកគ្របសង្កត់ហើយ ប្រសិនបើ(កូរទត្ត)មិនបាន(មកជួប)នឹងយើងក្នុងថ្ងៃនេះ យប់នេះទេ ម្នាលសុទស្សនៈ អ្នកចូរដឹងចុះ យើងកាលមិនឃើញកូរទត្តទេ យើងមុខជានឹងលះបង់នូវជីវិតពុំខាន។

កូនទាំងឡាយពោលថា :

៥០. អម្ម អស្សាស មា សោចិ   អានយិស្សាម ភាតរំ
ទិសោទិសំ គមិស្សាម   ភាតុបរិយេសនំ ចរំ
បព្វតេ គិរិទុគ្គេសុ   គាមេសុ និគមេសុ ច
ឱរេន សត្តរត្តស្ស   ភាតរំ បស្ស អាគតំ ។

បពិត្រព្រះមាតា សូមព្រះមេ លោកដកដង្ហើមឲ្យស្រួលចុះ កុំសោយសោកឡើយ យើងទាំងឡាយនឹងនាំបងមក យើងទាំង-

ឡាយត្រាច់ទៅកាន់ទីស្វែងរកបង នឹងទៅកាន់ទិសតូចធំលើភ្នំ ជ្រោះភ្នំ ក្នុងស្រុក និងនិគមទាំងឡាយ លោកចូរឃើញបង ដែលមកក្នុងរវាងខាងក្នុង៧រាត្រី។

បន្ទាប់អំពីនោះមក សុទស្សនៈទើបគិតថា បើយើងទាំងបីទៅរួមគ្នាក៏នឹងយឺតយូរ គួរបែងជាបីកន្លែង គឺម្នាក់ទៅទេវលោក ម្នាក់ទៅកាន់ព្រៃហេមពាន្ត ម្នាក់ទៅកាន់មនុស្សលោក តែបើឲ្យកាណារិដ្ឋៈទៅមនុស្សលោក បើទៅជួបភូរិទត្តក្នុងស្រុក និងនិគមណា ក៏នឹងដុតបំផ្លាញស្រុក និងនិគមនោះអស់ ព្រោះកាណារិដ្ឋៈគ្រោតគ្រាតអាក្រក់ណាស់ មិនគួរឲ្យទៅមនុស្សលោកទេ ដូច្នេះទើបបញ្ជូនអរិដ្ឋៈ ទៅទេវលោកថា ម្នាលអរិដ្ឋៈ អ្នកចូលទៅកាន់ទេវលោក បើទេវតាត្រូវការ ស្ដាប់ព្រះធម៌នាំភូរិទត្តទៅទុកទេវលោកសោត អ្នកចូរនាំគេត្រឡប់មកវិញ។ នឹងបញ្ជូនសុភោគៈឲ្យទៅកាន់ព្រៃហេមពាន្តថា ម្នាលសុភោគៈ អ្នកចូរទៅកាន់ព្រៃហេមពាន្តត្រាច់ស្វែងរកភូរិទត្តក្នុងមហានទីទាំង៥ ជួបភូរិទត្តហើយចូរនាំមក។ ចំណែកសុទស្សនៈខ្លួនឯងបង់ទៅមនុស្សលោក តែ

បែរជាគិតថា បើយើងនឹងទៅដោយភេទជាមនុស្សកម្លោះ ពួកមនុស្សមិនស្រឡាញ់រាប់អាន គួរនឹងទៅដោយភេទជាតាបសវិញ ព្រោះពួកបព្វជិតជាទីស្រឡាញ់របស់ពួកមនុស្សៗ គេទើបប្លែងភេទជាតាបស ថ្វាយបង្គំលាព្រះមាតា ហើយគេចចេញទៅៗ ឯភូរិទត្តពោធិសត្វនោះ មាននាងនាគប្អូនស្រីផ្សេងមាតាម្នាក់ឈ្មោះអច្ចិមុខីៗ នាងអច្ចិមុខីនោះ ស្រឡាញ់ព្រះពោធិសត្វជាពន់ពេក នាងឃើញសុទស្សនៈទៅទើបស្រែកសុំថា បពិត្រម្ចាស់បង ប្អូនលំបាកចិត្តក្រៃពេក ប្អូនសូមទៅជាមួយនឹងម្ចាស់បងដែរ សុទស្សនៈពោលថា ម្នាលប្អូនស្រីមិនអាចទៅជាមួយនឹងបងបានទេ បងនឹងទៅដោយភេទជាបព្វជិតៗ អច្ចិមុខីពោលថា បពិត្រម្ចាស់បង ប្អូនស្រីនឹងក្លាយជាកង្កែបតូចមួយ ដេកនៅក្នុងជដា(ផ្នួងសក់)របស់លោកបងៗ សុទស្សនៈពោលថា បើដូច្នោះចូរមកទៅជាមួយគ្នាចុះៗ នាងអច្ចិមុខីទើបប្លែងជាកូនកង្កែបតូចដេកនៅក្នុងជដារបស់បង សុទស្សនៈគិតថា យើងនឹងល្បងសាកសួរតាំងអំពីដើមទៅដូច្នេះហើយ ទើបសួរដល់កន្លែងៗ ដែលព្រះភូរិទត្តបានទៅរក្សា

ឧបោសថនឹងកិរិយាព្រះកុរិទត្តជាមុនហើយ ទើបទៅក្នុងទីនោះឯង ឃើញឈាម និងកន្ទែងចាក់កន្ទ្រក ដែលធ្វើដោយវល្លិ ក្នុងទីកន្ទែង អាលម្ពាយន៍ចាប់ព្រះបរមពោធិសត្វ ដឹងច្បាស់ថា ហ្លួងសចាប់ កុរិទត្តទៅ ក៏កើតសេចក្ដីសោកឡើងភ្លាមមានភ្នែកពេញទៅដោយ ទឹកភ្នែក ទើបដើរតាមស្នាមអាលម្ពាយន៍រហូតទៅដល់ស្រុកដែល អាលម្ពាយន៍ឲ្យព្រះកុរិទត្តលេងគ្រាដំបូង ទើបសួរពួកមនុស្សថា ហ្លួងសយកនាគរាជឈ្មោះបែបនេះ មកលេងក្នុងស្រុកនេះខ្លះឬទេ? មនុស្សឆ្លើយថា អាលម្ពាយន៍យកនាគរាជបែបនេះមកលេង តាំង អំពីនោះរហូតដល់ថ្ងៃនេះប្រមាណជាមួយខែហើយ។ សុទស្សនៈ សួរថា ហ្លួងសនោះបានអ្វីខ្លះទេ? មនុស្សឆ្លើយថា ត្រង់ស្រុកនេះ ហ្លួងសបានទ្រព្យប្រមាណមួយពាន់កហាបណៈ។ សុទស្សនៈសួរ ថា ឥឡូវនេះហ្លួងសទៅណា? មនុស្សឆ្លើយថា ហ្លួងសទៅស្រុក ឈ្មោះនោះ។ សុទស្សនៈសួររឿយៗទៅតាំងតែអំពីស្រុកនោះរហូត ដល់ទ្វារព្រះរាជវាំង។



ចប់វិលាបកណ្ឌ

ខណៈនោះអាលម្ពាយន៍ផ្លូតទឹកកក់សីសៈលាបរបស់ក្រអូប ស្លៀកដណ្ដប់ សំពត់សាច់រលោងហើយ ឲ្យមនុស្សលើកកន្ត្រកកែវទៅកាន់ទ្វារព្រះរាជវាំង។ មហាជនក៏ប្រជុំគ្នា ព្រះរាជាសនៈក៏រៀបចំទុកព្រមស្រេចហើយ។ ព្រះរាជានោះ ស្ដេចនៅខាងក្នុងនិវេសន៍ទ្រង់បញ្ជូនសាសន៍ទៅថា យើងនឹងមើល សូមអាលម្ពាយន៍ចូរឲ្យនាគរាជលេងទៅចុះ។ អាលម្ពាយន៍ទើបដាក់កន្ត្រកកែវចុះខាងលើគ្រឿងកម្រាលដ៏វិចិត្រ បើកកន្ត្រកចេញហើយឲ្យសញ្ញាថា សូមមហានាគចេញមកចុះ។ សម័យនោះសុទស្សនៈក៏ទៅឈរខាងចុងបរិស័ទទាំងពួង ព្រះបរមពោធិសត្វងើបក្រឡេកមើលបរិស័ទទូទៅ នាគទាំងឡាយក្រឡេកមើល បរិស័ទដោយអាការៈពីរយ៉ាងគឺ ដើម្បីនឹងមើលអន្តរាយអំពីគ្រុឌម្យ៉ាង ដើម្បីនឹងមើលពួកញាតិម្យ៉ាង។ នាគពួកនោះកាលឃើញគ្រុឌក៏ខ្លាចមិនរាំ កាលឃើញពួកនាគក៏អៀនខ្មាស់មិនរាំ។ ចំណែកព្រះបរមពោធិសត្វកាលក្រឡេកទៅឃើញបងប្រុសក្នុងចន្លោះបរិស័ទ លោកក៏លូនវារចេញអំពីកន្ត្រកតម្រង់ទៅរកបងប្រុស ទាំងដែលទឹកភ្នែកពេញព្រះកក្ត្រ។ មហាជនឃើញព្រះភូរិទត្តវារក៏នាំគ្នាស្ទុតចិត្ត គេបចេញ

ទៅៗ នៅឈរតែសុទស្សនៈម្នាក់គត់ព្រះភូរិទត្តទៅជប់សីសៈស្រែក យំនៅត្រង់ខ្នងជើងរបស់សុទស្សនៈ ចំណែកសុទស្សនៈក៏ស្រែក យំៗ ព្រះបរមពោធិសត្វស្រែកយំហើយ ក៏ត្រឡប់មកចូលក្នុង កន្ត្រកវិញ អាលម្ពាយន៍យល់ថាតាបសត្រូវនាគនេះចឹក គិតនឹង លួងលោមលោក ទើបចូលទៅរកសុទស្សនៈ ហើយពោលថា :

៩១. ហត្ថា បមុត្តោ ឧរគោ ចាទេ តេ និបតី ភុសំ
កច្ចិ នុ តំ ឌំសិតោ តាត មា ភាយិ សុខិតោ ភវ។

នាគដែលរួចអំពីដៃ(របស់យើង)ក្រាបចុះលើជើងលោកយ៉ាង ខ្លាំង លោកត្រូវពស់ចឹកឬ លោកកុំខ្លាចឡើយ ចូរដល់សេចក្តី សុខចុះៗ

សុទស្សនទាគរាជពោលថា :

៩២. នេវ មយ្ហំ អយំ នាគោ អលំ ទុក្ខាយ កាយចិ
យាវតត្ថិ អហិគ្គាហោ មយា ភិយ្យោ ន វិជ្ជតិ។

នាគនេះមិនអាចឲ្យទុក្ខណាមួយដល់អាត្មាទេ អ្នកចាប់ពស់ មានទាំងប៉ុន្មាន មិនមែនមានច្រើនជាងអាត្មាទេៗ

អាលម្ពាយន៍កាលមិនស្គាល់ថា អ្នកនេះ គឺអ្នកណា ក៏ក្រោធខឹងពោលថា :

៥៣. កោនុ ព្រាហ្មណវណ្ណេន   ទេត្តោ បរិសមាគតោ

អវ្ហាយន្តុ សុយុទ្ធេន   សុណន្តុ បរិសា មម។

អ្នកណាហ្នឹ៎ភ្ញីភ្ញើ មានភេទដូចជាភេទព្រាហ្មណ៍ មកកាន់បរិស័ទ ហើយហៅ(អញ)ច្បាំង បរិស័ទចូរស្តាប់ពាក្យរបស់យើងចុះ។

សុទស្សនទាគរាជពោលថា :

៥៤. ត្វំ មំ នាគេន អាលម្ព   អហំ មណ្ឌូកឆាបិយា

ហោតុ នោ អព្ភុតំ តត្ថ   អាសហស្សេហិ បញ្ចហិ។

ម្នាលអាលម្ពាយន៍ អ្នកច្បាំងនឹងយើងដោយនាគ យើងក៏ច្បាំងនឹងអ្នកដោយកូនកង្កែបដែរ ការភ្នាល់ក្នុងចម្បាំងនោះ ចូរមានដល់យើងដោយកហាបណៈ៥.០០០ជាកំណត់។

អាលម្ពាយនព្រាហ្មណ៍ពោលថា :

៥៥. អហញ្ហិ វសុមា អឌ្ឍោ   ត្វំ ទលិទ្ទោសិ មាណវ

កោ នុ តេ ចាដិភោគត្ថិ   ឧបជូតញ្ច កឹ សិយា។

ឧបជ្ឈតញ្ញ មេ អស្ស ចាជិភោគោ ច តាទិសោ
ហោតុ នោ អត្ថតំ តត្ថ អាសហាសេស្សហិ បញ្ញហិ។

ម្នាលមាណព យើងជាអ្នកមានទ្រព្យស្តុកស្តម្ភ អ្នកឯងជាអ្នកទាល់ក្រ តើបុគ្គលណាជាអ្នកជានាអ្នក យ៉ាងទៀតទ្រព្យដម្កល់ទុកក្នុងការភ្នាល់មានដែរឬ។ ទ្រព្យដម្កល់ទុកក្នុងការភ្នាល់របស់យើងមានទាំងបុគ្គលជាអ្នកធានា ប្រាកដដូច្នោះក៏មានដែរ ការភ្នាល់ក្នុងចម្បាំងនោះ ចូរមានដល់យើង ដោយកហាបណៈ៥.០០០ ជាកំណត់។

សុទស្សនៈកាលបានស្តាប់ពាក្យរបស់អាលម្ពាយន៍នោះហើយមិនក្លាហាន អះអាងថា ណ្ហើយចុះភ្នាល់គ្នាដោយទ្រព្យ៥.០០០ កហាបណៈដូច្នេះ ក៏ឡើងកាន់ព្រះរាជនិវេសន៍ ទៅគាល់ព្រះចៅក្រុងពារាណសីដែលត្រូវជាអ៊ុំ ហើយពោលគាថាដូច្នេះថា :

៨៦. សុណោហិ មេ មហារាជ វចនំ ភទ្ទមត្ថុ តេ
បញ្ចន្នំ មេ សហស្សានំ ចាជិភោគោ ហិ កិត្តិមា។

បពិត្រមហារាជ សូមព្រះអង្គទ្រង់ព្រះសណ្ដាប់ពាក្យអាត្មាភាព សេចក្ដីចម្រើនចូរមានដល់ព្រះអង្គ ព្រះអង្គមានកិត្តិគុណ សូមព្រះអង្គជានាដោយកហាបណៈ៥.០០០របស់អាត្មាភាពផង។

ព្រះរាជាទ្រង់ត្រិះរិះថា តាបសនេះសុំទ្រព្យយើងច្រើនក្រៃពេក ទើបត្រាស់គាថាដូច្នេះថា :

៥៧. បេត្តិកំ វា ឥណំ ហោតិ  យំ វា ហោតិ សយំ កតំ
កឹ ត្វំ ឯវំ ពហុំ មយ្ហំ  ធនំ យាចសិ ព្រាហ្មណ។

នែ៎!ព្រាហ្មណ៍ បំណុលជារបស់បិតា ឬថាខ្ញុំជំពាក់ដោយខ្លួនឯង បានជាអ្នកទារយកទ្រព្យរបស់យើងច្រើន តើព្រោះហេតុអ្វី។

សុទស្សនទាគរាជពោលថា :

៥៨. អាលម្ពាយនោ ហិ នាគេន  មមំ អភិជិគីសតិ
អហំ មណ្ឌូកនាបិយា  ឱសយិស្សាមិ ព្រាហ្មណំ។
តំ ត្វំ ទដ្ឋុំ មហារាជ  អដ្ឋ រដ្ឋាភិវឌ្ឍន
ខត្តសង្ឃបរិព្យូឡ្ហោ  នីយាហិ អហិទស្សនំ។

ដ្បិតអាលម្ពាយនព្រាហ្មណ៍ ផ្ចាញ់អាត្មាភាពដោយនាគ អាត្មាភាពនឹងញ៉ាំងកូនកង្កែបឲ្យខាំព្រាហ្មណ៍ៗ បពិត្រមហារាជ ញ៉ាំងដែនឲ្យចម្រើន ព្រោះហេតុនោះ សូមព្រះអង្គមានពួកអ្នកកាន់ព្រះខ័នហែហម យាងទៅដើម្បីទតពស់ដែលគួរទតៗ

ព្រះរាជាត្រាស់ថា បើដូច្នោះយើងនឹងទៅ ទើបស្ដេចទៅព្រមជាមួយតាបសនោះឯងៗ អាលម្ពាយន៍ឃើញព្រះរាជាស្ដេចមកជាមួយតាបសក័យខ្លាចថា តាបសនេះទៅយាងព្រះរាជាចេញមកប្រហែលជានឹងជាបព្វជិតក្នុងព្រះរាជតំណាក់ កាលនឹងបណ្ដោយតាម ទើបពោលគាថាដូច្នេះថា :

៥៩. នេវ តំ អតិមញ្ញាមិ សិប្បវាទេន មាណវ
អតិមត្តោសិ សិប្បេន ឧរគំ នាបចាយសិ ។

ម្នាលមាណព ខ្ញុំមិនមើលងាយអ្នកដោយសិប្បវាទទេ ចំណែកអ្នកមើលងាយខ្ញុំដោយសិប្ប: បានជាមិនកោតក្រែងនាគៗ

សុទស្សនះពោលថា :

៦០. អហម្បិ នាតិមញ្ញាមិ សិប្បវាទេន ព្រាហ្មណ

អវិសេន ច នាគេន ភុសំ វញ្ចយសេ ជនំ។
ឯវញ្ចេតំ ជនោ ជញ្ញា យថា ជានាមិ តំ អហំ
ន ត្វំ លភសិ អាលម្ព ថុសមុដ្ឋី កុតោ ធនំ។

នែ៎ព្រាហ្មណ៍ អាត្មាក៏មិនមើលងាយអ្នកដោយសិប្បវាទទេ តែអ្នកបញ្ឆោតជនច្រើន ដោយនាគដែលមិនមានពិស។ អាត្មាដឹងអ្នកយ៉ាងណា ជនក៏ត្រូវដឹងអ្នកយ៉ាងនោះដែរ ម្នាលអាលម្ពាយន៍ អ្នកមិនបានអង្កាមមួយក្តាប់ នឹងបានទ្រព្យអំពីណា។

អាលម្ពាយន៍ពោលថា :

៦១. ខរាជិនោ ជដី ទុម្មី ទត្តោ បរិសមាគតោ
យោ ត្វំ ឯវំ គតំ នាគំ អវិសោ អតិមញ្ញសិ។
អាសជ្ជ ខោ នំ ជញ្ញាសិ បុណ្ណំ ឧគ្គស្ស តេជសា
មញ្ញេ តំ ភស្មរាសីវ ខិប្បមេសោ ករិស្សតិ។

អ្នកស្លៀកដណ្តប់ស្បែកខ្លាទាំងក្រចក មានផ្នួងសក់ ជាមនុស្សកខ្វក់ភ្លីភ្លើ មកកាន់បរិស័ទ ហើយមើលងាយនាគបែបនេះថា មិន

មានពិស អ្នកចូលមក ហើយគង់នឹងជីងនាគនោះ ដែលពេញដោយតេជះរបស់នាគដ៏ខ្លាំងខ្លាស់ ខ្ញុំសម្គាល់ថា នាគនុ៎ះនឹងធ្វើអ្នកឲ្យដូចជាគំនរផេះយ៉ាងឆាប់ៗ

សុទស្សនៈពោលថា :

៦២. សិយា វិសំ សិលុត្តស្ស ធុទ្ទុភស្ស សិលាភុនោ
ནេវ លោហិតសីសស្ស វិសំ នាគស្ស វិជ្ជតិ ។

ពិសនៃពស់ផ្ទះ ពស់ទឹក ពស់ខៀវគ្រាន់មានខ្លះ ឯពិសនៃនាគមានក្បាលក្រហម មិនមានសោះឡើយៗ

អាលម្ពាយន៍ពោលថា :

៦៣. សុតមេតំ អរហតំ សញ្ញតានំ តបស្សិនំ
ឥធ ទានានិ ទត្វាន សគ្គំ គច្ឆន្តិ ទាយកា
ជីវន្តោ ទេហិ ទានានិ យទិ តេ អត្ថិ ទាតវេ ។
អយំ នាគោ មហិទ្ធិកោ តេជសី ទុរតិក្កមោ
តេន តំ ឌំសយិស្សាមិ សោ តំ ភស្មំ ករិស្សតិ ។

ខ្ញុំបានស្តាប់ពាក្យនេះរបស់ពួកព្រះអរហន្ត ដែលសង្រួមហើយ មានតបៈ ថាទាយកទាំងឡាយក្នុងលោកនេះ ឲ្យទានទាំងឡាយ រមែងទៅកាន់ឋានសួគ៌ ថាបើមានវត្ថុតិចតួចដែលគួរឲ្យ អ្នកទាន់នៅរស់ ចូរឲ្យទានទាំងឡាយចុះៗ នាគនេះមានឫទ្ធិច្រើន មានតេជៈ ដែលគេកន្លងបានដោយក្រ ខ្ញុំនឹងប្រើនាគនេះឲ្យបឹកអ្នក នាគនោះ នឹងធ្វើអ្នកឲ្យជាផេះៗ

សុទស្សនៈពោលថា :

៦៤. មយាបេតំ សុតំ សម្ម សញ្ញតានំ តបស្សិនំ
ឥធ ទានានិ ទត្វាន សគ្គំ គច្ឆន្តិ ទាយកា
ត្វមេវ ទេហិ ជីវន្តោ យទិ តេ អត្ថិ ទាតវេ។
អយំ អច្ចិមុខិ នាម បុណ្ណា ឧគ្គស្ស តេជសា
តាយ តំ ឌំសយិស្សាមិ សា តំ ភស្មំ ករិស្សតិ។
យា ធីតា ធតរដ្ឋស្ស វេមាតា ភគិនី មម
សា ឌំសតុ អច្ចិមុខី បុណ្ណា ឧគ្គស្ស តេជសា។

ម្នាលសម្លាញ់ ខ្ញុំក៏បានស្តាប់ពាក្យនេះ របស់ពួកព្រះអរហន្ត

ដែលសង្រួម ហើយមានតបៈថា ទាយកទាំងឡាយក្នុងលោកនេះ ឲ្យទានទាំងឡាយ រមែងទៅឋានសួគ៌ ថាបើអ្នកមានវត្ថុតិចតួច ដែលគួរឲ្យ អ្នកទាន់នៅរស់ ចូរឲ្យទានទាំងឡាយចុះ។ កូនកង្អែប នេះឈ្មោះអច្ចិមុខី ពេញដោយតេជៈរបស់ពស់ដ៏ខ្ពង់ខ្ពស់ អាត្មានឹង ប្រើនាងអច្ចិមុខីនោះឲ្យខាំអ្នក នាងអច្ចិមុខីនោះនឹងធ្វើឲ្យអ្នកទៅជា ផេះ។ នាងអច្ចិមុខីនោះជាធីតារបស់ព្រះបាទធតរដ្ឋៈ មានមាតាផ្សេង គ្នា ជាប្អូនស្រីរបស់អាត្មា ដ៏ពេញដោយតេជៈរបស់ពស់ដ៏ខ្ពង់ខ្ពស់ ចូរខាំចុះ។

ក៏ឯសុទស្សនៈ កាលពោលយ៉ាងនេះហើយទើបលាតដៃ ស្រែកហៅប្អូនស្រី ក្នុងកណ្ដាលមហាជននោះឯង ដោយពាក្យថា ម្នាលប្អូនស្រីអច្ចិមុខី ចូរចេញអំពីខាងក្នុងជដារបស់បងមកឈរ នៅក្នុងបាទដៃរបស់បង។

នាងអច្ចិមុខីអង្គុយនៅខាងក្នុងជដានោះឯង បានឮសម្លេងហៅ របស់សុទស្សនៈបងប្រុស ញុំាងភ្លៀងកូនកង្អែបឲ្យធ្លាក់ដល់បីដង ហើយ ទើបចេញអំពីខាងក្នុងជដា អង្គុយត្រង់ចន្លោយស្មា លោតអំពី

នោះឈរនៅខាងលើបាទដៃរបស់សុទស្សនៈបងប្រុស ហើយធ្វើតំណក់ពិស៣ដំណក់ ឲ្យធ្លាក់ ហើយចូលទៅខាងក្នុងជដារបស់សុទស្សនៈទៀតដូចដើម។ សុទស្សនៈឈរកាន់ពិស ហើយប្រកាសសម្លេងខ្លាំងៗឡើងថា អ្នកជនបទនឹងវិនាសធំ។ សម្លេងរបស់សុទស្សនៈ បានឮគ្របដណ្តប់នគរពារាណសីរហូត១២យោជន៍។ លំដាប់នោះ ព្រះរាជាទើបទ្រង់ត្រាស់សួរគេថា ជនបទនឹងវិនាសព្រោះហេតុអ្វី? សុទស្សនៈពោលថា បពិត្រមហារាជ អាត្មាមិនឃើញកន្លែងដាក់ដំណក់របស់ពិសនេះទេ។ ព្រះរាជាត្រាស់ថា លោកចូរសម្រក់ពិសត្រង់ផែនដីធំចុះ។ លំដាប់នោះសុទស្សនៈ កាលនឹងហាមព្រះរាជាថា អាត្មាភាពមិនអាចសម្រក់ពិសខាងលើផែនដីធំនោះបានទេមហាបពិត្រ ទើបពោលគាថាដូច្នេះថា :

៦៨. ឆមាយំ ចេ និសិញ្ចិស្សំ ព្រហ្មទត្ត វិជានាហិ
តិណលតានិ ឱសធ្យោ ឧស្សុស្សេយ្យុំ អសំសយំ ។

បពិត្រព្រះអង្គ ព្រះនាមព្រហ្មទត្ត សូមទ្រង់ជ្រាបចុះ បើអាត្មាភាពសាចពិសទៅលើផែនដី ស្មៅ វល្លិ ពួកឈើជាឱសថ

នឹងស្ងិតស្រពោនគ្មានសល់។

សុទស្សនៈ កាលនឹងសម្ដែងថា ដល់ក្នុងអាកាសនោះក៏មិនអាចសាចពិសនោះទៅបានឡើយ ទើបពោលគាថាដូច្នេះថា :

៦៦. ឧទ្ធំ ចាគយិស្សាមិ ព្រហ្មទត្ត វិជានាហិ
សត្ត វស្សានិ យំ ទេវោ ន វស្សេ ន ហិមំ បតេ។

បពិត្រព្រះអង្គ ព្រះនាមព្រហ្មទត្ត សូមទ្រង់ជ្រាបចុះ បើអាត្មាភាពសាចពិសទៅខាងលើ ភ្លៀងនឹងមិនបង្អុរចុះ ទឹកសន្សើមនឹងមិនធ្លាក់ចុះអស់៧ឆ្នាំ។

ព្រះរាជាត្រាស់ថា ម្នាលបា បើដូច្នោះបាចូរសាចពិសចូលទៅក្នុងទឹក។ សុទស្សនៈកាលនឹងសម្ដែងថា សូម្បីក្នុងទឹកនោះក៏សាចពិសចុះទៅមិនបាន ទើបពោលគាថាដូច្នេះថា :

៦៧. ឧទកេ ចេ និសិញ្ចិស្សំ ព្រហ្មទត្ត វិជានាហិ
យាវន្តោទកជា បាណា មរេយ្យុំ មច្ឆកច្ឆបា។

បពិត្រព្រះអង្គ ព្រះនាមព្រហ្មទត្ត សូមទ្រង់ជ្រាបចុះ បើអាត្មាភាពសាចពិសទៅក្នុងទឹក ត្រីនិងអណ្ដើក ដែលជាសត្វកើត

ក្នុងទឹកទាំងប៉ុន្មាន នឹងស្លាប់ទាំងអស់ៗ

លំដាប់នោះព្រះរាជាត្រាស់នឹងសុទស្សនៈថា ម្នាលបាខ្ញុំមិនដឹងអ្វីទេ អ្នកចូរជួយរកឧបាយ ដែលនឹងមិនឲ្យដែនរបស់យើងវិនាសផងចុះៗ សុទស្សនៈក្រាបទូលថា បពិត្រមហារាជ បើដូច្នោះមហារាជចូរបង្គាប់ឲ្យមនុស្សជីកអណ្តូង បីតៗគ្នានៅក្នុងទីកន្លែងនេះៗ ព្រះរាជាបង្គាប់ឲ្យគេជីកអណ្តូងហើយ សុទស្សនៈទើបដាក់អណ្តូងដំបូងឲ្យពេញដោយថ្នាំផ្សេងៗ អណ្តូងទីពីរឲ្យដាក់អាចម៍គោ និងអណ្តូងទីបីឲ្យដាក់ថ្នាំទិព្យ ហើយទើបដាក់ដំណក់ពិសចុះក្នុងអណ្តូងទីមួយ ខណៈនោះឯង ក៏កើតផ្សែងភ្លើងឆេះឡើងជាអណ្តាត ហើយឆាបទៅឆេះអណ្តូងអាចម៍គោ ហើយឆេះឆាបតទៅរហូតដល់អណ្តូងថ្នាំទិព្យ ឆេះថ្នាំទិព្យអស់ហើយ ទើបរលត់ៗ អាលម្ពាយន៍ឈរនៅជិតអណ្តូង លំដាប់នោះផ្សែងពិសឆាបយកសម្បុរពងកាយរបកឡើងទៅអស់ៗ បានក្លាយជាពេកពពាលអាលម្ពាយន៍តក់ស្លុតខ្លាច ទើបបញ្ចេញសម្លេងឡើងបីដងថា ខ្ញុំពន្លែងនាគរាជហើយ ព្រះពោធិសត្វបានឮដូច្នោះ ទើបចេញអំពី

កន្ទ្រកកែវនេរមិត្តអត្តភាព ដែលប្រដាប់ដោយគ្រឿងអលង្ការទាំងពួង ឈរនៅដោយអាកប្បកិរិយាដូចទេវរាជ។ ទាំងសុទស្សនៈ ទាំងអច្ចិមុខី ក៏មកឈរដូចព្រះពោធិសត្វនោះឯង។ លំដាប់នោះសុទស្សនៈទើបទូលសួរព្រះបាទក្រុងពារាណសីថា បពិត្រមហារាជ ព្រះអង្គទ្រង់ស្គាល់ខ្ញុំព្រះអង្គ ទាំងបីនាក់នេះជាកូនអ្នកណាដែរឬទេ? ព្រះរាជាទ្រង់ឆ្លើយថា ម្នាលបាយើងមិនស្គាល់ទេ សុទស្សនៈនិយាយថា ព្រះអង្គទ្រង់មិនស្គាល់ខ្ញុំទាំងបីនាក់ ចូរលើកទុកសិនចុះ តែព្រះអង្គទ្រង់ជ្រាបរឿងដែលលើកនាងសមុទ្ទជា ជារាជធីតាព្រះចៅក្រុងកាសី បានព្រះរាជទានដល់ស្ដេចធតរដ្ឋដែរទេ? ព្រះរាជាមានព្រះរាជឱង្ការថា អើយើងដឹង នាងសមុទ្ទជាជាប្អូនស្រីបង្កើតរបស់យើង។

សុទស្សនៈនិយាយថា បពិត្រមហារាជ ខ្ញុំទាំងបីនាក់នេះជាកូនរបស់ព្រះនាងសមុទ្ទជា ព្រះអង្គជាព្រះបិតុលារបស់ខ្ញុំទាំងបីនាក់។ ព្រះរាជាទ្រង់បានស្ដាប់ដូច្នោះ ក៏ទ្រង់ចុម្ពិត(ថើប)ក្មួយទាំងបីបណ្ដើរ ទ្រង់ព្រះកន្សែង(យំ) ហើយនាំឡើងលើប្រាសាទ ទ្រង់

ធ្វើសក្ការៈជាច្រើន ហើយទ្រង់ធ្វើបដិសណ្ឋារៈ រួចត្រាស់សួរថា ម្នាលភូរិទត្ត ឰបាមានឫទ្ធិតេជៈខ្ពង់ខ្ពស់យ៉ាងនេះ ហេតុអ្វីក៏អាលម្ពាយន៍អាចចាប់បាន។ ព្រះភូរិទត្តទើបទូលរឿងនោះដោយពិស្ដារ ហើយ កាលនឹងថ្វាយឱវាទព្រះរាជា ទើបសម្ដែងព្រះរាជធម៌ដល់ព្រះបិតុលា ដោយន័យមានជាអាទិ៍ថា សូមព្រះអង្គព្រះរាជទានទទួលយកនូវធម្មទំនៀម, ព្រះរាជាគួរនឹងតាំងនៅក្នុងរាជសម្បត្តិដោយទំនងយ៉ាងនេះ។

លំដាប់នោះសុទស្សនៈ ទើបក្រាបទូលព្រះរាជាថា បពិត្រព្រះបិតុលា មាតារបស់ខ្ញុំព្រះអង្គនៅមិនទាន់ជួបភូរិទត្ត ក៏នឹងទុក្ខព្រួយ ខ្ញុំព្រះអង្គមិនអាចនៅយូរបានទេក្រាបទូល។

ព្រះរាជាទ្រង់ត្រាស់ថា សាធុ! ឰបាចូរនាំគ្នាទៅសិនចុះ តែថាអ៊ំចង់ជួបប្អូនស្រីរបស់យើងដែរ ធ្វើយ៉ាងណាទើបនឹងបានជួបគ្នា។ សុទស្សនៈនិយាយថា បពិត្រព្រះបិតុលា ព្រះបាទកាសិករាជជាព្រះអយ្យិការបស់ខ្ញុំព្រះអង្គ ឥឡូវនេះនៅទីណា។ ព្រះរាជាទ្រង់ត្រាស់ថា ម្នាលឰបា ព្រះបាទកាសិករាជនោះត្រូវព្រាត់ប្រាស់ចាក

ប្អូនស្រីរបស់បិតុលាហើយ មិនអាចនឹងនៅសោយរាជ្យសម្បត្តិបាន ក៏លះបង់រាជសម្បត្តិទ្រង់បួស ហើយព្រះរាជាស្ដេចទ្រង់ទៅគង់នៅក្នុងសណ្ឌ:(ព្រៃស្ដុក)កន្លែងនោះ។

សុទស្សនៈនិយាយថា បពិត្រព្រះបិតុលា មាតារបស់ខ្ញុំព្រះអង្គប្រាថ្នានឹងចង់ជួបព្រះបិតុលា និងព្រះអយ្យកាដែរ ដល់ថ្ងៃនោះព្រះអង្គស្ដេចយាងទៅកាន់ សម្នាក់ព្រះអយ្យកា ខ្ញុំព្រះអង្គនឹងនាំមាតាទៅកាន់អាស្រមព្រះអយ្យកា ព្រះបិតុលានឹងបានជួបព្រះមាតារបស់ទូលព្រះបង្គំនៅក្នុងទីនោះឯង។ ដូច្នោះអ្នកទាំងបីនាក់ទើបកំណត់ណាត់ថ្ងៃដែលព្រះបិតុលាហើយ ចេញអំពីព្រះរាជនិវេសន៍ព្រះរាជា ទ្រង់បញ្ជូនព្រះរាជភាគិនេយ្យទៅហើយ ក៏ទ្រង់ព្រះកន្សែងហើយត្រឡប់មកវិញ ក្មួយទាំងបីនាក់ក៏ជ្រកផែនដីចុះទៅកាន់នាគពិភព។



ចប់ឆាគវេសនកណ្ឌ

កាលព្រះបរមពោធិសត្វដល់ពិភពនាគ សម្ដេងយំរៀបរាប់ក៏កើតឡើងព្រមគ្នា ចំណែកព្រះភូរិទត្តនឿយហត់ព្រោះចូលនៅក្នុងកន្ទ្រកអស់មួយខែ ទើបដេកគ្រេន មានពួកនាគមកសួរសុខទុក្ខមិនដាច់ៗ ព្រះភូរិទត្តនឿយហត់ ព្រោះប្រាស្រ័យជាមួយនឹងនាគពួកនោះៗ កាណារិដ្ឋៈ ដែលទៅកាន់ទេវលោក កាលមិនជួបព្រះបរមពោធិសត្វក៏ត្រឡប់មកមុនៗ លំដាប់នោះញាតិមិត្តរបស់ព្រះបរមពោធិសត្វ ឃើញថា កាណារិដ្ឋៈនោះ ជានាគកាចគ្រោតគ្រាតអាចនឹងហាមនាគបរិស័ទបាន ទើបឲ្យកាណារិដ្ឋៈជាអ្នក យាមទ្វារបន្ទប់បន្ទំរបស់ព្រះពោធិសត្វៗ ចំណែកសុភោគៈដែលត្រាច់ទៅកាន់ហេមពាន្តអំពីនោះ ទើបត្រួតត្រាតទៅតាមរកឯមហាសមុទ្ទនិងស្ទឹងក្រៅនោះហើយ ត្រួតមើលមកដល់ស្ទឹងយមុនាៗ

ចំណែកព្រាហ្មណ៍នេសាទឃើញអាលម្ពាយន៍កើតរោគឃ្លង់ទើបគិតថា ព្រាហ្មណ៍នេះធ្វើភូរិទត្តឲ្យលំបាក ទើបកើតជារោគឃ្លង់ៗ ចំណែកឯតាព្រាហ្មណ៍ ក៏ជាមនុស្សបង្អុលប្រាប់ភូរិទត្តអ្នកមានគុណច្រើនឲ្យដល់អាលម្ពាយន៍ ដោយចង់បានកែវមណី

កម្មអាក្រក់នោះគង់នឹងមកដល់យើងជាមិនខាន, យើងនឹងទៅកាន់ស្ថានយមុនារហូតពេលដែលកម្មនោះនៅមិនទាន់មកដល់ ហើយនឹងធ្វើពិធីបណ្តេតបាបត្រង់កំពង់បយាគៈ គេទើបទៅត្រង់កំពង់ទឹកបយាគៈ ហើយពោលថា យើងបានធ្វើកម្មប្រទូសរ៉ាយព្រះគុរុទត្តដែលជាមិត្រដ៏ល្អរបស់យើង, យើងនឹងបណ្តេតបាបនោះចោលដូច្នេះហើយទើបធ្វើពិធីចុះទឹកលាងបាបតាមពិធីរបស់ព្រាហ្មណ៍។

ខណៈនោះឯងសុកោគៈទៅដល់ទីនោះដែរ បានឮពាក្យរបស់ព្រាហ្មណ៍នេសាទនោះ ទើបគិតថា បានឮថា តានេះបាបក្រាស់ណាស់, បងប្រុសរបស់យើងឲ្យយសសក្តិវាច្រើនហើយ ត្រឡប់ជាទៅប្រាប់ឲ្យហ្មព្រាន់ ព្រោះចង់បានកែវមណី យើងយកជីវិតវាចុះ។ ដូច្នេះហើយ ទើបយកកន្ទុយព័ន្ធជើងព្រាហ្មណ៍ទាំងពីរខាងអូសឲ្យលិចចុះទៅក្នុងទឹកល្មមជិតនឹងដាច់ខ្យល់ទើបបន្ធូរបន្តិច។ ល្មមព្រាហ្មណ៍ងើបក្បាលឡើងបាន ក៏ត្រឡប់អូសឲ្យលិចចុះទៅទៀត ទូន្មានឲ្យលំបាកយ៉ាងនេះច្រើនដង ព្រាហ្មណ៍នេសាទងើបក្បាលឡើងបាន ទើបពោលគាថាដូច្នេះថា :

៦៨. លោកំ្យ សជន្តំ ឧទកំ  បយាគស្មឹ បតិដ្ឋិតំ
កោ មំ អជ្ឈោហរី ភូតោ ឱគាឡ្ហំ យមុនំ នទិ។

ទឹកដែលតាំងនៅក្នុងកំពង់បយាគៈ ដែលអញកំពុងស្រោចជាទឹកដែលលោកសន្មតថា សម្រាប់លាងបាប ចុះខ្មោចអ្វីជ្រមុជអញឲ្យចុះទៅក្នុងទឹកស្ទឹងយមុនាដ៏ជ្រៅ។

លំដាប់នោះ សុភោគៈបានពោលនឹងព្រាហ្មណ៍នេសាទនោះដោយគាថាដូច្នេះថា:

៦៩. យទេស លោកាធិបតី យសស្សី
ពារាណសឹ បក្ករិយាហរី សមន្តតោ
តស្សាហ បុត្តោ ឧរគូសភស្ស
សុភោគោតិ មំ ព្រាហ្មណ វេទយន្តិ។

នាគណាជាធំក្នុងលោក មានយសបានមកព័ទ្ធក្រុងពារាណសីដោយជុំវិញ អញជាកូននាគដ៏ប្រសើរនោះ ម្នាលព្រាហ្មណ៍ នាគទាំងឡាយហៅអញថា សុភោគៈដូច្នេះ។

លំដាប់នោះព្រាហ្មណ៍នេសាទ ទើបគិតថា នាគនេះជាបងប្អូនរបស់ព្រះភូរិទត្ត នឹងមិនទុកជីវិតយើងដូច្នោះឡើយ យើងនឹង

លើកកិត្តិគុណរបស់នាគនេះទាំងមាតា និងបិតារបស់នាគឲ្យចិត្តទន់ ហើយសុំជីវិតយើងទុកដូច្នេះ ទើបពោលគាថាដូច្នេះថា:

៧០. សចេសិ បុត្តោ ឧរគូសភស្ស
កាសិស្ស រញ្ញោ អមរាធិបស្ស
មហេសក្ខោ អញ្ញតរោ បិតា តេ
មច្ចេសុ មាតា បន តេ អតុល្យា
ន តាទិសោ អរហតិ ព្រាហ្មណស្ស
ទាសំបិ ឱហារិតុំ មហានុភាវោ ។

បើអ្នកជាកូននៃនាគដ៏ប្រសើរ ជាព្រះរាជាក្នុងដែនកាសី ជាធំជាងនាគ ដែលមានអាយុវែង បិតារបស់អ្នកជានាគមានស័ក្តិធំមួយដែរ បណ្តាសត្វទាំងឡាយ មាតារបស់អ្នកក៏មិនមានស្ត្រីណាផ្ទឹមបានឡើយ បុគ្គលមានអានុភាពច្រើនដូចអ្នក មិនគួរចាប់ជ្រមុជបុគ្គលសូម្បីជាទាសៈនៃព្រាហ្មណ៍ឡើយ។

លំដាប់នោះសុភោគៈ ទើបពោលនឹងព្រាហ្មណ៍នោះថា នែ៎អាតាព្រាហ្មណ៍អាក្រក់ សម្គាល់ថានឹងបោកបញ្ឆោតឲ្យយើងពន្លែងឬ

យើងនឹងមិនទុកជីវិតរបស់អ្នកឯងទេ  កាលនឹងប្រកាសកម្មដែលព្រាហ្មណ៍នោះធ្វើ ទើបពោលគាថាដូច្នេះថា :

៧៣. រុក្ខំ និស្សាយ វិជ្ឈិត្វា  ឯណេយ្យំ ចាតុមាគតំ
សោ វិទ្ធោ ទូរមាចរិ  សរវេគេន បេក្ខវា។
តំ ត្វំ បតិតមទ្ទក្ខិ  អរញ្ញស្មិំ ព្រហាវនេ
ស មំសកាជមាទាយ  សាយំ និគ្រោធុចាគមិ ។
សុវសាលិយសង្ឃុដ្ឋំ  បិង្គិយំ សណ្ឌតាយុតំ
កោកិលាភិរុទំ រម្មំ  ធុវំ ហរិតសទ្ទលំ ។
តត្ថ តេ សោ ចាតុរហុ  ឥទ្ធិយា យសសា ជលំ
មហានុភាវោ ភាតា មេ  កញ្ញាហិ បរិវារិតោ។
សោ តេន បរិចិណ្ណោ ត្វំ  សព្វកាមេហិ តប្បិតោ
អទុដ្ឋស្ស តុវំ ទុព្ភិ  តន្តេ វេរំ ឥធាគតំ។
ចិប្បំ គីវំ បសារេហិ  ន តេ ទស្សាមិ ជីវតំ
ភាតុ បរិសរំ វេរំ  ឆេទយិស្សាមិ តេ សិរំ។

ឯងអែបដើមឈើ  ហើយបាញ់ទ្រាយ  ដែលមកផឹក(ទឹក) ទ្រាយនោះ ដែលឯងបាញ់ហើយ  ក៏ងាកមើលដោយកម្លាំងនៃសរ

ក៏ស្ទុះទៅកាន់ទីឆ្ងាយៗ ឯងបានឃើញទ្រាយនោះ ដួលក្នុងព្រៃធំ ហើយ ក៏នាំសាច់មួយអម្រែក ចូលទៅកាន់ដើមជ្រៃ ក្នុងវេលាល្ងាច ជាឈើដែលគឺកកងដោយសត្វសេក និងសាលិកា មានស្លឹកលឿង ដេរដាសដោយពួរ ដែលសត្វតាវៅទំយំ ជាទីគួររីករាយ មានផែនដីដុះស្មៅខៀវជានិច្ច បងរបស់អញ ដែលមានអានុភាពច្រើន រុងរឿងដោយឫទ្ធិ និងយស ដែលពួកនាគកញ្ញាចោមរោមហើយ ក៏ប្រាកដដល់ឯងក្នុងទីនោះៗ ឯងនោះ ដែលបងរបស់អញនោះផ្តាប់ផ្គុនហើយ ឲ្យស្លាប់ស្លល់ដោយកាមទាំងពួង ឯងបានប្រទូស្តចំពោះបង ដែលមិនប្រទូស្ត ពៀរនោះមកដល់ឯងក្នុងទីនេះហើយៗ ឯងចូរជកកយ៉ាងឆាប់ អញនឹងមិនឲ្យជីវិតដល់ឯងទេ អញរឭកឃើញនូវពៀរ(ដែលឯងធ្វើ)ចំពោះបង អញនឹងកាត់ក្បាលឯងឥឡូវនេះៗ

លំដាប់នោះព្រាហ្មណ៍នេសាទទើបគិតថា នាគនេះឃើញថា នឹងមិនទុកជីវិតយើងពិត តែដូច្នោះយើងក៏គួរនឹងព្យាយាមពោលអ្វីៗដើម្បីឲ្យរួចទាល់តែបាន ទើបពោលគាថាដូច្នេះថា :

៧២. អជ្ឈាយកោ យាចយោគី អាហុតគ្គិ ច ព្រាហ្មណោ

ឃាតេហិ តីហិ ឋានេហិ    អវជ្ឈោ ភវតិ ព្រាហ្មណោ។

ព្រាហ្មណ៍ជាអ្នករៀនមន្ត១ ជាអ្នកប្រកបដោយការសូម១ ជាអ្នកបូជាភ្លើង១ ព្រាហ្មណ៍ប្រកបដោយហេតុទាំង៣នេះ អ្នកមិនគួរសម្លាប់ទេ។

សុភោគៈបានស្តាប់ដូច្នោះហើយ ក៏កើតសេចក្តីសង្ស័យ ទើបគិតថា យើងនាំព្រាហ្មណ៍នេះទៅកាន់នាគពិភពសាកសួរបងប្អូនមើល ក៏នឹងដឹងបានដូច្នេះ ទើបបានពោលគាថា ពីរគាថាដូច្នេះថា :

៧៣. យំ បុរំ ធតរដ្ឋស្ស    ឱគាឡ្ហំ យមុនំ នទឹ
ជោតតេ សព្វសោវណ្ណំ    គិរិមាហច្ច យាមុនំ។
តត្ថ តេ បុរិសព្យគ្ឃា    សោទរិយា មម ភាតរោ
យថា តេ តត្ថ វក្ខន្តិ    តថា ហេស្សសិ ព្រាហ្មណា។

បុរីណារបស់ព្រះបាទធតរដ្ឋៈ ជាវិការៈនៃមាសទាំងអស់ ដែលចូលទៅកាន់ស្ទឹងយមុនា ទល់នឹងភ្នំហិមពាន្ត ដែលនៅជិតស្ទឹងយមុនា រមែងរុងរឿង។ បងប្អូនរបស់អញទាំងនោះ ជាបុរសក្លៀវក្លា ជាអ្នករួមផ្ទៃ នៅក្នុងបុរីនោះ បងប្អូនទាំងនោះ ក្នុងបុរីនោះ និយាយយ៉ាងណា ឯងនឹងទៅជាយ៉ាងនោះ។

សុភោគៈកាលពោលដូច្នេះហើយ ទើបចាប់កព្រាហ្មណ៍ច្រាន ចេញទៅបណ្តើរ ជេរទៅបណ្តើរ រហូតដល់ទ្វារប្រាសាទរបស់ ព្រះពោធិសត្វ។



ចប់សុភោគកណ្ឌ

លំដាប់នោះ កាណារិដ្ឋៈអង្គុយយាមទ្វារ ឃើញសុភោគៈនាំព្រាហ្មណ៍នេសាទ ធ្វើទារុណកម្មមកដូច្នោះ ទើបដើរទៅប្រាប់ថា នែ៎បងសុភោគ បងកុំបៀតបៀន ព្រាហ្មណ៍នោះអី ព្រោះពួកដែលឈ្មោះថា ព្រាហ្មណ៍ក្នុងលោកនេះ ជាបុត្រស្តេចមហាព្រហ្ម បើស្តេចមហាព្រហ្មដឹង ក៏នឹងក្រេវក្រោធថា នាគពួកនេះបៀតបៀនសូម្បីកូនទាំងឡាយរបស់យើង ហើយនឹងធ្វើនាគពិភពទាំងអស់ឲ្យវិនាស ព្រោះពួកដែលឈ្មោះថា ជាព្រាហ្មណ៍ ជាបុគ្គលប្រសើរ និងមានអានុភាពច្រើនក្នុងលោក បងមិនដឹងអានុភាពរបស់ព្រាហ្មណ៍ពួកនោះទេ ចំណែកខ្ញុំដឹង បានឮមកថា កាណារិដ្ឋៈខ្ញុំនេះក្នុងភពជាលំដាប់ដែលកន្លងមក បានកើតជាព្រាហ្មណ៍បូជាយញ្ញ ព្រោះដូច្នោះទើបបានពោលយ៉ាងនេះ ក៏ឯគ្រាពោលហើយដោយអំណាចដែលខ្លួនធ្លាប់សោយមកក្នុងកាលមុន ទើបមានប្រក្រតីកប់នៅក្នុងការបូជាយញ្ញ ទើបហៅសុភោគ និងនាគបរិស័ទមកប្រាប់ថា ម្នាលអ្នកដ៏ចម្រើនទាំងឡាយ ចូរមកចុះយើងនឹងពណ៌នា

គុណរបស់ព្រាហ្មណ៍ អ្នកធ្វើការបូជាយ័ញ្ញដូច្នេះហើយ កាល ផ្ដើមពណ៌នាយ័ញ្ញ ទើបពោលថា :

៧៤. អគ្គិត្ថោ ឥតរសម្បយុត្តា
យញ្ញា ច វេទា ច សុភោគ លោកេ
តទគ្គរយ្ហំ ហិ វិជិគ្ចមានោ
ជហាតិ វិត្តញ្ច សតញ្ច ធម្មំ។

បពិត្រសុភោគ យ័ញ្ញ និងវេទទាំងឡាយក្នុងលោកនេះ ដែលព្រាហ្មណ៍ ឯទៀតប្រកបហើយមិនមែនជារបស់ផ្ដេសផ្ដាសទេ ព្រោះហេតុនោះ បុគ្គលកាលតិះដៀលព្រាហ្មណ៍ ដែលមិនគួរតិះដៀល ឈ្មោះថាលះបង់ទ្រព្យ និងធម៌របស់ពួកសប្បុរស។

បានឮមកថា គេបានពោលថា នាគបរិស័ទទាំងឡាយកុំបានដើម្បីពោលថា ព្រាហ្មណ៍នេះ បានធ្វើកម្មប្រទូសរ៉ាយចំពោះព្រះភូរិទត្តដែលជាមិត្រឡើយ។ លំដាប់នោះកាណារិដ្ឋៈបានពោលនឹងសុភោគៈនោះថា ម្នាលបងសុភោគៈ បងសុភោគៈដឹង ឬមិនដឹងថា លោកនេះអ្នកណាសាង កាលសុភោគៈឆ្លើយថា មិនដឹងដើម្បី

នឹងសម្តែងថា លោកនេះស្តេចមហាព្រហ្ម តារបស់ពួកព្រាហ្មណ៍សាង ទើបពោលគាថាទៀតថា :

៧៥. អជ្ឈេនមរិយា បឋវី ជនិន្ទា
វេស្សា កសឹ ចារិចរិយញ្ច សុទ្ទា
ឧចាគូ បច្ចេកំ យថាបទេសំ
កតាហុ ឯតេ វសិនាតិ អាហុ។

ពួកអ្នកប្រសើរ(ព្រាហ្មណ៍) ប្រកាន់ខាងការរៀនមន្ត ពួកជាធំជាងជន(ក្សត្រិយ៍)ប្រកាន់ខាងការផែនដី ពួកវេស្សៈប្រកាន់ខាងការភ្ជួររាស់ ពួកសូទ្រៈប្រកាន់ខាងការបម្រើផ្សេងៗគ្នា តាមសមគួរដល់ប្រទេស ជនទាំងឡាយបានពោលថា ត្រកូលទាំង៤នេះ ព្រហ្មបានតាក់តែងហើយ។

កាលណាវិធុរៈពោលថា ដែលឈ្មោះថា មហាព្រហ្ម ជាអ្នកមានអានុភាពច្រើនយ៉ាងនេះ ក៏កាលណាធ្វើចិត្តឲ្យជ្រះថ្លាក្នុងមហាព្រហ្មពួកនោះរមែងឲ្យទាន បុគ្គលនោះមិនមានការបដិសន្ធិក្នុងទីដទៃ រមែងទៅកាន់ទេវលោកតែម្យ៉ាង ទើបពោលថា :

៧៦. ធាតា វិធាតា វរុណោ កុវេរោ
សោមោ យមោ ចន្ទិមា វាយុ សុរិយោ
ឯតេបិ យញ្ញំ បុថុសោ យជិត្វា
អជ្ឈាយកានំ អថ សព្វកាមេ។
វិកាសិតា ចាបសតានិ បញ្ច
យោ អជ្ជុនោ ពលវា ភីមសេនោ
សហស្សពាហុ អសមោ បថព្យា
សោបិ តទា អាទហិ ជាតវេទំ។

*ទេវរាជព្រះនាមធាតុ វិធាតុ វរុណៈ កុវេរៈ សោមៈ យមៈ ចន្ទិមៈ វាយុ សុរិយៈ ស្ដេចទាំងនេះ បានបូជាយញ្ញដ៏ច្រើន ទាំង(បានឲ្យ)វត្ថុជាទីប្រាថ្នាគ្រប់យ៉ាងដល់ពួកព្រាហ្មណ៍អ្នករៀនមន្ត។ ព្រះបាទអជ្ជុនៈណាមានកម្លាំង មានសេនាគួរខ្លាច មានដៃមួយពាន់ មិនមានបុគ្គលណាស្មើ លើផែនដី ជាអ្នកយិតធ្នូ៥០០បាន ព្រះបាទអជ្ជុនៈនោះឯង ក៏បូជាភ្លើងក្នុងកាលនោះដែរ។*

កាណារិដ្ឋៈនោះកាលនឹងសរសើរចំពោះពួកព្រាហ្មណ៍ សូម្បីឲ្យក្រៃលែងឡើងទៅទើបពោលគាថាដូច្នេះថា :

៧៧. យោ ព្រាហ្មណោ ភោជយិ ទីឃរត្តំ
អន្នេន បានេន យថានុភាវំ
បសន្នចិត្តោ អនុមោទមានោ
សុភោគ ទេវញ្ញតរោ អហោសិ។

បុគ្គលណា មានចិត្តជ្រះថ្លាវិកភាយ បានញ៉ាំងព្រាហ្មណ៍ឲ្យបរិភោគបាយ និងទឹកអស់កាលយូរ ដ៏សមគួរ តាមអានុភាពបពិត្រសុភោគ បុគ្គលនោះនឹងបានជាទេវតាមួយអង្គ។ លំដាប់នោះកាណារិដ្ឋៈ កាលនឹងនាំហេតុ សូម្បីដទៃទៀតមកសម្តែងទើបពោលគាថាដូច្នេះថា :

៧៨. មហាសនំ ទេវមនោមវណ្ណំ
យោ សប្បិនា អសក្ខិ ភោជេតុមគ្គិ
សោ យញ្ញតន្តំ វរតោ យជិត្វា
ទិព្វំ គតី មុចលិន្ទជ្ឈគច្ឆិ។

ព្រះបាទមុចលិន្ទ អាចញ៉ាំងទេវតាភ្លើង ជាអ្នកស៊ីច្រើន មានពន្លឺមិនថោកទាប ឲ្យស្កប់ស្កល់ ដោយសប្បិ បានបូជាវិធីយ័ញ្ញចំពោះទេវតាភ្លើងដ៏ប្រសើរ ទ្រង់បានទៅកាន់គតិជាទិព្យ។

បានឮមកថា ព្រះរាជាមួយព្រះអង្គទ្រង់ព្រះនាមថា មុចលិន្ទ ក្នុងក្រុងពារាណសី កាលមុនទ្រង់ត្រាស់បង្គាប់ឲ្យហៅព្រាហ្មណ៍ទាំងឡាយមកហើយ សួរដល់ផ្លូវទៅកាន់ស្ថានសួគ៌។

លំដាប់នោះ ព្រាហ្មណ៍ពួកនោះ ក្រាបទូលព្រះរាជានោះថា សូមព្រះអង្គទ្រង់ធ្វើសក្ការៈដល់ពួកព្រាហ្មណ៍ និងដល់ទេវតាដែលជាព្រាហ្មណ៍ កាលព្រះរាជាទ្រង់ត្រាស់សួរថា ទេវតាដែលជាព្រាហ្មណ៍ពួកណា ទើបក្រាបទូលថា ទេវតា គឺភ្លើងដូច្នេះហើយ ទើបទូលព្រះរាជាថា សូមព្រះអង្គចូរឲ្យភ្លើងនោះឆ្អែត ដោយទឹកដោះថ្លា នឹងទឹកដោះខាប់ ព្រះរាជានោះបានទ្រង់ធ្វើយ៉ាងនោះ។ កាណារិដ្ឋៈ កាលនឹងប្រកាសសេចក្ដីនោះ ទើបពោលគាថានេះថា :

៧៩. មហាសុភាគោ វស្សសហស្សជីវី
យោ បព្វជិ ឧស្សនេយ្យោ ឧឡារោ

ហិត្វា អបរិយន្តំ រដ្ឋំ សសេនំ
រាជា ទុទីបោបព្វជាមិ សគ្គំ។

ព្រះរាជាព្រះនាមទុទីបៈ មានអានុភាពច្រើន មានព្រះជន្ម ១.០០០ឆ្នាំ បានលះបង់ដែនព្រមទាំងសេនា មិនមានទីបំផុត ហើយបួស បានជាទក្ខិណេយ្យបុគ្គល គួររមិលមើលដ៏លើសលុប ទ្រង់បានទៅកាន់ឋានសួគ៌។

កាណារិដ្ឋៈ កាលនឹងសម្ដែងឧទាហរណ៍ដទៃទៀត ដល់សុភោគៈនោះ ទើបពោលគាថាដូច្នេះថា :

៨០. យោ សាគរោ សាគរន្តំ វិជិត្វា
យូបំ សុភំ សោវណ្ណមយំ ឧឡារំ
ឧស្សេសិ វេស្សានរមាទហានោ
សុភោគ ទេវញ្ញតរោ អហោសិ។
យស្សានុភាវេន សុភោគ គង្គា
បវត្តតិ ទធិសន្និសិន្នំ សមុទ្ទំ

សោ លោមបាទោ បរិចរិយមគ្គី
អង្គោ សហស្សក្ខបុរមជ្ឈគច្ឆិ ។

បពិត្របងសុភោគ ព្រះបាទសាគរឈ្មោះផែនដី មានសាគរជាទីបំផុត បានលើកសសរយ័ញ្ញដ៏ល្អ ជាវិការៈនៃមាសដ៏លើសលុបបូជាភ្លើង ទ្រង់បានជាទេវតាមួយអង្គ។ បពិត្រសុភោគ ទន្លេគង្គា ប្រព្រឹត្តទៅដោយអានុភាពនៃព្រះរាជាណា ទឹកដោះជូរដែលស្ងប់ស្ងៀម ទៅជាសមុទ្រដោយអានុភាពនៃព្រះរាជាណា ព្រះរាជានោះ គឺព្រះបាទអង្គៈ មានរោមត្រង់ព្រះបាទ បម្រើភ្លើង ក៏ទ្រង់បានទៅកាន់បុរីនៃព្រះឥន្ទ្រ។

បពិត្របងសុភោគៈ ស្ទឹងគង្គា និងមហាសមុទ្រ អ្នកណាសាងបងដឹងទេ។ សុភោគៈពោលថា យើងមិនដឹងទេ។ កាណារិដ្ឋៈពោលថា បងមិនដឹងអ្វីសោះ បងដឹងតែវាយព្រាហ្មណ៍ប៉ុណ្ណោះ។ ក្នុងអតីតកាល ព្រះបាទក្រុងពារាណសីទ្រង់ព្រះនាមថា អង្គ-លោមបាទ ទ្រង់ត្រាស់សួរផ្លូវទៅកាន់ស្ថានសួគ៌នឹងពួកព្រាហ្មណ៍ កាលពួកព្រាហ្មណ៍ក្រាបទូលថា សូមព្រះអង្គចូលទៅកាន់ព្រៃហេ-

មពាន្ត ធ្វើសក្ការៈដល់ព្រាហ្មណ៍ទាំងឡាយ ហើយបម្រើភ្លើង ព្រះអង្គទើបនាំមេគោ និងមហេសីរកប្រមាណមិនបាន ចូលទៅកាន់ព្រៃហេមពាន្ត បានធ្វើយ៉ាងនោះ កាលព្រះរាជាទ្រង់ត្រាស់សួរថា ទឹកដោះស្រស់ និងទឹកដោះជូរដែលនៅសល់អំពី ពួកព្រាហ្មណ៍បរិភោគហើយ នឹងគប្បីធ្វើយ៉ាងណា ទើបពោលថា ចូរលះបង់ចោលៗ ក្នុងទឹកន្ទែងៗទឹកដោះនីមួយៗបន្តិចបន្តួច ត្រូវលះបង់ចោលទៅនោះៗ បានក្លាយទៅជាស្ទឹងតូច ចំណែកទឹកដោះនោះក្លាយទៅជាទឹកដោះជូរ ហូរទៅយាំងក្នុងទីណា ទីនោះបានក្លាយជាសមុទ្ទ ព្រះបាទពារាណសីបានធ្វើសក្ការៈបែបនេះ ស្តេចទៅកាន់បូរីរបស់សហស្សនេយន៍ (ភ្នែកមួយពាន់) បុគ្គលបម្រើភ្លើងតាមវិធីដែលព្រាហ្មណ៍ពោលដោយប្រការដូច្នេះៗ

កាណារិដ្ឋៈ កាលនាំអតីតនិទាននេះមក ចង្អុលបង្ហាញប្រាប់ដល់សុភោគៈដូច្នេះហើយ ទើបពោលគាថាដូច្នេះថា :

៨៣. មហិទ្ធិកោ ទេវវរោ យសស្សី

សេនាបតិ តិទិវេ វាសវស្ស

សោ សោមយាគេន មលំ វិហន្ត្វា

សុភោគ ទេវញ្ញតរោ អហោសិ ។

បពិត្រសុភោគៈ ទេវតាដ៏ប្រសើរ មានឫទ្ធិច្រើន មានយស ជាសេនាបតីនៃព្រះបាទវាសវៈ ក្នុងឋានត្រៃត្រិង្ស ព្រោះតែបាន កំចាត់បង់នូវមន្ទិល ដោយសោមយាគវិធី ក៏បានជាទេវតាមួយអង្គ។ បពិត្របងសុភោគៈដ៏ចម្រើន ឥឡូវនេះអ្នកដែលជាសេនាបតីរបស់ សក្កទេវរាជ មានយសច្រើនជាទេវបុត្រ សូម្បីអ្នកនោះកាលពីមុន ជាព្រះបាទពារាណសី សួរដល់ផ្លូវដែលជាទីទៅកាន់ស្ថានសួគ៌នឹង ពួកព្រាហ្មណ៍ កាលពួកព្រាហ្មណ៍ពោលថា សូមព្រះអង្គបណ្តេត មន្ទិលរបស់ខ្លួនដោយសោមយាគវិធី ហើយនឹងទៅកាន់ទេវលោក ទើបទ្រង់ធ្វើសក្ការៈដ៏ធំ ដល់ពួកព្រាហ្មណ៍ទាំងឡាយហើយ ធ្វើការ បូជាសោមយាគៈ តាមវិធីដែលពួកព្រាហ្មណ៍ពោលហើយ ទើប ទ្រង់កម្ចាត់មន្ទិលដោយវិធីនោះហើយ កើតជាទេពមួយព្រះអង្គ កាលនឹងប្រកាសសេចក្តីនេះ ទើបពោលយ៉ាងនេះ។ កាលកា-

ណាវិជ្ជុះនឹងសម្ដែងឧទាហរណ៍ សូម្បីដទៃទៀតដល់សុភោគៈ ទើបពោលថា :

៨២. អក្ការយិ លោកមិមំ បរញ្ច
ភាគីរថិ ហិមវន្តញ្ច វិជ្ឈំ
យោ ឥទ្ធិមា ទេវវរោ យសស្សី
សោបិ តទា អាទហិ ជាតវេទំ។
មាលាគិរិ ហិមវា យោ ច វិជ្ឈា
សុទស្សនោ និសភោ កាកនេរុ
ឃតេ ច អញ្ញេ ច នគា មហន្តា
ចិត្យា កតា យញ្ញករេភិ មាហុ។

ទេវតាដ៏ប្រសើរ ព្រហ្មមានឫទ្ធិច្រើន មានយស បានសាងលោកនេះ និងលោកដទៃ និងស្ទឹងភាគីរថីផង ភ្នំហិមពាន្តផង ភ្នំវិជ្ឈៈផង ព្រហ្មនោះឯង ក៏បានបូជាភ្លើងក្នុងកាលនោះដែរៗ ម្យ៉ាងទៀតភ្នំមាលាគិរី១ ភ្នំហិមពាន្ត១ ភ្នំវិជ្ឈៈ១ ភ្នំសុទស្សនៈ១ ភ្នំ

និសកៈ១ ភ្នំកាកវេរុ១ ពួកព្រាហ្មណ៍ពោលថា ភ្នំទាំងនេះក្តី ភ្នំដទៃធំៗក្តី ពួកព្រាហ្មណ៍អ្នកបូជាយ័ញ្ញ បានធ្វើឲ្យវិចិត្រហើយ។

ម្នាលបងសុភោគៈ មហាព្រហ្មណាបានសាងលោកនេះ និងលោកខាងមុខ ស្ទឹងភាគីរថី ស្ទឹងគង្គា ភ្នំហេមពាន្ត ភ្នំវិជ្ឈ និងភ្នំកាកវេរុក្នុងកាលណា មហាព្រហ្មសូម្បីនោះ បានជាមាណពកើតឡើងមុនព្រហ្មដទៃ ក្នុងកាលនោះគេផ្តើមបូជាភ្លើង ជាមហាព្រហ្មបានសាងវត្ថុគ្រប់យ៉ាង ព្រាហ្មណ៍អ្នកមានឫទ្ធិក៏យ៉ាងនោះៗ បានឮមកថា កាលមុនព្រះបាទក្រុងពារាណសីមួយព្រះអង្គទ្រង់ត្រាស់សួរដល់ផ្លូវទៅកាន់ស្ថានសួគ៌ដល់ពួកព្រាហ្មណ៍ កាលពួកព្រាហ្មណ៍ក្រាបទូលថា សូមព្រះអង្គធ្វើសក្ការៈដល់ពួកព្រាហ្មណ៍ ព្រះអង្គក៏បានថ្វាយមហាទានដល់ព្រាហ្មណ៍នោះហើយ ទ្រង់ត្រាស់សួរថាក្នុងការឲ្យទានរបស់ខ្ញុំនេះមិនមានផលឬ? កាលពួកព្រាហ្មណ៍ក្រាបទូលថា មានទាំងអស់ព្រះអង្គ តែអាសនៈមិនគ្រប់គ្រាន់ដល់ពួកព្រាហ្មណ៍ ទើបបង្គាប់រៀបឥដ្ឋសាងអាសនៈទាំងឡាយ។ ទីដេកនិងតាំងដែលព្រះរាជាឲ្យកសាងឡើងនោះ ចម្រើនដោយអានុភាព

របស់ពួកព្រាហ្មណ៍ ក្លាយជាភ្នំមាលាគិរីជាដើម ភ្នំពួកនោះគេនិយាយគ្នាថា ពួកព្រាហ្មណ៍អ្នកបូជាយញ្ញបានសាងទុក ដោយប្រការដូច្នេះៗ

លំដាប់នោះកាណារិដ្ឋៈទើបពោលនឹងសុភោគៈទៀតថា បងសុភោគៈ បងដឹងឬមិនដឹងថា ព្រោះហេតុអ្វីសមុទ្រនេះទើបកើតជាទឹកប្រៃផឹកមិនបានៗ សុភោគៈ និយាយថា នែ៎អរិដ្ឋៈបងមិនដឹងទេៗ កាណារិដ្ឋៈនិយាយនឹងសុភោគៈថា បងក៏ដឹងតែបៀតបៀនពួកព្រាហ្មណ៍ប៉ុណ្ណោះ មិនដឹងអ្វីដទៃឡើយ សូមចាំស្តាប់ចុះទើបពោលគាថាដូច្នេះថា :

៨៣. អជ្ឈាយកំ មន្តគុណូបបន្នំ
តបស្សិនំ យាចយោគីតិធាហុ
តីរេ សមុទ្ទស្សុទកំ សជន្តំ
តំ សាគរជ្ឈោហរិ តេនបេយ្យោ។

ជនទាំងឡាយ បានពោលចំពោះព្រាហ្មណ៍ អ្នករៀនមន្តបរិបូណ៌ដោយគុណនៃមន្ត មានតបៈក្នុងលោកនេះថា ជាអ្នក

ប្រកបដោយការសូម សាគរបានពន្ទិចព្រាហ្មណ៍នោះ ដែលស្ថិតនៅលើត្រើយកំពុងសាចទឹកសមុទ្រ ហេតុនោះបានជាសមុទ្រមានទឹកប្រៃផឹកមិនបាន។

បានឮមកថា ថ្ងៃមួយព្រាហ្មណ៍នោះធ្វើកម្ម គឺការបណ្តែតបាប ឈរនៅត្រង់ច្រាំង ដួសទឹកអំពីសមុទ្ទ ធ្វើការមុជកក់ក្បាលរបស់ខ្លួន ខណៈនោះសាគរកម្រើក ជន់លិចព្រាហ្មណ៍នោះ អ្នកធ្វើយ៉ាងនោះ មហាព្រហ្មបានស្តាប់ហេតុនោះ ទើបក្រោធថា បានជ្រាបថាសាគរនេះសម្លាប់បុត្រយើង ទើបជេរបរិភាសថា សមុទ្ទចូរផឹកមិនបាន ចូរជាទឹកប្រៃ។ ដោយហេតុនោះសមុទ្ទទើបផឹកមិនបាន ក្លាយជាទឹកប្រៃ ឈ្មោះថាព្រាហ្មណ៍ពួកនេះ មានគុណច្រើនបែបនេះ។

កាណារិដ្ឋៈពោលតទៅថា

៨៤. អាយាគវត្ថូនិ បុថុ្វ បថព្យា
សំវិជ្ជន្តិ ព្រាហ្មណា វាសវស្ស
បុរិមំ ទិសំ បច្ឆិមំ ទក្ខិណុត្តរំ

សំវិជ្ជមានា ជនយន្តិ វេធំ។

ព្រាហ្មណ៍ទាំងឡាយ ជាវត្ថុសម្រាប់បូជា មានច្រើនលើផែនដី មានក្នុងទិសខាងកើត ទិសខាងលិច ទិសខាងត្បូង និងទិសខាងជើង តែងញ៉ាំងសេចក្ដីត្រេកអរឲ្យកើតដល់វាសវៈ។



ចប់ការពណ៌នាយញ្ញវាទ

នាគជាច្រើន អ្នកមកសួរសុខទុក្ខព្រះបរមពោធិសត្វ ស្តាប់ពាក្យសម្តីរបស់កាណារិដ្ឋៈនោះហើយ ក៏បណ្តោយការយកខុសដោយគិតថា កាណារិដ្ឋៈនិយាយតែសេចក្តីពិតប៉ុណ្ណោះៗ ព្រះបរមពោធិសត្វដេកឈឺបានស្តាប់ពាក្យនោះទាំងអស់ហើយ ទាំងពួកនាគដែលមកប្រាប់ឲ្យលោកដឹងទៀតៗ លំដាប់នោះព្រះបរមពោធិសត្វគិតថា អរិដ្ឋៈពណ៌នាផ្លូវខុសៗ ណ្ហើយចុះយើងនឹងបំផ្លាញវាទៈរបស់កាណារិដ្ឋៈនោះ ហើយនឹងធ្វើបរិស័ទឲ្យជាសមាទិដ្ឋិ លោកក្រោកឡើងងូតទឹក ប្រដាប់ដោយគ្រឿងអលង្ការទាំងពួង អង្គុយខាងលើធម្មាសនៈ បង្គាប់ឲ្យនាគបរិស័ទទាំងអស់ប្រជុំគ្នាឲ្យហៅកាណារិដ្ឋៈមក ហើយពោលថា អ្នកពោលសរសើររឿងដែលមិនពិត គឺវេទយ័ញ្ញ និងព្រាហ្មណ៍ទាំងឡាយ ឈ្មោះថាការបូជាយ័ញ្ញ ដោយវិធីវេទរបស់ព្រាហ្មណ៍ទាំងឡាយមិនរាប់ថាជាវត្ថុប្រសើរឡើយ និងមិនមែនជាផ្លូវនៃស្ថានសួគ៌ យើងនឹងចង្អុលបង្ហាញសេចក្តីមិនពិតក្នុងវាទៈរបស់អ្នក ដូច្នេះហើយ កាល

នឹងផ្តើមឈ្មោះវាទៈ ដែលពោលដោយប្រភេទនៃយ័ញ្ញ ទើបពោលថា :

៨៥. កលី ហិ ធីរាន កតំ មគានំ
ភវន្តិ វេទជ្ឈគតា អរិដ្ឋ
មរីចិធម្មំ អសមេក្ខិតត្តា
មាយាគុណា នាតិវហន្តិ បញ្ញំ។
វេទា ន តាណាយ ភវន្តិ ទស្ស
មិត្តទ្ទុនោ ភូនហុនោ នរស្ស
ន តាយតេ បរិចិណ្ណោវ អគ្គិ
ទោសន្តរំ មច្ចមនរិយកម្មំ។

ម្នាលអរិដ្ឋៈ ការរៀនយកនូវវេទទាំងឡាយ ជាទោសរបស់អ្នកប្រាជ្ញទាំងឡាយ តែជាអំពើរបស់បុគ្គលពាលទាំងឡាយ (ត្រៃវេទ)ជាធម៌ ដូចថ្ងៃបណ្តើរកូន ព្រោះសំឡឹងមើលទៅ មិនស្មើ វេទទាំងឡាយ ជាចំណែកនៃកលឧបាយ ទង់ទាញអ្នកមានបញ្ញាមិនបានទេ ការពារជនអ្នកទ្រុស្តមិត្ត បំផ្លាញសេចក្តីចម្រើននោះ

ក៏មិនបានទេ ភ្លើងដែលបុគ្គលបម្រើហើយ រមែងមិនការពារនូវសត្វមានកម្មបានទេ ជារបស់មិនប្រសើរ ប្រកបដោយទោស។

៨៥, ១. សព្វញ្ច មច្ចា សធនា សភោគា
អាទីបិតំ ទារុតិណេន មិស្សំ
ទហំ ន តប្បេ អសមត្ថតេជោ
កោ តំ សុភិក្ខំ ទិរសញ្ញុ កយិរា។

មួយទៀត សត្វទាំងឡាយមានទ្រព្យ មានភោគៈ យកទ្រព្យទាំងអស់ លាយដោយឧស និងស្មៅ ហើយដុតភ្លើងមានតេជៈមិនមានអ្វីស្មើ កាលឆេះវត្ថុដែលគេដុតហើយ ក៏មិនគប្បីឆ្អែតម្នាលអ្នកដ៏ចំរើនដោយអណ្ដាតទាំងពីរ ចុះបុគ្គលណាគប្បីធ្វើភ្លើងនោះឲ្យឆ្អែតបាន។

៨៥, ២. យថាបិ ខីរំ វិបរិណាមធម្មំ
ទធិ ភវិត្វា នវនីតំបិ ហោតិ
ឯវំបិ អគ្គិ វិបរិណាមធម្មោ
តេជោ សមារូហតិ យោគយុត្តោ។

ទីរៈ(ទឹកដោះស្រស់) មានការប្រែប្រួលជាធម្មតា ក្លាយទៅជាទធិ(ទឹកដោះជូរ) ហើយទៅជានវនីត(ទឹកដោះខាប់) យ៉ាងណា ភ្លើងជាតេជោធាតុ មានការប្រែប្រួលជាធម្មតា យ៉ាងនោះដែរ លុះតែប្រេបកដោយគ្រឿងពួតទើបឆេះ។

៨៥, ៣. ន ទិស្សតិ អគ្គិមនុប្បវិដ្ឋោ
សុក្ខេសុ កដ្ឋេសុ នវេសុ ចាបិ
នាមត្ថមានោ អរណីនរេន
នាកម្មុនា ជាយតិ ជាតវេទោ។

ភ្លើងដែលចូលទៅក្នុងឈើស្ងួត ឬស្រស់ក៏មិនប្រាកដ ភ្លើងដែលនរជន មានឈើពំនួតក្នុងដៃ មិនបានពួតក៏មិនឆេះ ភ្លើងមិនមែនឆេះដោយការមិនធ្វើទេ។

៨៥, ៤. សចេ ហិ អគ្គិ អន្តរតោ វសេយ្យ
សុក្ខេសុ កដ្ឋេសុ នវេសុ ចាបិ
សព្វានិ សុស្សេយ្យុំ វនានិ លោកេ
សុក្ខានិ កដ្ឋានិ ច បជ្ជលេយ្យុំ។

ប្រសិនបើភ្លើងនៅក្នុងឈើស្ងួត ឬឈើស្រស់ នៅខាងក្នុង នៅក្នុងព្រៃទាំងអស់ក្នុងលោក គប្បីស្ងួតក្រៀម ឯឈើស្ងួតទាំង-ឡាយគប្បីឆេះ។

៨៥, ៥. ករោតិ ចេ ទារុតិណេន បុញ្ញំ
ភោជំ នរោ ធូមសិខឹ បតាបវំ
អង្គារិកា លោណករា ច សូទា
សរីរទាហាបិ ករេយ្យុ បុញ្ញំ។

ថាបើនរជនញុំាងភ្លើងដ៏ក្តៅ ប្រកបដោយផ្សែង និងអណ្តាត ឲ្យស៊ីដោយឧស និងស្មៅ ឈ្មោះថា ធ្វើបុណ្យឬ ជនអ្នកធ្វើធ្យូង អ្នកធ្វើអំបិល អ្នកធ្វើអាហារ និងអ្នកដុតសរីរៈនៃបុគ្គលស្លាប់ ឈ្មោះថាធ្វើបុណ្យដែរឬ។

៨៥, ៦. អថ ចេ ហិ ឯតេបិ ករោន្តិ បុញ្ញំ
អជ្ឈេនមគ្គឹ ឥធ តប្បយិត្វា
ន កោចិ លោកស្មិ ករោតិ បុញ្ញំ
ភោជំ នរោ ធូមសិខឹ បតាបវំ។

ប្រសិនបើព្រាហ្មណ៍ទាំងនុ៎ះ ញុំាងការរៀនមន្ត និងភ្លើងឲ្យឆេះក្នុងលោកនេះ ទើបឈ្មោះថាធ្វើបុណ្យ នរជនណាមួយក្នុងលោក កាលញុំាងភ្លើង មានកំដៅប្រកបដោយផ្សែង នឹងអណ្ដាតឲ្យស៊ី មិនឈ្មោះថា ធ្វើបុណ្យទេ។

៨៥, ៧. កថំ ហិ លោកាបចិតោ សមានោ

អមនុញ្ញគន្ធំ ពហូនំ អកន្តំ

យទេវ មច្ចា បរិវជ្ជយន្តិ

តទប្បសដ្ឋំ ទិរសញ្ញុ ភុញ្ជេ។

ម្នាលអ្នកដឹងរសដោយអណ្ដាតពីរ (អគ្គិទេពរបស់អ្នក) ដែលលោកគោរពហើយ ម្ដេចក៏ស៊ីវត្ថុមានក្លិនមិនជាទីគាប់ចិត្ត មិនជាទីត្រេកអរនៃជនដ៏ច្រើន ដែលពួកមនុស្សតែងវៀរ ជាវត្ថុមិនប្រសើរនោះ។

៨៥, ៨. សិខិម្បិ ទេវេសុ វទន្តិ ឯកេ

អាបំ មិលក្ខូ បន ទេវមាហុ

សព្វេវ ឯតេ វិតថំ ភណន្តិ

អគ្គិ ន ទេវញ្ញតរោ ន អាបោ។

*មនុស្សពួកខ្លះ ពោលថាភ្លើង(ជាទេវតាមួយអង្គ) ក្នុងពួកទេវតា ឯពួកមិលក្ខជនពោលថាទឹកជាទេវតា ជនទាំងអស់នុ៎ះពោលខុស ភ្លើងមិនមែនជាទេវតាណាមួយទេ ទឹកក៏មិនមែនដែរ។*

៨៥, ៩. អនិន្ទ្រិយំ សន្តមសញ្ញកាយំ

វេស្សានរំ កម្មករំ បជានំ

បរិចារិយមគ្គី សុគតី កថំ វជេ្ជ

បាបានិ កម្មានិ បក្រុព្វមានោ។

*ភ្លើងមិនមានឥន្ទ្រិយ ជាពួកមិនមានចេតនា សម្រាប់ធ្វើការងាររបស់ពួកមនុស្ស អ្នកធ្វើបាបកម្មទាំងឡាយ កាលបម្រើភ្លើង គប្បីទៅកាន់សុគតិដូចម្តេចកើត។*

៨៥, ១០. សព្វាភិភូតាហុច ជីវិកត្តា

អគ្គិស្ស ព្រហ្មា បរិចារិកោតិ

សព្វានុភាវី ច វសី កិមត្ថំ

អនិម្មិតោ និម្មិតំ វន្ទិតស្ស។

ពួកព្រាហ្មណ៍ជាអ្នកត្រូវការដោយជីវិតក្នុងលោកនេះពោល ថា (មហាព្រហ្ម) ជាអ្នកគ្របសង្កត់លោកនេះទាំងអស់ ហើយ ពោលថា ព្រហ្មជាអ្នកបម្រើភ្លើងដូច្នេះ បើ(មហាព្រហ្ម)មាន អានុភាពជាងលោកទាំងអស់ មានអំណាច មិនមានអ្នកណាសាង ហេតុអ្វីក៏សំពះភ្លើងដែលខ្លួននិម្មិតវិញ។

៨៥,១១. ហាសំ អជ្ឈាគមុំ អត្ថំ
សក្ការហេតុ បរិការិសុ បុព្វេ
តេ លាភសក្ការេ អបាតុភូតេ
សន្ធាភិតា ជន្តុភិ សន្តិធម្មំ។

ពាក្យព្រាហ្មណ៍ជាពាក្យគួរសើច មិនគួរដល់ការពិនិត្យ ជាពាក្យមិនពិត ពួកព្រាហ្មណ៍ក្នុងកាលមុនតាក់តែង (ពាក្យមិនពិត) ព្រោះហេតុនៃសក្ការៈ ព្រាហ្មណ៍ទាំងនោះ កាលបើលាភសក្ការៈ មិនកើតឡើងទេ ក៏តនូវសន្តិធម៌ ពោលគឺលទ្ធិរបស់ខ្លួន ជាមួយនឹងពួកសត្វ។

៨៥,១២. អញ្ញេនមរិយា បថវី ជនិន្ទា

 ១៤៨

វេស្សា កសឹ បារិចរិយញ្ច សុទ្ទា
ឧបាគូ បច្ចេកំ យថាបទេសំ
កតាហុ ឯតេ វសិនាតិ អាហុ។

ពួកអ្នកប្រសើរ (ព្រាហ្មណ៍) ប្រកាន់ការរៀនមន្ត ពួកជាធំជាងជន(ក្សត្រិយ៍)ប្រកាន់ផែនដី ពួកវេស្សៈប្រកាន់ការភ្ជួររាស់ ពួកសូទ្រៈប្រកាន់ការបម្រើផ្សេងៗគ្នា សមគួរតាមប្រទេស ជនទាំង-ឡាយបានពោលថា ត្រកូលទាំង៤នេះ ព្រហ្មបានតាក់តែងហើយ។

៨៥,១៣.ឯតញ្ច សច្ចំ វចនំ ភវេយ្យ
យថា ឥទំ ភាសិតំ ព្រាហ្មណេហិ
នាខត្តិយោ ជាតុ លភេថ រជ្ជំ
នាព្រាហ្មណោ មន្តបទានិ សិក្ខេ
នាញ្ញត្រ វេស្សា ហិ កសឹ ករេយ្យ
សុទ្ទោ ន មុញ្ចេ បរបេសនាយ។

ប្រសិនបើពាក្យនុ៎ះ ជាពាក្យពិត ដូចយ៉ាងពាក្យដែលព្រាហ្មណ៍ទាំងឡាយពោលហើយនេះ បុគ្គលមិនមែនក្សត្រិយ៍មិន

ត្រូវបានរាជ្យដោយដាច់ខាត បុគ្គលមិនមែនជាព្រាហ្មណ៍ មិនគប្បីសិក្សានូវបទនៃមន្ត បុគ្គលវៀរចាកពួកវេស្សៈ មិនគប្បីធ្វើការភ្ជួររាស់ ពួកសូទ្រៈមិនគប្បីរួចអំពីការប្រើនៃជនដទៃ។

៨៥,១៨. យស្មា ច ឯតំ វចនំ អភូតំ
មុសាវិមេ ឱទរិយា ភណន្តិ
តទប្បបញ្ញា អភិសទ្ទហន្តិ
បស្សន្តិ តំ បណ្ឌិតា អត្តនាវ។

ពាក្យនេះជាពាក្យមិនពិត ព្រោះហេតុណា (ហេតុនោះ) ព្រាហ្មណ៍ទាំងនេះពោលពាក្យកុហក ដើម្បីការបំពេញផ្ទៃ បុគ្គលអ្នកមិនមានប្រាជ្ញាទាំងឡាយ រមែងជឿស៊ប់នូវពាក្យនោះ ចំណែកខាងពួកបណ្ឌិត រមែងឃើញហេតុនោះ ដោយខ្លួនឯង។

៨៥,១៩. ខត្យា ហិ វេស្សាន ពលឹ ហរន្តិ
អាទាយ សត្ថានិ ចរន្តិ ព្រាហ្មណា
តំ តាទិសំ សង្ខុភិតំ អភិន្នំ
កស្មា ព្រហ្មា ន ឧជុំ ករោន្តិ លោកំ។

*ពួកក្សត្រិយ៍នាំយកពលី (ហូតពន្ធ) របស់ពួកវេស្សៈ ពួកព្រាហ្មណ៍កាន់យកគ្រឿងសស្ត្រាទាំងឡាយហើយដើរទៅ (សម្លាប់សត្វ) ហេតុអ្វីព្រហ្មមិនធ្វើលោកដែលជ្រួលជ្រើម បែកខ្ញែកបែបនោះនោះឲ្យត្រង់ៗ*

៨៥,១៦.សចេ ហិ សោ ឥស្សរោ សព្វលោកេ
ព្រហ្មាបហូ ភូតបតី បជានំ
កឹ សព្វលោកំ វិទហិ អលក្ខឹ
កឹ សព្វលោកំ ន សុខី អកាសិ។

*ប្រសិនបើព្រហ្មជាឥស្សរៈ ជាប្រធាន ជាម្ចាស់លើភូតរបស់ពួកសត្វក្នុងលោកទាំងអស់នោះ ហេតុអ្វីក៏ចាត់ចែងលោកទាំងអស់ឲ្យមានទុក្ខ ហេតុអ្វីមិនធ្វើលោកទាំងអស់ឲ្យបានសេចក្ដីសុខៗ*

៨៥,១៧.សចេ ហិ សោ ឥស្សរោ សព្វលោកេ
ព្រហ្មាបហូ ភូតបតី បជានំ
មាយា មុសាវជ្ជមទេន ចាបិ
លោកំ អធម្មេន កិមត្ថការី។

ប្រសិនបើព្រហ្មជាឥស្សរៈ ជាប្រធាន ជាម្ចាស់លើភូត របស់ពួកសត្វក្នុងលោកទាំងអស់នោះ ហេតុអ្វីក៏ធ្វើលោកឲ្យវិនាសដោយកលឧបាយ និងការញុាំញីដោយការពោលពាក្យកុហកដែលមិនមែនជាធម៌។

៨៥,១៨.សចេ ហិ សោ ឥស្សរោ សព្វលោកេ
ព្រហ្មាបហូ ភូតបតី បជានំ
អធម្មិកោ ភូតបតី អរិដ្ឋ
ធម្មេ សតី សោ វិទហី អធម្មំ។

ប្រសិនបើព្រហ្មជាឥស្សរៈ ជាប្រធាន ជាម្ចាស់លើភូត របស់ពួកសត្វក្នុងលោកទាំងអស់នោះ ម្នាលអរិដ្ឋៈ ព្រហ្មជាម្ចាស់លើភូតមិនប្រកបដោយធម៌ទេ ព្រោះកាលបើធម៌មាន បែរជាចាត់ចែងអធម៌វិញ។

៨៥,១៩.កីដា បដង្គា ឧរគា ច ភិង្គា
ហន្ត្វា កិមី សុជ្ឈតិ មក្ខិកា ច

ឃតេ ហិ ធម្មា អនរិយរូបា
កម្ពោជកានំ វិតថា ពហូនំ។

បុគ្គលសម្លាប់កណ្តូប កន្ទុំរុយ ពស់ កង្កែប ដង្កូវរុយ ទើបឈ្មោះថា បរិសុទ្ធ ឯធម៌ទាំងនេះ ជាធម៌របស់ជនអ្នកនៅក្នុងដែនកម្ពុជៈដ៏ច្រើន ជាធម៌មានសភាពមិនប្រសើរ ជាធម៌មិនពិត។

៨៦. សចេ ហិ សោ សុជ្ឈតិ យោ ហនាតិ
ហតោបិ សោ សគ្គមុបេតិ ឋានំ
ភោវាទិ ភោវាទិនមារយេយ្យុំ
យេ វាបិ តេសំ អភិសទ្ទហេយ្យុំ។

ប្រសិនបើអ្នកសម្លាប់នោះបរិសុទ្ធ ឬអ្នកដែលត្រូវសម្លាប់នោះទៅកាន់ឋានសួគ៌បាន ពួកព្រាហ្មណ៍គប្បីសម្លាប់ពួកព្រាហ្មណ៍ ឬសម្លាប់ពួកជនអ្នកជឿពាក្យព្រាហ្មណ៍នោះ(មុន)។

៨៦, ១. នេវ មិគា ន បសុនោបិ គាវោ
អាយាចន្តិ អត្តវធាយ កេចិ

វិប្បន្នមានា ឥធ ជីវិកត្ថា
យញ្ញេសុ ឃាណោ បសុមារភន្តិ។

មិនមានពួកម្រឹគ មិនមានពួកសត្វចិញ្ចឹម ពួកគោណាមួយ អង្វរឲ្យសម្លាប់ខ្លួនទេ សត្វទាំងឡាយក្នុងលោកនេះ សុទ្ធតែញាប់ញ័រត្រូវការដោយជីវិត (ព្រោះថា)ជនទាំងឡាយ ប្រារព្ធនឹងសម្លាប់សត្វទាំងឡាយ និងសត្វចិញ្ចឹមក្នុងយញ្ញទាំងឡាយ។

៨៦, ២. យូបុស្សនេ បសុពន្ធេ ច ពាលា
ចិត្រេហិ វណ្ណេហិ មុខំ នយន្តិ
អយន្តេ យូបោ កាមទុហោ បរត្ថ
ភវិស្សតិ សស្សតោ សម្បរាយេ។

ពួកបុគ្គលពាលរមែងបើកមាត់និយាយដោយហេតុ ទាំងឡាយដ៏វិចិត្រ ក្នុងការលើកឡើងនូវសសរយញ្ញ និងទីចងនៃសត្វចិញ្ចឹមថា សសរយញ្ញនេះបង្ហូរសេចក្តីប្រាថ្នាដល់អ្នកក្នុងបរលោក និងឲ្យសេចក្តីទៀងទាត់ក្នុងបរលោក។

៨៦, ៣. សចេ ច យូបេ មណិសង្ខមុត្តំ
ធញ្ញំ ធនំ រជតំ ជាតរូបំ
សុក្ខេសុ កដ្ឋេសុ នវេសុ ចាបិ
សចេ ទុហេ តិទិវេ សព្វកាមេ
តេវិជ្ជសង្ឃា បុថូ យជេយ្យុំ
ន ព្រាហ្មណា កិញ្ចិ ន យាជយេយ្យុំ។

ប្រសិនបើបុគ្គលគប្បីបានកែវមណី ស័ង្ខ កែវមុក្តា ស្រូវ ទ្រព្យ ប្រាក់ និងមាសក្នុងសសរយ័ញ្ញ ក្នុងឈើស្ងួត និងឈើស្រស់ ម្យ៉ាងទៀតប្រសិនបើ សសរយ័ញ្ញគប្បីបង្ហូរសេចក្តីប្រាថ្នាគ្រប់យ៉ាង ក្នុងឋានសួគ៌ ពួកជនអ្នកចេះត្រៃវេទដ៏ច្រើនគប្បីបូជាបុគ្គលមិនមែន ជាព្រាហ្មណ៍ មិនគប្បីបូជាតិចតួចទេ។

៨៦, ៤. កុតោ ច យូបេ មណិសង្ខមុត្តំ
ធញ្ញំ ធនំ រជតំ ជាតរូបំ
សុក្ខេសុ កដ្ឋេសុ នវេសុ ចាបិ

កុតោ ធុវោ តិធិវេ សព្វកាមេ។

កែវមណី ស័ង្ខ កែវមុក្តា ស្រូវ ទ្រព្យ ប្រាក់ មាសក្នុងសសរយ័ញ្ញ ក្នុងឈើស្ងួត និងឈើស្រស់ នឹងមានពីណា សសរយ័ញ្ញនឹងបង្ហូរសេចក្តីប្រាថ្នាគ្រប់យ៉ាង ក្នុងឋានសួគ៌ដូចម្តេចកើត។

៨៦, ៥. សឋា ច លុទ្ធា ច បលុទ្ធពាលា
ចិត្រេហិ វណ្ណេហិ មុខំ នយន្តិ
អាទាយ អគ្គឹ មម ទេហិ វិត្តំ
តតោ សុខី ហោហិសិ សព្វកាមេ។

ពួកព្រាហ្មណ៍ជាអ្នកបោកប្រាស ចិត្តអាក្រក់ ជាពួកពាលប្រលោមលោក តែបើកមាត់និយាយដោយហេតុដ៏វិចិត្រថា អ្នកឯងចូរយកភ្លើងចុះ ហើយឲ្យទ្រព្យដល់យើង លំដាប់នោះអ្នកឯងនឹងបាននូវសេចក្តីប្រាថ្នាគ្រប់យ៉ាងហើយ នឹងដល់នូវសេចក្តីសុខ។

៨៦, ៦. តមគ្គិហុត្តំ សរណំ បវិស្ស
ចិត្រេហិ វណ្ណេហិ មុខំ នយន្តិ

ឱរោបយិត្វា កេសមស្សុំ នខញ្ចុ

វេធេហិ វិត្តំ អតិគាឡ្ហយន្តិ។

*ពួកព្រាហ្មណ៍ នាំបុគ្គលជាសរណៈ(ព្រះរាជា និងមហាមាត្យ) ចូលទៅកាន់រោងសម្រាប់បូជាភ្លើងនោះ ក៏បើកមាត់និយាយដោយហេតុដ៏វិចិត្រ ឲ្យកោរសក់ ពុកមាត់ កាត់ក្រចក ហើយគាបយកទ្រព្យដោយវេទទាំងឡាយ។*

៨៦,៧. កាកា ឧលូកំវ រហោ លភិត្វា

ឯកំ សមានំ ពហុកា សមេច្ច

អន្នានិ ភុត្វា កុហកា កុហិត្វា

មុណ្ឌំ ករិត្វា យញ្ញបថោ សជន្តិ។

*ពួកព្រាហ្មណ៍ជាអ្នកកុហកដ៏ច្រើន បានទាយកម្នាក់ ហើយក៏ចោមស៊ីបាយ ដូចជាក្អែកទាំងឡាយ ចោមចាប់មៀមក្នុងទីស្ងាត់ កុហកធ្វើឲ្យរលីង ហើយដាក់ចុះទៅក្នុងផ្លូវនៃយញ្ញ។*

៨៦,៨. ឯវំ ហិ សោ វញ្ចិតោ ព្រាហ្មណេហិ

ឯកោ សមានោ ពហុកា សមេច្ច
តេ យោគយោគេន វិលុម្បមានា
ទិដ្ឋំ អទិដ្ឋេន ធនំ ហរន្តិ។

ទាយកតែម្នាក់នោះត្រូវពួកព្រាហ្មណ៍ បញ្ឆោតហើយដោយអាការៈយ៉ាងនេះ ឯព្រាហ្មណ៍ទាំងនោះជាច្រើនចោមប្លន់ដោយការប្រកបដោយឧបាយ ក៏នាំយកទ្រព្យ ដែលឃើញដោយទេវលោកដែលមិនឃើញសោះ។

៨៦,៩. អកាសិយា រាជូហិ វានុសិដ្ឋា
តទស្ស អាទាយ ធនំ ហរន្តិ
តេ តាទិសា ចោរសមា អសន្តា
វជ្ឈា ន ហញ្ញន្តិ អរិដ្ឋ លោកេ។

ដូចយ៉ាងពួករាជបុរស ដែលព្រះរាជាប្រើទៅហើយ ក៏នាំយកទ្រព្យនោះរបស់គេ ម្នាលអរិដ្ឋៈ ពួកព្រាហ្មណ៍ប្រាកដដូច្នេះប្រហែលគ្នានឹងពួកចោរ ជាអសប្បុរស ជាបុគ្គលគួរសម្លាប់ តែគេមិនសម្លាប់ក្នុងលោក។

៨៦,១០. ឥន្ទស្ស ពាហារសិ ទក្ខិណាតិ
យញ្ញេសុ ឆិន្ទន្តិ បលាសយដ្ឋឹ
តញ្ចេបិ សច្ចំ មឃវា ឆិន្នពាហុ
កេនស្ស ឥន្ទោ អសុរេ ជិនាតិ។

ពួកព្រាហ្មណ៍បានកាត់ដើមចា មកប្រើក្នុងវិធីយ័ញ្ញ(ប្រាប់ថានេះ)ជាដៃស្តាំរបស់ព្រះឥន្ទ្រ បើពាក្យនោះពិត ព្រះឥន្ទ្រទៅជាដាច់ដៃ ចុះព្រះឥន្ទ្រឈ្នះពួកអសុរៈដោយកម្លាំងដៃដូចម្តេច។

៨៦,១១. តញ្ចេវ តុច្ឆំ មឃវា សមង្គី
ហន្តា អវជ្ឈោ បរមោ សុទេវោ
មន្តា ឥមេ ព្រាហ្មណា តុច្ឆរូបា
សន្ទិដ្ឋិកា វញ្ចនា ឯស លោកេ។

ពាក្យនោះទទេសោះ ព្រះឥន្ទ្រនៅមានដើមដៃគ្រប់គ្រាន់ ជាទេវតាដ៏ប្រសើរ មិនមានអ្នកណាសម្លាប់បាន បានកម្ចាត់ពួកអសុរ មន្តទាំងឡាយនេះ របស់ពួកព្រាហ្មណ៍ មានសភាពជារបស់ទទេ នេះជាការបញ្ឆោត ដែលគេឃើញច្បាស់ក្នុងលោក។

៨៦,១២. មាលាគិរិ ហិមវា យោ ច វិជ្ឈា
សុទស្សនោ និសភោ កាកវេរុ
ឯតេ ច អញ្ញេ ច នគា មហន្តា
ចិត្រា កតា យញ្ញករេហិ មាហុ។

ភ្នំមាលាគិរី១ ភ្នំហិមពាន្ត១ ភ្នំវិជ្ឈៈ១ ភ្នំសុទស្សនៈ១ ភ្នំនិសភៈ១ ភ្នំកាវេរុ១ ភ្នំទាំងនុ៎ះក្តី ភ្នំធំៗឯទៀតក្តី ព្រាហ្មណ៍ទាំង-ឡាយពោលថា ពួកព្រាហ្មណ៍អ្នកបូជាយ័ញ្ញ កសាងហើយដ៏វិចិត្រដូច្នោះ។

៨៦,១៣. យថាបការានិ ហិ ឥដ្ឋកានិ
ចិត្រា កតា យញ្ញករេហិ មាហុ
ន បព្វតា ហោន្តិ តថាបការា
អញ្ញា ទិសា អចលា ទិដ្ឋសេលា។

ព្រាហ្មណ៍ទាំងឡាយពោលថា ភ្នំទាំងឡាយ ដែលពួកព្រា-ហ្មណ៍អ្នកបូជាយ័ញ្ញ កាន់យកឥដ្ឋទាំងឡាយ មានប្រការយ៉ាងណា ធ្វើវិចិត្រហើយ ភ្នំទាំងឡាយមិនមែនមានប្រការដូច្នោះទេ ឯ

ភ្នំទាំងឡាយ មិនដូចរបស់ដទៃទេ ជារបស់មិនកម្រើក ជាថ្មសុទ្ធ ដែលគេឃើញច្បាស់ៗ

៨៦,១៨.ន ឥដ្ឋកា ហោន្តិ សិលា ចិរេន
ន តត្ថ សញ្ជាយតិ អយោ ន លោហំ
យញ្ញញ្ច ឯតំ បរិវណ្ណយន្តា
ចិត្យា កតា យញ្ញករេភិមាហុ។

ភ្នំទាំងឡាយមិនមែនជាឥដ្ឋទេ ជាថ្មយូរយារហើយ ដែកមិនមែនកើតក្នុងឥដ្ឋនោះទេ លោហៈក៏មិនមែនកើតក្នុងឥដ្ឋនោះដែរ ពួកព្រាហ្មណ៍កាលសរសើរនូវយញ្ញនេះ បានពោលថា ភ្នំទាំង-ឡាយដែលពួកព្រាហ្មណ៍អ្នកបូជាយញ្ញ ធ្វើវិចិត្រហើយៗ

៨៦.១៩.អជ្ឈាយកំ មន្តគុណូបបន្នំ
តបស្សិនំ យាចយោគីតិធាហុ
តីរេ សមុទ្ទស្សុទកំ សជន្តំ
តំ សាគរជ្ឈោហរិ តេនបេយ្យោ។

ព្រាហ្មណ៍ទាំងឡាយក្នុងលោកនេះ បានពោលនូវព្រាហ្មណ៍អ្នករៀនមន្ត បរិបូណ៌ដោយគុណនៃមន្ត មានតបៈ ថាជាអ្នកប្រកបដោយការសូម សាគរពន្ទិចព្រាហ្មណ៍នោះ ដែលកំពុងសាចទឹកនៃសមុទ្រលើប្រាំង ព្រោះហេតុនោះ បានជាទឹកសមុទ្រនោះប្រែផឹកមិនបាន។

៨៦,១៦.បរោសហស្សំបិ សមន្តវេទេ
មន្តូបបន្នេ នទិយោ វហន្តិ
ន តេន ព្យាបន្នរសូទកានិ
កស្មា សមុទ្ទោ អតុលោ អបេយ្យោ។

ស្ទឹងទាំងឡាយកួចយកពួកព្រាហ្មណ៍ អ្នកបរិបូណ៌ដោយវេទ បរិបូណ៌ដោយមន្តច្រើនជាងពាន់នាក់ ទឹកទាំងឡាយមិនខូចរស ព្រោះហេតុនោះទេ សមុទ្រមិនមានអ្វីស្មើ មានរសប្រែ ផឹកមិនបាន តើព្រោះហេតុអ្វី។

៨៦,១៧.យេ កេចិ កូបា ឥធ ជីវលោកេ
លោណូទកា កូបខណោហិ ខាតា

ន ព្រាហ្មណាជ្ឈាហារណោន តេសុ
អាបោ អបេយ្យា ទិរសញ្ញុរាហុ។

*អណ្តូងខ្លះ ក្នុងជីវលោកនេះ មានទឹកប្រៃដែលពួកជនអ្នកផឹកអណ្តូង បានផឹកហើយ ម្នាលអ្នកដ៏ងរសដោយអណ្តាតទាំងពីរ ជនទាំងឡាយមិនពោលថា ទឹកក្នុងអណ្តូងទាំងនោះ មានរសប្រៃផឹកមិនបាន ព្រោះតែកួចយកព្រាហ្មណ៍ទេ។*

៨៦,១៨. បុរេ បុរត្ថា កា កស្ស ភរិយា
មនោ មនុស្ស អជនេសិ បុព្វេ
តេនាបិ ធម្មេន ន កោចិ ហីនោ
ឯវម្បិ វោស្សគ្គវិភង្គមាហុ។

*តាំងពីមុនដំបូងមក ស្ត្រីណាជាភរិយារបស់បុរសណា មនោបានញុំាងមនុស្សឲ្យកើតឡើងក្នុងកាលមុន មិនមានអ្នកណាមួយថោកទាបជាងគ្នាដោយធម៌នោះ ព្រាហ្មណ៍ទាំងឡាយបានពោលនូវការចែក(វណ្ណៈ) ដោយការលះបង់ (ធម៌នោះ) យ៉ាងនេះឯង។*

៨៦,១៩. ចណ្ឌាលបុត្តោបិ អធិច្ច វេទេ

ភាសេយ្យ មន្តេ កុសលោ មតីមា
ន តស្ស មុទ្ធា វិផលេយ្យ សត្តធា
មន្តា ឥមេ អត្តវធាយ កតា ។

សូម្បីកូនចណ្ឌាល ជាអ្នកឈ្លាសវៃមានប្រាជ្ញា បានរៀនវេទទាំងឡាយ ពោលមន្តទាំងឡាយ ក្បាលនៃកូនជនចណ្ឌាលនោះមិនបែកជា៧ភាគទេ មន្តទាំងឡាយនេះពួកព្រាហ្មណ៍ធ្វើហើយដើម្បីសម្លាប់ខ្លួន ។

៨៦,២០. វាចា កតា គិទ្ធិ កតា គហិតា
ទុម្មោចយា កាព្យាបថានុបន្នា
ពាលាន ចិត្តំ វិសមេ និវិដ្ឋំ
តទប្បបញ្ញា អភិសទ្ទហន្តិ ។

វាចាកុហក ពួកព្រាហ្មណ៍បានតាក់តែងហើយ ការចង់បាន ពួកព្រាហ្មណ៍បានតាក់តែង កាន់យកហើយ កើតឡើងតាមគន្លងនៃកាព្យឃ្លោង ដែលគេស្រាយបានដោយក្រ ចិត្តរបស់បុគ្គល

ពាលទាំងឡាយជឿស៊ប់ក្នុងអំពើមិនស្មើ បុគ្គលឥតប្រាជ្ញា រមែងជឿពាក្យនោះៗ

៨៦,២១.សីហស្ស ព្យគ្ឃស្ស ច ទីបិនោ ច
ន វិជ្ជតី ឱរសិយំ ពលេន
មនុស្សភាវោ ច គវំវ បេក្ខោ
ជាតី ហិ តេសំ អសមា សមានំ។

ព្រាហ្មណ៍មិន(ប្រកប)ដោយកម្លាំងដ៏មាំ ដូចកម្លាំងនៃរាជសីហ៍ ខ្លាធំ និងខ្លាដំបង មនុស្សភាព(របស់ព្រាហ្មណ៍ទាំងនោះ) ត្រូវយល់ថា ដូចគោដែរ ព្រោះជាតិរបស់ព្រាហ្មណ៍ទាំងនោះ ស្មើ (ដោយគោ) ស្មើដោយសីហៈជាដើមៗ

៨៦,២២.សចេ ច រាជា បថវី វិជិត្វា
សជីវវា អស្សវា ចារិសជ្ជោ
សយមេវ សោ សត្តុសង្ឃំ វិជេយ្យ
តស្សប្បជា និច្ច សុខី ភវេយ្យ។

ប្រសិនបើព្រះរាជាឈ្នះផែនដី ប្រកបដោយអាមាត្យ មាន អ្នកស្តាប់បង្គាប់ មានបរិស័ទ ព្រះរាជានោះគប្បីឈ្នះពួកសត្រូវ ដោយព្រះអង្គឯង ប្រជាជនរបស់ព្រះរាជានោះ គប្បីបានសេចក្តីសុខជានិច្ច។

៨៦,២៣. ខត្តិយមន្តា ច តយោ ច វេទា
អត្ថេន ឯតេ សមកា ភវន្តិ
តេសញ្ច អត្ថំ អវិនិច្ឆិនិត្វា
ន ពុជ្ឈតិ ឱឃបថំវ ឆន្នំ។

មន្តរបស់ក្សត្រិយ៍ និងវេទទាំង៣នេះ ស្មើគ្នាដោយអត្ថ (តែក្សត្រិយ៍ក្តី ព្រាហ្មណ៍ក្តី) មិនបានវិនិច្ឆ័យនូវអត្ថនៃមន្ត និងវេទទាំងនោះទេ ទាំងមិនដឹង ដូចបុគ្គលកាលមិនដឹងផ្លូវដែលកំបាំងដោយទឹក។

៨៦,២៤. ខត្តិយមន្តា ច តយោ ច វេទា
អត្ថេន ឯតេ សមកា ភវន្តិ
លាភោ អលាភោ យសោ អយសោ ច

សព្ពេវ តេសំ ចតុន្នញ្ច ធម្មា។

មន្តរបស់ក្សត្រិយ៍ និងវេទទាំង៣នេះ ស្មើគ្នាដោយអត្ថលាភ ឥតលាភ យស និងឥតយសទាំងអស់នេះជាធម៌របស់វណ្ណៈទាំង៤នោះ។

៨៦,២៥.យថាបិ ឥព្ភា ធនធញ្ញហេតុ
កម្មានិ ការេន្តិ បុថូ បថព្យា
តេវិជ្ជសង្ឃាបិ តថេវ អជ្ជ
កម្មានិ ការេន្តិ បុថូ បថព្យា។

ពួកគហបតី ជាច្រើនលើផែនដី ញុំាងបុគ្គលឲ្យធ្វើការងារទាំងឡាយ ព្រោះហេតុតែទ្រព្យ និងស្រូវយ៉ាងណា សូម្បីពួកអ្នកមានត្រៃវេទជាច្រើនលើផែនដី ក៏ញុំាងបុគ្គលឲ្យធ្វើការងារទាំង-ឡាយ ក្នុងថ្ងៃនេះ យ៉ាងនោះដែរ។

៨៦,២៦.ឥព្ភេហិ យេតេ សមកា ភវន្តិ
និច្ចុស្សុកា កាមគុណេសុ យុត្តា

កម្មានិ ការេន្តិ បុថុ បថព្យា

គតប្បបញ្ញា ធិរសញ្ញា តេ។

ព្រាហ្មណ៍ទាំងនោះស្មើគ្នានឹងគហបតី ព្រាហ្មណ៍ទាំងឡាយជាច្រើន លើផែនដី ជាអ្នកខ្វល់ខ្វាយជានិច្ច ប្រកបក្នុងកាមគុណទាំងឡាយ តែងញ៉ាំងបុគ្គលឲ្យធ្វើការងារទាំងឡាយ ម្នាលអរិដ្ឋៈអ្នកដឹងរសដោយអណ្តាតទាំងពីរ ព្រោះហេតុនោះ ព្រាហ្មណ៍ទាំងនោះ ជាអ្នកឥតបញ្ញា។

ព្រះបរមពោធិសត្វ កាលបំផ្លាញវាទៈរបស់ព្រាហ្មណ៍នោះហើយ ឲ្យតាំងនៅក្នុងវាទៈរបស់ព្រះអង្គ ដោយប្រការដូច្នេះ។ នាគបរិស័ទទាំងអស់បានស្តាប់ធម្មកថា របស់ព្រះបរមពោធិសត្វហើយ ក៏នាំគ្នាកើតសោមនស្ស ចំណែកព្រះបរមពោធិសត្វ (ភូរិទត្ត) ទើបបង្គាប់ឲ្យនាគបរិស័ទ នាំព្រាហ្មណ៍នេសាទចេញអំពីនាគពិភព សូម្បីតែការបរិភាស ក៏មិនបានធ្វើដល់ព្រាហ្មណ៍នោះឡើយ។



ចប់បរិបូណ៌

ចំណែក ព្រះបាទសាគរព្រហ្មទត្ត មិនបានកន្លងហួសថ្ងៃដែលទ្រង់កំណត់ទុក ព្រះរាជាស្ដេចយាងទៅកាន់អាស្រមរបស់ព្រះរាជបិតាព្រមទាំងចតុរង្គសេនា ចំណែកភូរិទត្តដែលជាព្រះពោធិសត្វ ក៏បង្គាប់ឲ្យវាយស្គរស្រែកប្រកាសថា យើងនឹងទៅគាល់សម្ដេចព្រះបិតុលា និងព្រះអយ្យកោរបស់យើង ហើយក៏ព្រះភូរិទត្តស្ដេចឡើងអំពីស្ទឹងយមុនាដោយសិរីដ៏ល្អល្អះឆ្ពោះទៅកាន់អាស្រមបទនោះ បងប្អូនក្រៅអំពីនោះ និងព្រះមាតាបិតា ក៏ទៅតាមខាងក្រោយ ក្នុងខណៈនោះព្រះបាទសាគរព្រហ្មទត្តទតព្រះនេត្រឃើញព្រះបរមពោធិសត្វមកជាមួយនាគបរិស័ទជាច្រើន ព្រះរាជាចាំមិនបាន កាលនឹងទូលសួរព្រះរាជបិតា ទើបត្រាស់ថា :

៨៧. កស្ស ភេរី មុទិង្គា ច សង្ខា បណវទិន្ទិមា
បុរតោ បដិបន្នានិ ហាសយន្តា រថេសភំ ។

ស្គរធំ សម្ភោរ ស័ង្ខ ស្គរជ័យនឹងស្គរទ័ពរបស់អ្នកណាដែលដើរខាងមុខ ហើយញ៉ាំងព្រះរាជាដ៏ប្រសើរក្នុងរថឲ្យរីករាយ។

៨៧,១. កស្ស កញ្ចនបដ្ដេន បុថុនា វិជ្ជុវណ្ណិនា
យុវា កលាបសន្នទ្ធោ កោ ឯតិ សិរិយា ជលំ។

(សម្បុរមុខ) របស់អ្នកណា(ដ៏រុងរឿង) ដោយជម្ពូរមាស ដ៏ក្រាស់ មានពន្លឺដូចផ្លេកបន្ទោរ អ្នកណានៅកម្លោះប្រដាប់ដោយ បំពង់ព្រួញរុងរឿងដោយសិរីហើយដើរមក។

៨៧,២. ឧក្កាមុខេ បហដ្ឋំវ ខទិរង្គារសន្និភំ
មុខំ ចារុរិវាភាតិ កោ ឯតិ សិរិយា ជលំ។

មុខអ្នកណាស្រស់បស់ដូចមាសឆ្អិន លើមាត់ជើងក្រាន ឬ ប្រាកដស្មើដោយរងើកនៃឧសគគីរ អ្នកណារុងរឿងដោយសិរី ហើយដើរមក។

៨៧,៣. កស្ស ជម្ពោនទំ ឆត្តំ សសលាកំ មនោរមំ
អាទិច្ចរំសាវរណំ កោ ឯតិ សិរិយា ជលំ។

ឆ័ត្ររបស់បុគ្គលណាជាវិការៈនៃមាសជម្ពូនទ ប្រកបដោយ ឆ្អឹងជាទីរីករាយនៃចិត្ត ជាគ្រឿងបិទបាំង រស្មីនៃព្រះអាទិត្យ អ្នក ណារុងរឿងដោយសិរី ហើយដើរមក។

៨៧,៤. កស្ស អគ្គំ បរិគ្គយ្ហ វាលវិជនិមុត្តមំ
ឧភតោ វរបញ្ញស្ស មុទ្ធនិ ឧបរូបរិ។

*អគ្គ(អ្នកកាន់ផ្ចិត) បានកាន់យកវាលវិជនីដ៏ឧត្តម ខាងលើក្បាលទាំងពីរខាងនៃបុគ្គលមានបញ្ញាដ៏ប្រសើរណា។*

៨៧,៥. កស្ស បេក្ខុណហត្ថានិ ចិត្រានិ ច មុទូនិ ច
សុវណ្ណមណិទណ្ឌានិ ចរន្តិ ឧភតោមុខំ។

*បាច់នៃកន្ទុយក្ងោកដ៏វិចិត្រផង ទន់ផង មានដងជាវិការៈនៃមាស និងកែវមណី ប្រព្រឹត្តទៅទាំងពីរខាងមុខរបស់បុគ្គលណា។*

៨៧,៦. ខទិរង្គារវណ្ណាភា ឧក្កាមុខបហំសិតា
កស្សេតេ កុណ្ឌលា វគ្គូ សោភន្តិ ឧភតោ មុខំ។

*កុណ្ឌលទាំងឡាយនេះដ៏ល្អ មានពន្លឺដូចជាពណ៌រងើកភ្លើងនៃឧសគគីរ ដ៏ភ្លឺលើមាត់ជើងក្រាន រមែងរុងរឿងទាំងពីរខាង មុខរបស់បុគ្គលណា។*

៨៧,៧. កស្ស វាតេន ឆុបិតា សិនិទ្ធគ្គា មុទុកាឡិកា
សោភយន្តិ នលាតន្តំ នភា វិជ្ជុរិវុគ្គតា។

សក់របស់បុគ្គលណា មានចុងដ៏ស្និទ្ធ ទន់ ខ្មៅត្រូវខ្យល់បក់ហើយ ក៏ញ៉ាំងទីបំផុតនៃថ្ងាសឲ្យល្អ ដូចជាផ្លេកបន្ទោរដែលចេញអំពីមេឃ។

៨៧,៨. កស្ស ឯតានិ អក្ខីនិ អាយតានិ បុថូនិ ច
កោ សោភតិ វិសាលក្ខោ កស្សេតំ ឧណ្ណជំ មុខំ
កស្សេតេ លបនជាតា សុទ្ធា សង្ខវរូបមា
ភាសមានស្ស សោភន្តិ ទន្តា កុប្បិលសាទិសា។

ភ្នែកទាំងនេះវែងធំរបស់អ្នកណា អ្នកណាមានភ្នែកទូលាយសមមុខនេះ របស់អ្នកណា ភ្លឺថ្លះដូចកញ្ចក់មាស មាត់នេះរបស់អ្នកណា ដ៏ស្អាតដូចជាស័ង្ខ ដ៏ប្រសើរ ធ្មេញរបស់បុគ្គលណាកាលនិយាយឡើងដូចជាផ្កាមណ្ឌាក្រពុំ។

៨៧,៩. កស្ស លាខារសសមា ហត្ថបាទា សុខេ ឋិតា
កោ សោ តិម្ពោដ្ឋសម្បន្នោ ទិវា សុរិយោវ សោភតិ។

ដៃ និងជើងទាំងឡាយរបស់អ្នកណាដូចជាទឹកល័ក្ខតាំងនៅ

ក្នុងសេចក្ដីសុខ អ្នកណាមានរិមបបូមាត់ដូចផ្លែបាស ដ៏ល្អដូចជាព្រះអាទិត្យក្នុងវេលាថ្ងៃ។

៨៧, ១០. ហិមច្ចយេ ហិមវតោ មហាសាលោវ បុប្ផិតោ

កោ សោ ឱទាតចាវាសោ ជយំ ឥន្ទោវ សោភតិ។

អ្នកណា មានសំពត់បាវារៈដ៏សដូចដើមរាំងដ៏ធំមានផ្ការីកហើយ ក្នុងព្រៃហិមពាន្តក្នុង កាលដែលកន្លងទៅនៃទឹកសន្សើមល្អដូចព្រះឥន្ទ្រដែលមានជ័យជម្នះ។

៨៧, ១១. សុវណ្ណបីឡកាកិណ្ណំ មណិទណ្ឌវិចិត្តកំ

កោ សោ បរិសមោគ្គយ្ហ អំសេ ឧក្កំ បមុញ្ចតិ។

អ្នកណានៅក្នុងបរិស័ទ ដោះដាវនៅលើស្មា ដែលមានដងដ៏វិចិត្រដោយកែវមណី ដ៏ដេរដាសដោយពក ជាវិការៈនៃមាស។

៨៧, ១២. សុវណ្ណវិកតា ចិត្រា សុកតា ចិត្រសិព្វិនី

កោ សោ ឱមុញ្ចតេ បាទា នមោ កត្វា មហេសិនោ។

អ្នកណាដោះស្បែកជើង ដែលប៉ាក់ដោយមាស វិចិត្រដោយ

កែវ៧ប្រការ ដេរដោយសូត្រដ៏វិចិត្រ របទាល្អហើយ ក៏ថ្វាយបង្គំតាបសអ្នកស្វែងរកគុណដ៏ធំ។

តាបសជាបិតាពោលថា :

៨៨. ធតរដ្ឋស្ស តេ នាគា ឥទ្ធិមន្តោ យសស្សិនោ
សមុទ្ទជាយ ឧប្បន្នា ឯតេ នាគា មហិទ្ធិកាតិ។

នាគទាំងនោះ ជានាគមានឫទ្ធិ មានយស ជាកូននៃព្រះបាទធតរដ្ឋ កើតអំពីនាងសមុទ្ទជា នាគទាំងនេះ សុទ្ធតែជានាគមានឫទ្ធិច្រើន។

កាលព្រះរាជឫសី និងព្រះបាទសាគរព្រហ្មទត្ត ត្រាស់យ៉ាងនេះ នាគបរិស័ទទាំងឡាយ ទើបនាំគ្នាថ្វាយបង្គំព្រះតាបស ហើយអង្គុយក្នុងទីដ៏សមគួរ។ ចំណែកនាងសមុទ្ទជា ក៏ថ្វាយបង្គំព្រះរាជបិតា និងព្រះរាជមាតាហើយ ក៏បរិទេវនា ព្រះកន្សែង ហើយក៏នាំនាគបរិស័ទត្រឡប់ទៅកាន់នាគពិភពវិញ។ ចំណែកព្រះបាទសាគរព្រហ្មទត្ត ទ្រង់ប្រថាប់ក្នុងទីនោះពីរបីថ្ងៃ ទើបថ្វាយបង្គំលាខមាទោស ព្រះរាជបិតាហើយ ក៏ត្រឡប់ទៅកាន់ក្រុងពារាណសីវិញ។ នាងសមុទ្ទជាទេវី ក៏អស់ជីវិតក្នុងនាគពិភពនោះឯង។

ចំណែកព្រះពោធិសត្វ ក៏រក្សាសីលរហូតអស់ជីវិត ក្នុងទីបំផុតព្រះជន្មាយុ ក៏បានទៅកើតឯស្ថានសួគ៌ជាមួយនឹងនាគបរិស័ទ។

ព្រះបរមសាស្តា កាលទ្រង់នាំធម្មទេសនានេះមកហើយទ្រង់ត្រាស់ថា ម្នាលឧបាសកទាំងឡាយ បុរាណបណ្ឌិត កាលព្រះពុទ្ធជាម្ចាស់ នៅមិនទាន់កើតឡើង ក៏នៅទ្រង់លះបង់នាគសម្បត្តិបែបនេះ ធ្វើឧបោសថកម្មដូច្នេះ។ ទើបប្រជុំជាតកថាមាតាបិតារបស់ភូរិទត្តក្នុងកាលនោះ បានមកជាសក្យរាជត្រកូលព្រាហ្មណ៍នេសាទបានមកជាទេវទត្ត សោមទត្តបានមកជាព្រះអានន្ទនាងអច្ចិមុខី បានមកជាឧប្បលវណ្ណា សុទស្សនៈបានមកជាព្រះសារីបុត្រ សុភោគៈបានមកជាព្រះមោគ្គល្លាន កាណារិដ្ឋៈបានមកជាសុនក្ខត្តលិច្ឆវី ភូរិទត្តបានមកជាព្រះតថាគត។



ចប់ភូរិទត្តជាតកាទី (២)

# អារម្ភកថា

សៀវភៅរឿង ព្រះភូរិទត្តបំពេញសីលបារមី នេះខ្ញុំបានដកស្រង់ចេញពីគម្ពីរព្រះត្រៃបិដកលេខ៦២ ព្រមទាំងសេចក្តីអត្ថាធិប្បាយនៅក្នុងគម្ពីរអដ្ឋកថា យកមករួមធ្វើជាសៀវភៅ។

ក្នុងការចងក្រងជាសៀវភៅនេះឡើង ដើម្បីតម្រូវការដល់ការសិក្សាផ្នែកខាងព្រះពុទ្ធសាសនា ឱ្យពុទ្ធបរិស័ទយើងបានយល់អំពីការកសាងបារមីរបស់ព្រះពោធិសត្វ ដែលព្រះអង្គយោនយកកំណើតកើតនៅក្នុងវាលវដ្តសង្សារ។ សូម្បីតែព្រះអង្គកើតជាសត្វតិរច្ឆានក៏ដោយ ក៏ព្រះអង្គអាចបំពេញសីលបារមីកើតបានដែរ។ ដែលព្រះឥន្ទ្រាធិរាជបានប្រសិទ្ធនាមថា ព្រះភូរិទត្ត ព្រោះលោកប្រកបដោយបញ្ញាដ៏បរិបូណ៌ស្មើដោយផែនដី។ ហើយក៏បានទៅឧបដ្ឋាកសក្កទេវរាជ ឃើញវេជ្ជយន្តប្រាសាទដែលកម្មវិចិត្រហើយ និងសម្បត្តិរបស់ព្រះឥន្ទ្រាធិរាជ គួរជាទីមនោរម្យក្រៃពេកពាសពេញទៅដោយស្រីទេពអប្សរ ទើបធ្វើសេចក្តីប្រាថ្នាក្នុងទេវលោក រួបគិតឡើងថា យើងនឹងមានប្រយោជន៍អ្វីចំពោះអត្តភាពនេះ ដោយមានកង្កែបជាអាហារ។ ហើយទៅកាន់ពិភពនាគរក្សាឧបោសថ តែមិនអស់ចិត្តក៏ឡើងមកកាន់មនុស្សលោកយើងនេះ នៅលើដំបូកមួយ របូតអាលម្ពាយន៍ ដែលជាហ្មពស់

ចាប់យកទៅធ្វើបាបស្ទើរផុតជីវិត តែព្រះអង្គមិនបានក្រេវក្រោធ មិនបានតបតឡើយ ព្រោះខ្លាចដាច់សីល។ សេចក្ដីត្រង់នេះ សបញ្ជាក់ឱ្យឃើញថា ព្រះសម្មាសម្ពុទ្ធ ព្រះអង្គមានគុណដ៏ធ្ងន់ រហូតលះបង់អ្វីៗទាំងអស់នៅលើលោក ដើម្បីដូរយកនូវពោធិញ្ញាណតែម្យ៉ាង រួបបម្លងសត្តនិករឱ្យដល់ត្រើយ ពោលគឺព្រះនិព្វាន ជាឋានបរមសុខ។

ដូច្នេះហើយសៀវភៅនេះក៏ជាផ្នែកមួយ អាចជួយដល់ស្មារតីអ្នកកាន់ព្រះពុទ្ធសាសនា ឱ្យងាកបែរមករកសម្មាទិដ្ឋិយល់ត្រូវ ហើយលះបង់អស្មិមានះចេញ រួបបំពេញទាន សីល ភាវនាដ៏សមគួរ តាមឧបនិស្ស័យរៀងៗខ្លួន ដល់ទីបំផុតនៃអនាគតជាតិ បានសម្រេចនូវលោកុត្តរសម្បត្តិ រហូតដល់ព្រះនិព្វាន។

# ឧទ្ទិសកថា

បុណ្យកុសលនៃការប្រឹងប្រែងយកចិត្តទុកដាក់ បងក្រងនូវសៀវភៅរឿងព្រះភូរិទត្តនេះ សូមឧទ្ទិសស្នាដៃទាំងនេះជូនដល់បុព្វការីជនទាំងឡាយ មានមាតា បិតា និងញាតិកាក្នុងសង្សារវដ្តទាំងអស់ ព្រមទាំងពពួកភូមទេវតា អាកាសទេវតា អារក្ខទេវតា និងទេវតាឆកាមាវចរសួគ៌ ព្រមទាំងសព្វសត្វទាំងអស់ក្នុងសែនកោដិចក្រវាឡ រហូតដល់ស្ដេចយមរាជ ឬសព្វសត្វនៅក្នុងអបាយភូមិទាំងអស់ ដែលអាចអនុមោទនាបាន ចូរត្រេកអរអនុមោទនាឱ្យបានគ្រប់ៗគ្នា ទីបំផុតសូមឱ្យបានសម្រេចនូវសន្តិបទ គឺព្រះនិព្វានកុំបីឃ្លៀងឃ្លាតឡើយ។

*សូមអនុមោទនា!!!*

ភិក្ខុធម្មចារោ **សាន្ត~សប្បាយ**

# អ្នកមានឧបការៈក្នុងការបោះពុម្ពសៀវភៅធម៌

១- ភិក្ខុ សុត្តបញ្ញោ **ហង្ស-សុគឿន** វត្តវិសុទ្ធិមគ្គ ជួយកែសម្រួល ។

២- ភិក្ខុ សក្យបុត្តោ **ប៊ុត្ត-សំបាន** វត្តវិសុទ្ធិមគ្គ ជួយកែសម្រួល ។

៣- ភិក្ខុ ធម្មភាណកោ **ពាញ-ប៊ូពា** វត្តស្វាយរមៀត រចនាបទរូប ។

៤- សាមណេរ **គាន់-ចន្ទ្រា** វត្តវិសុទ្ធិមគ្គ ជួយកែសម្រួល ។

៥- ឧបាសក **សោម-សុភាព** ភ្នំពេញ ជួយកែសម្រួល ។

៦- ឧបាសក **សុន្ទរ-សាមឿន** ភ្នំពេញ ជួយកែសម្រួល ។

៧- ឧបាសក **ស៊ឹម-រតនះ** សៀមរាប បច្ចេកទេសកុំព្យូទ័រ និង កែសម្រួល ។

# មាតិកានុក្រម

ឈ្មោះមាតិកា.............................................លេខទំព័រ

១- អារម្ភបទ, ឧទ្ទិសកថា, អ្នកមានឧបការៈ, មាតិកានុក្រម, សង្ខេបរឿង **ក** ដល់ **ខ**

២- កច្ឆបកណ្ឌ.......................................................០១ ដល់១៨

៣- នគរកណ្ឌ....................................................... ១៩ ដល់២៩

៤- ឧបោសថកណ្ឌ................................................... ៣០ ដល់៣៦

៥- ព្រាហ្មណនេសាទកណ្ឌ.........................................៣៧ ដល់៥៦

៦- សុបណ្ណកណ្ឌ.................................................... ៥៧ ដល់៦០

៧- សោមទត្តកុមារ................................................ ៦១ ដល់៧១

៨- សោមទត្តកណ្ឌ..................................................៧២ ដល់៧៣

៩- សីលកណ្ឌ..........................................................៧៤ ដល់៧៦

១០- អាលម្ពាយនកណ្ឌ................................................៧៧ ដល់៨២

១១- វិលាបកណ្ឌ.........................................................៨៣ ដល់៩៧

១២- នាគវេសនកណ្ឌ...................................................៩៨ ដល់១១៤

១៣- សុភោគកណ្ឌ...................................................១១៥ ដល់១២២

១៤- ការពណ៌នាយញ្ញវាទ..........................................១២៣ ដល់១៣៧

១៥- យញ្ញភេទកណ្ឌ.................................................១៣៨ ដល់១៦៦

១៦- ភូរិទត្តជាតក.....................................................១៦៧ ដល់១៧៤

# កំណាព្យ សង្ខេបរឿងព្រះភូរិទត្ត

*(ស្មូត្រតាមលំនាំបទគោរពទង់ព្រះពុទ្ធសាសនា)*

ព្រះភូរិទត្ត កាលត្រាច់រង្គាត់ មានចិត្តអត់ធ្មត់ ក្នុងវដ្តសង្សារ
កំណើតជានាគ ប្រសើរថ្លៃថ្លា កសាងសីលា ព្រះបារមីញាណ។
កម្មអកុសល បានហុចមកដល់ ឱ្យលោកខ្វាយខ្វល់ បានលំបាកប្រាណ
តែបេះកែខៃ ប្ដូររូបទៅបាន ដល់ទីសុខសាន្ត នាឋានសួស្ដី។
ព្រះភូរិទត្ត បញ្ញាប្រាកដ ព្រះឥន្ទ្រិយស្មារតិ បេះគ្រប់អ្វីៗ
ដោះស្រាយបញ្ហា ដល់ជនប្រុសស្រី ទោះទេវតាក្ដី មិនអាចប្រៀបផ្ទឹម។
លោកមានបញ្ញា ស្មារតីក្លៀវក្លា ស្មើដោយពសុធា ឱ្យគេសង្ឃឹម
យកជាទីពឹង និងដោយញញឹម ព្រោះអត្តមានខ្លឹម តាមពុទ្ធដីកា។
កាលឃើញប្រាសាទ ស្អិតស្អាងដោយស្អាត ល្អល្អះត្រូវខ្នាត ព្រះឥន្ទ្រនុះណោះ
ទើបតាំងក្នុងចិត្ត គិតរកប្រាថ្នា ឱ្យជាទេវតា ដូចព្រះឥន្ទ្រគ្រប់។
ធ្វើឧបោសថ មានចិត្តលំអុត លំឱនបរិសុទ្ធិ ក្នុងនាគពិភព
សប្បាយក្នុងធម៌ បរិវទាំងគ្រប់ ព្រោះជ្រកក្រោមម្លប់ នៃព្រះធម្មា។
កន្លះខែម្ដង ព្រះអង្គបំណង ដោយក្ដីប៉ុនប៉ង ចូលគាល់មាតា
បិតាសួនគ្រង គន្លងអស្ចារ្យ ដោយក្ដីប្រាថ្នា បម្រើផ្ទាល់ដៃ។

ធ្វើកិច្ចជានិច្ច គ្មានសតិភ្លេច ឱ្យបានសម្រេច ប្រសើរថ្លៃថ្លៃ
ឱ្យលោកពេញចិត្ត គំនិតប្រពៃ ក្នុងប្រធាននៃ គុណធំច្បាស់ច្បង។
នាឋានភុជង្គ- នាគនៅយូរលង់ ឱបោសបទ្រង់ មិនល្អហ្មត់ហ្មង
ទើបឡើងស្ថានមនុស្ស ដោយក្ដីប៉ុនប៉ង ឱបោសបផង លើដំបូកមួយ។
ព្រោះជាស្ថានស្ងាត់ ពួតែមាត់សត្វ ទៅមកប្រវាត់ ពុំមានក្ដីព្រួយ
ជួបព្រាននេសាទ សង្វាតលើកស្ទួយ ឱ្យព្រាននោះជួយ កុំប្រាប់អ្នកណា។
ដូច្នេះព្រះអង្គ មិននៅយូរលង់ នាំទៅភុជង្គ ព្រាននឹងបុត្រា
ឱ្យសោយសម្បត្តិ ភពក្នុងជលសា ទាំងពីរកាយា បានមួយឆ្នាំដែរ។
ទើបត្រឡប់វិញ គ្មានចិត្តទោម្នេញ ដោយការទន្ទេញ ព្រោះចង់នៅក្បែរ
សាច់ញាតិគ្រួសារ អ្នកចំការស្រែ មានចិត្តប្រួលប្រែ ព្រោះបុណ្យតិចក្ដាត់។
តែព្រាននេសាទ ភ្លេចប្បាប់ឱវាទ កាន់ធមិប្រមាទ ទ្រុស្តពោធិសត្វ
ទៅប្រាប់ហ្មពស់ ព្រោះតែសម្បត្តិ ឱ្យចាប់មហាសត្វ ភូរិទត្តណា។
ព្រះមហាសត្វថ្លៃ មានជាតិប្រពៃ ដោយប្រធាននៃ ព្រោះទ្រង់ចរិយា
មិនហ៊ានតបត ខ្ជាបជាប់សីលា សុខចិត្តកាយា ទៅតាមហ្មពស់។
បង្គាប់ព្រះអង្គ ទៅតាមចិត្តចង់ បានទ្រព្យពេញបង់ ហ្មបានល្បីឈ្មោះ
ព្រះអង្គធ្វើតាម ស្មើរគ្មានពេលលោះ ព្រានបានកិត្តិយស មិនលែងព្រះអង្គ។
បាននាគជាញាតិ តាមព្រះអង្គព្រាត មិនឱ្យមានឃ្លាត ឥតនៅរេរង់
យកព្រះអង្គវិញ ទៅឋានភុជង្គ ជួបញាតិវង្ស សប្បាយក្រាស់ក្រៃ។

# ៥

ព្រះពោធិសត្វ    បង់នៅទីស្ងាត់    ដោយហាត់ពេកក្លាត់ ព្រោះឬព្រៃផ្សៃ
ឱ្យនាគប្អូនយាម    ទាំងយប់ទាំងថ្ងៃ    ញាតិនាគដទៃ    មកសួរសុខទុក្ខ។
កាលនោះអរិដ្ឋ    អនុជនៃបតិត្យ    គេឱ្យនៅជិត    យាមជាបន្ទុក
គាត់បេះប្រាប់ព្រាហ្មណ៍ ក្រាស់ក្រៃលប្រើនមុខ ពន្យល់ថាសុខ រឿងយញ្ញបូជា។
ពួកនាគទាំងឡាយ    បានស្តាប់បរិយាយ    មានចិត្តសប្បាយ    យល់ខុសគ្រប់គ្នា
ថាបូជាយញ្ញ    ឱ្យប្រើនមហិមា    នោះបានទៅជា    អង្គទេពប្រសើរ។
ព្រះពោធិវង្ស    បានស្តាប់ហើយទ្រង់ បង់បំបាក់បង់    ឱ្យបាត់គ្រាន់បើ
ឱ្យយល់ត្រូវវិញ    ទើបបានប្រសើរ    បុះតាមដំណើរ    នៃព្រះធម្មា។
ញ៉ាំងនាគបរិស័ទ    ឱ្យបេះលះកាត់    តាមពោធិសត្វ    យល់ត្រូវគ្រប់គ្នា
កាន់បរិយាធម៌    បវរសោភា    ក្នុងភពនាគា    មានសីលល្អស្អាត។
សូមសាធុជន    ចូរកុំទម្រន់    កិច្ចការស្រោលធ្ងន់ កុំកើតប្រមាទ
ប្រព្រឹត្តធម៌ល្អ    បន្តធម៌ស្អាត    ឡើងកាន់ប្រាសាទ ធម៌ព្រះសម្ពុទ្ធ។
ដោយសីលនោះណា ជួយគ្រងរក្សា    ឆ្លងផុតជលសា    ដល់ទីបំផុត
ឱ្យបានរស់នៅ ក្នុងស្ថានបរិសុទ្ធ    សីលមិនធ្លាក់ស្រុត ចូលទីទាបឡើយ។
ចូរអ្នកមានសីល    ភាវនាកុំខ្ជិល    និងលះមន្ទិល    កុំបីមានស្បើយ
ប្រព្រឹត្តឱ្យស្អាត    សង្វាតឱ្យហើយ    នោះបានដល់ត្រើយ សួគ៌និព្វានឆាយ។

*ដោយឧបាសក* **ស៊ឹម~រតនៈ**



បោះពុម្ពលើកទី១ ចំនួន ១.០០០ច្បាប់

សម្រាប់ជាធម្មទាន